អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

# ព្រឹត្តិបត្រពន្ធដារ

ត្រីមាសទី២ ឆ្នាំ២០២៤













លេខ៖ ១០

មេសា - មិថុនា ២០២៤

# អារម្ភកថា



រាជរដ្ឋាភិបាលថ្មីអាណត្តិទី៧ ដែលមានសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** ជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីដំបូង នីតិកាលទី៧ នៃរដ្ឋសភា នៅថ្ងៃព្រហស្បតិ៍ ទី២៤ ខែសីហា ឆ្នាំ២០២៣ និងបានប្រកាសដាក់ចេញ "**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១**" ដើម្បីជំរុញកំណើនសេដ្ឋកិច្ច បង្កើតការងារ ធានាសមធម៌ បង្កើនប្រសិទ្ធភាព និងរក្សាចីរភាព សំដៅឆ្លើយតបនឹងបំណងប្រាថ្នាប្រជាជន ឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ ជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ និងឆ្នាំ២០៥០ ជាប្រទេសមានចំណូលខ្ពស់។

ភាគីពាក់ព័ន្ធទាំងស្ថាប័នរដ្ឋ និងវិស័យឯកជននៃរាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងគាំទ្រនិងចូលរួមយ៉ាងសកម្មក្នុងការអនុវត្តកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាលថ្មីអាណត្តិទី៧ ដើម្បីសម្រេចបាននូវបំណងប្រាថ្នាទាំងពីរខាងលើ។ ស្របជាមួយគ្នានេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមានអគ្គនាយកដ្ឋានពន្ធដារជាសេនាធិការ និងមានតួនាទីប្រមូល និងគ្រប់គ្រងចំណូលពន្ធផ្ទៃក្នុងដែលជាផ្នែកមួយដ៏សំខាន់នៃថវិកាសម្រាប់អភិវឌ្ឍជាតិ ក៏បាននិងកំពុងបន្តប្តេជ្ញាយកចិត្តទុកដាក់លើការកែទម្រង់ទាំងគោលនយោបាយនិងរដ្ឋបាលសារពើពន្ធ ពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ប្រកបដោយភាពសុចរិត និងស្មើភាពចំពោះអ្នកជាប់ពន្ធ ដើម្បីជំរុញអនុលោមភាពដោយស្ម័គ្រចិត្តឈានទៅសម្រេចបាននូវការប្រមូលចំណូលពន្ធប្រកបដោយចីរភាព ក្នុងគោលដៅលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនកម្ពុជា។ ជាមួយគ្នានេះ ក្នុងទិសដៅផ្តល់សេវាគ្រប់មធ្យោបាយជូនអ្នកជាប់ពន្ធឱ្យកាន់តែប្រសើរ និងទទួលបានព័ត៌មានត្រឹមត្រូវនិងទាន់ពេលវេលា អគ្គនាយកដ្ឋានពន្ធដារបានរៀបចំបោះពុម្ពព្រឹត្តិបត្រពន្ធដារប្រចាំត្រីមាសចំនួន ៩ លេខ តាំងពីដើមឆ្នាំ២០២២ និងបន្តចងក្រងបោះពុម្ព សម្រាប់ត្រីមាសទី២ ឆ្នាំ២០២៤ ទៀត ជាមួយនឹងមាតិកា រួមមាន ព្រឹត្តិការណ៍សំខាន់ៗ, ស្ថានភាពនៃការគ្រប់គ្រងប្រមូលចំណូលពន្ធ, វឌ្ឍនភាពការងារនៃមុខងារប្រតិបត្តិការស្នូលនិងមុខងារគាំទ្រ, បច្ចុប្បន្នភាពច្បាប់ លិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ និងគោលនយោបាយសារពើពន្ធ, កិច្ចសហប្រតិបត្តិការក្របខ័ណ្ឌជាតិ-អន្តរជាតិ និងការផ្សព្វផ្សាយនិងបញ្ជ្រាបវប្បធម៌បង់ពន្ធ។

ក្នុងនាមជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ខ្ញុំមានជំនឿថាលោក លោកស្រី សាធារណជន និងស្ថាប័នជាតិ-អន្តរជាតិ នឹងជ្រាបកាន់តែច្បាស់អំពីស្ថានភាពគ្រប់គ្រងការប្រមូលចំណូលពន្ធនិងវឌ្ឍនភាពថ្មីៗ ជាពិសេសកិច្ចខិតខំប្រឹងប្រែងរបស់អគ្គនាយកដ្ឋានពន្ធដារក្នុងការធ្វើបច្ចុប្បន្នកម្មបទប្បញ្ញត្តិនិងទំនើបកម្មរដ្ឋបាលសារពើពន្ធនិងប្រព័ន្ធបច្ចេកវិទ្យា ស្របតាមគោលនយោបាយ ទស្សនវិស័យ និងទិសដៅរបស់រាជរដ្ឋាភិបាលកម្ពុជាដែលបានដាក់ចេញតាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ៕

ថ្ងៃសុក្រ ៧ កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ពុទ្ធសករាជ ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៤

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**



**គង់ វិបុល**

# ព្រឹត្តិបត្រពន្ធដារ

## ត្រីមាសទី២ ឆ្នាំ២០២៤

**សមាសភាពទទួលបន្ទុកតាក់តែង និពន្ធ និងបោះពុម្ពព្រឹត្តិបត្រពន្ធដារ**

| | | |
|---|---|---|
| និពន្ធនាយក | ៖ | ឯកឧត្តម **គង់ វិបុល** |
| គណៈដឹកនាំ | ៖ | លោក **វៀម វដ្ឋា** និងលោក **កែ ឈុំបញ្ញា** |
| អ្នករៀបរៀងអត្ថបទ | ៖ | លោកស្រី **សេង ច័ន្ទមុន្នី** លោកស្រី **ដេត ពុទ្ធាវី** និងលោក **រិន ណារ៉ូ** |
| អ្នករចនា | ៖ | លោក **លីម សិទ្ធិ** កញ្ញា **ឈៀង សុខឡេង** និងលោក **សារិន ម៉េងហៀង** |
| អ្នកផ្តល់រូបភាព | ៖ | លោក **ចិត្ស ចំរើនបញ្ញា** លោក **សុន្ទរៈ ត្រដឹម** និងលោក **ឥន្ទ វាសនា** |
| អ្នកស្រាវជ្រាវ | ៖ | លោក **ជុំ សូលីវណ្ណ** លោក **សំរិទ្ធ មករា** លោក **រិទ្ធ តីណា** កញ្ញា **សុធីរ វឌ្ឍនា** លោកស្រី **សាវិន វីនីហ្សា** និងលោក **អាន ចាន់ថាណារិទ្ធ** |
| អ្នកកែសម្រួលអក្ខរាវិរុទ្ធ | ៖ | លោក **អ៊ុន សំបុក** និងលោក **ជា ពិសិដ្ឋ** |
| អ្នកបោះពុម្ព | ៖ | លោក **ស៊ុនលី ជីនី** |
| អ្នកផ្សព្វផ្សាយព័ត៌មាន និងចែកចាយ | ៖ | លោកស្រី **ឌីពៅ ចិត្សធីយ៉ា** លោកស្រី **ថុង ស្រីពៅ** លោក **មូ សុភ័ក្ត្រ** និងលោក **ឡាង តក្កា** |

# មាតិកា


**ព្រឹត្តិការណ៍សំខាន់ៗ........................................................................................................៧**

**ផ្នែកទី១៖ ស្ថានភាពនៃការគ្រប់គ្រងការប្រមូលចំណូលពន្ធ**

១. លទ្ធផលការងារប្រមូលចំណូលពន្ធ.......................................................................................២៩

២. ស្ថានភាពចំណូលពន្ធតាមប្រភេទអ្នកជាប់ពន្ធ.........................................................................២៩

៣. ស្ថានភាពចំណូលពន្ធតាមប្រភេទពន្ធសំខាន់ៗ........................................................................៣០

៤. ស្ថានភាពចំណូលពន្ធតាមសកម្មភាពអាជីវកម្មសំខាន់ៗ.............................................................៣១

**ផ្នែកទី២៖ វឌ្ឍនភាពការងារនៃមុខងារប្រតិបត្តិការស្នូល និងមុខងារគាំទ្រ**

១. ការចុះបញ្ជីពន្ធដារ....................................................................................................... ៣៥

២. ការផ្តល់សេវាអ្នកជាប់ពន្ធ................................................................................................. ៣៥

៣. ការចាត់ចែងលិខិតប្រកាសពន្ធ.........................................................................................៤២

៤. ការធ្វើសវនកម្មពន្ធដារ.....................................................................................................៤៣

៥. ការប្រមូលបំណុលពន្ធ និងបណ្តឹងតវ៉ា ................................................................................ ៤៣

៦. បច្ចេកវិទ្យាព័ត៌មាន .........................................................................................................៤៤

**ផ្នែកទី៣៖ បច្ចុប្បន្នភាពច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយសារពើពន្ធ**

១. ប្រកាស........................................................................................................................៥១

២. សេចក្តីណែនាំ................................................................................................................៥២

៣. សេចក្តីជូនដំណឹង.........................................................................................................៥២

**ផ្នែកទី៤៖ កិច្ចសហប្រតិបត្តិការក្របខ័ណ្ឌជាតិ-អន្តរជាតិ**

១. សកម្មភាពផ្សេងៗរបស់អគ្គនាយកដ្ឋានពន្ធដារ.......................................................................៥៧

២. កិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័ន..........................................................................៦៤

៣. កិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន អង្គការ សមាគម និងស្ថាប័នអន្តរជាតិ.........................៦៨

៤. កិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា ( Double Taxation Agreement-DTA )...... ៨៣

**ផ្នែកទី៥៖ ការផ្សព្វផ្សាយ និងបង្រៀនវប្បធម៌បង់ពន្ធ**

១. កិច្ចការបណ្តុះបណ្តាល និងសិក្ខាសាលារបស់សាលាជាតិពន្ធដារ..............................................៩០

២. ការស្រាវជ្រាវ អភិវឌ្ឍន៍កម្មវិធី និងបណ្ណាល័យ.......................................................................៩១

៣. សិក្ខាសាលាសំខាន់ៗ........................................................................................................៩៣

**សំណួរ និងចម្លើយ...........................................................................................................១០២**

# ទស្សនវិស័យ

អគ្គនាយកដ្ឋានពន្ធដារ ជាស្ថាប័នសាធារណៈ
ដែលត្រូវបានជឿជាក់ គោរព និងទទួលស្គាល់លើ
គុណភាពនិងជំនាញ ក្នុងការប្រមូលចំណូលពន្ធក្នុងស្រុក
ដើម្បីចូលរួមអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព

# បេសកកម្ម

អគ្គនាយកដ្ឋានពន្ធដារ ពង្រឹងការអនុវត្តច្បាប់
និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ និងផ្តល់សេវាប្រកបដោយ
ស័ក្តិសិទ្ធិភាព តម្លាភាព គណនេយ្យភាព និងសុចរិតភាព ដើម្បីធានាបាននូវប្រសិទ្ធភាព
នៃការប្រមូលចំណូលពន្ធ និងលើកកម្ពស់អនុលោមភាពដោយស្ម័គ្រចិត្ត

# គុណតម្លៃ

អគ្គនាយកដ្ឋានពន្ធដារបំពេញបេសកកម្ម និង
ធ្វើប្រតិបត្តិការរបស់ខ្លួន ដោយប្រកាន់ខ្ជាប់នូវគុណតម្លៃ ដូចខាងក្រោម ៖

| ការអនុវត្ត | វិជ្ជាជីវៈ | ស័ក្តិសិទ្ធិភាព | សុចរិតភាព | ភាពបត់បែន |
|---|---|---|---|---|
| អនុវត្តច្បាប់ គាំទ្រអ្នកជាប់ពន្ធដែលមានអនុលោមភាព តែម៉ឺងម៉ាត់ចំពោះអ្នកជាប់ពន្ធដែលមិនមានអនុលោមភាព | ប្រើប្រាស់ក្រមសីលធម៌វិជ្ជាជីវៈ និងជំនាញ ដើម្បីផ្តល់នូវសេវាដែលមានភាពសាមញ្ញ ងាយស្រួល ឆ្លាតវៃ និងនវានុវត្តន៍ | ប្រើប្រាស់ធនធានដោយសន្សំសំចៃ ទាន់ពេលវេលា និងចំគោលដៅ | ផ្តល់សេវាអ្នកជាប់ពន្ធដោយស្មើភាព តម្លាភាព និងស្អាតស្អំ | ឆ្លើយតបយ៉ាងសកម្មទៅនឹងបញ្ហាប្រឈម និងទាញយកប្រយោជន៍ពីគ្រប់ឱកាសដែលមាន |

# គោលបំណង

អគ្គនាយកដ្ឋានពន្ធដារបានកំណត់ចេញនូវគោលបំណងជាយុទ្ធសាស្ត្រសំខាន់ៗ
ចំនួន៣ សម្រាប់ជាត្រីវិស័យក្នុងការតម្រង់ទិសនៃកំណែទម្រង់រដ្ឋបាលសារពើពន្ធ

| គោលបំណងទី១ | គោលបំណងទី២ | គោលបំណងទី៣ |
|---|---|---|
| បង្កើនអនុលោមភាពសារពើពន្ធតាមរយៈការលើកកម្ពស់គុណភាព ភាពច្បាស់លាស់ តម្លាភាព និងគណនេយ្យភាពក្នុងការផ្តល់សេវា និងការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ | បន្តធ្វើបរិវត្តកម្មឌីជីថលរដ្ឋបាលសារពើពន្ធ ដើម្បីក្លាយជារដ្ឋបាលសារពើពន្ធ ២.០ បូក | បន្តអភិវឌ្ឍមូលធនមនុស្ស និងពង្រឹងប្រសិទ្ធភាពការងារ |

# “យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១”

## ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និង ចីរភាព
## កសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០

### បាវចនា ៥៖

កំណើន, ការងារ, សមធម៌, ប្រសិទ្ធភាព និងចីរភាព

### អាទិភាពគន្លឹះ ៥៖

មនុស្ស, ផ្លូវ, ទឹក, ភ្លើង និងបច្ចេកវិទ្យាឌីជីថល

### គោលដៅយុទ្ធសាស្ត្រ ៥៖

១.កំណើនសេដ្ឋកិច្ច ៧% ប្រចាំឆ្នាំ ២.បង្កើនការងារ (បរិមាណ និងគុណភាព) ៣.កាត់បន្ថយភាពក្រីក្រ ៤.ពង្រឹងប្រសិទ្ធភាពការងារ និង៥.ចីរភាពនៃការអភិវឌ្ឍសង្គមជាតិនិងការកសាងភាពធន់

### ស្នូលនៃយុទ្ធសាស្ត្រ ៥៖ អភិបាលកិច្ច

១. ការកែទម្រង់ស្ថាប័ន
២. ការពង្រឹងប្រសិទ្ធភាពការងារ
៣. ការពង្រឹងភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ
៤. ការពង្រឹងប្រសិទ្ធភាពច្បាប់ និងប្រព័ន្ធយុត្តិធម៌ និង
៥. អភិបាលកិច្ចវិស័យឯកជន

### បរិស្ថានគ្របដណ្តប់ ៥៖

១.ការបន្តពង្រឹងសន្តិភាព ស្ថិរភាព សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ
២.ការប្រកាន់ខ្ជាប់នូវនយោបាយការបរទេសឯករាជ្យផ្អែកច្បាប់និងឈ្លាសវៃ
៣.ការធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច
៤.ការកសាងភាពជាដៃគូ និង
៥.ការបន្តធ្វើសមាហរណកម្មស៊ីជម្រៅក្នុងតំបន់ និងសកលលោក

### បញ្ចកោណយុទ្ធសាស្ត្រ ៥៖

**បញ្ចកោណទី១៖** ការអភិវឌ្ឍមូលធនមនុស្ស
**បញ្ចកោណទី២៖** ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើនភាពប្រកួតប្រជែង
**បញ្ចកោណទី៣៖** ការអភិវឌ្ឍវិស័យឯកជន និងការងារ
**បញ្ចកោណទី៤៖** ការអភិវឌ្ឍប្រកបដោយភាពធន់, ចីរភាព និងបរិយាបន្ន
**បញ្ចកោណទី៥៖** ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល

### កម្មវិធីគោលនយោបាយអាទិភាព ៦ សម្រាប់ចាប់ផ្តើមអនុវត្តភ្លាមក្នុងឆ្នាំ២០២៣៖

១.ការពង្រីកសេវាថែទាំសុខភាព ឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសកល ២.ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនិងបច្ចេកទេស ជូនដល់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យនៅទូទាំងប្រទេស ៣.ការធ្វើស្ថាបនូបនីយកម្មកម្មវិធីជាតិជំនួយសង្គម សម្រាប់គ្រួសារក្រីក្រ ក្រុមជនងាយរងគ្រោះនៅក្នុងគ្រួសារក្រីក្រនិងគ្រួសារងាយរងហានិភ័យនៅក្នុងគ្រាមានវិបត្តិសេដ្ឋកិច្ច និងគ្រាមានអាសន្ន ៤.ការដាក់ចេញយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ (ចូលរួមក្នុងប្រព័ន្ធនិងអាចទទួលបានផលប្រយោជន៍ពីប្រព័ន្ធគាំពារសង្គមផ្លូវការ) ៥.ការដាក់ចេញនូវយន្តការសម្របសម្រួល និងកម្មវិធីហិរញ្ញប្បទាន សំដៅលើកស្ទួយផលិតកម្ម រកទីផ្សារ និងរក្សាលំនឹងថ្លៃកសិផលសំខាន់ៗ ក្នុងកម្រិតសមរម្យ និង៦.ការដាក់ពង្រាយមន្ត្រីបច្ចេកទេសកសិកម្មទៅគ្រប់ឃុំ-សង្កាត់ ដែលមានសកម្មភាពកសិកម្មនៅទូទាំងប្រទេស។

### វិធានការគន្លឹះ ៥៖

១.ការពង្រឹងសមត្ថភាពរដ្ឋបាលសាធារណៈ (ពង្រឹងគុណភាព ប្រសិទ្ធភាពនិងសមិទ្ធកម្មរបស់មន្ត្រី និងស្ថាប័ន) ២.ការលើកកម្ពស់គុណភាពអប់រំ (ពង្រឹងគុណភាពសាលារដ្ឋពីថ្នាក់មត្តេយ្យដល់មធ្យមសិក្សា-K12) ៣.ការលើកកម្ពស់គុណភាពសេវាសុខាភិបាល (ពង្រឹងសមត្ថភាពផ្តល់សេវាសុខភាពបឋមនៅមូលដ្ឋាន) ៤.ការពង្រឹងការអនុវត្តគោលនយោបាយ “ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព (កាត់បន្ថយ និងឈានទៅដល់ការលុបបំបាត់ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀននៅក្នុងសហគមន៍) និង៥.ការពង្រឹងនិងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌។

# ព្រឹត្តិការណ៍សំខាន់ៗ




កិច្ចប្រជុំកំពូលធុរកិច្ចអាស៊ាន-កម្ពុជា

( Cambodia-ASEAN Business Summit )

សូមអានពិស្តារនៅទំព័រទី ៩



ការចុះត្រួតពិនិត្យវឌ្ឍនភាពគម្រោងសាងសង់អគារអគ្គនាយកដ្ឋានពន្ធដារថ្មី

សូមអានពិស្តារនៅទំព័រទី ១១



កិច្ចប្រជុំពិភាក្សាស្តីពីបញ្ហាប្រឈមនិងដំណោះស្រាយចំពោះការចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ( CamDX )

សូមអានពិស្តារនៅទំព័រទី ១៣



កិច្ចប្រជុំពិនិត្យលើវឌ្ឍនភាពការងារនៃអង្គវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១៩

សូមអានពិស្តារនៅទំព័រទី ១៤



ជំនួបពិភាក្សាការងាររវាងឯកឧត្តម គង់ វិបុល និង ឯកអគ្គរដ្ឋទូតបារាំង អាល្លឺម៉ង់ និងសហភាពអឺរ៉ុប ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

សូមអានពិស្តារនៅទំព័រទី ១៦



សិក្ខាសាលាផ្សព្វផ្សាយផ្ទៃក្នុង ស្តីពីសៀវភៅណែនាំ ស្តីពីបែបបទនិងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារសម្រាប់មន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ និងសៀវភៅណែនាំស្តីពីការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ

សូមអានពិស្តារនៅទំព័រទី ១៩



កិច្ចប្រជុំពិភាក្សាកម្រិតបច្ចេកទេស លើកទី៣ របស់អនុក្រុមការងារសមាគមពាណិជ្ជកម្មកម្ពុជា-ជប៉ុន និងអគ្គនាយកដ្ឋានពន្ធដារ

សូមអានពិស្តារនៅទំព័រទី ២១



ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវអគារសាខាពន្ធដារខេត្តកំពង់ធំ

សូមអានពិស្តារនៅទំព័រទី ២៣

# កិច្ចប្រជុំកំពូលធុរកិច្ចអាស៊ាន-កម្ពុជា
## (Cambodia-ASEAN Business Summit)




*សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា*

នាព្រឹកថ្ងៃអង្គារ ទី២ ខែមេសា ឆ្នាំ២០២៤ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានអញ្ជើញចូលរួមជាវាគ្មិនក្នុងកិច្ចពិភាក្សាក្រោមប្រធានបទ កម្ពុជាជាច្រកទ្វារទៅកាន់អាស៊ាន "Cambodia - Gateway to ASEAN" នៃកិច្ចប្រជុំកំពូលធុរកិច្ចអាស៊ាន-កម្ពុជា ឆ្នាំ២០២៤ក្រោមមូលបទ បញ្ចេញសក្តានុពលអាស៊ាន៖ បច្ចេកវិទ្យា ចីរភាព និងកំណើនប្រកបដោយបរិយាបន្ន ( Unleashing ASEAN's Potential: Technology, Sustainability, and Inclusive Growth ) ដែលមានការចូលរួមពីថ្នាក់ដឹកនាំក្រសួង-ស្ថាប័នរដ្ឋ វិស័យឯកជនពាក់ព័ន្ធ និងក្រុមហ៊ុនអន្តរជាតិធំៗនៅកម្ពុជានិងអាស៊ាន នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញ ភូគីត្រា៕






CAMBODIA-ASEAN
Business Summit 2024
Unleashing ASEAN's Potential:
Connectivity, Technology, and Inclusive Growth
CAMBODIA CHAMBER OF COMMERCE
ASEAN BUSINESS ADVISORY COUNCIL CAMBODIA


Cambodia - Gateway to ASEAN
Moderator
MR. ARNAUD DARC
Panelist
H.E. DR. KUN NHIM
Panelist
H.E. SUN CHANTHOL
Deputy Prime Minister and First Vice-Chairman of Council for the Development of Cambodia
Panelist
H.E. KONG VIBOL
Panelist
H.E. SOU SOCHEAT
Director General of Security and Exchange Regulator of Cambodia


CAMBODIA-ASEAN
Business Summit 2024

# ការចុះត្រួតពិនិត្យវឌ្ឍនភាព
# គម្រោងសាងសង់អគារអគ្គនាយកដ្ឋានពន្ធដារថ្មី



នារសៀលថ្ងៃអង្គារ ទី២១ ខែឧសភា ឆ្នាំ២០២៤ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងការចុះពិនិត្យវឌ្ឍនភាព គម្រោងសាងសង់អគារអគ្គនាយកដ្ឋានពន្ធដារថ្មី ដែលមានទីតាំងស្ថិតនៅសង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញអមដំណើរដោយឯកឧត្តមបណ្ឌិតសភាចារ្យ **ជូ វិជិត្ត** រដ្ឋលេខាធិការប្រចាំការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានពន្ធដារ និងមន្ត្រីពាក់ព័ន្ធផ្សេងៗទៀត៕

















# កិច្ចប្រជុំពិភាក្សាស្តីពីបញ្ហាប្រឈមនិងដំណោះស្រាយ ចំពោះការចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន (CamDX)



នារសៀលថ្ងៃព្រហស្បតិ៍ ទី២៥ ខែមេសា ឆ្នាំ២០២៤ នៅទីស្តីការក្រសួងពាណិជ្ជកម្ម ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពិភាក្សាស្តីពីបញ្ហាប្រឈមនិងដំណោះស្រាយ ចំពោះការចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន (CamDX)៕



*លោកជំទាវ **ចម និម្មល***
*រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម*



*ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ*



# កិច្ចប្រជុំពិនិត្យលើវឌ្ឍនភាពការងារ នៃអង្គវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៩



នាព្រឹកថ្ងៃចន្ទ ទី២០ ខែឧសភា ឆ្នាំ២០២៤ នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពិនិត្យលើវឌ្ឍនភាពការងារនៃអង្គវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៩។



ឯកឧត្តម ***ស៊ុន ចាន់ថុល***
*ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*



ឯកឧត្តម ***គង់ វិបុល*** *រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជា*
*ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ*





ឯកឧត្តម ***ជា វុទ្ធី*** *អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*



ឯកឧត្តម ***ឌិត ទីណា***
*រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*









# ជំនួបពិភាក្សាការងាររវាងឯកឧត្តម គង់ វិបុល និងឯកអគ្គរដ្ឋទូតបារាំង អាល្លឺម៉ង់ និងសហភាពអឺរ៉ុបប្រចាំនៅព្រះរាជាណាចក្រកម្ពុជា



នាព្រឹកថ្ងៃសុក្រ ទី៥ ខែមេសា ឆ្នាំ២០២៤ នៅអគ្គនាយកដ្ឋានពន្ធដារ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានទទួលជួបពិភាក្សាការងារជាមួយឯកឧត្តម Jacques PELLET ឯកអគ្គរដ្ឋទូតសាធារណរដ្ឋបារាំងប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ឯកឧត្តម Stefan Messerer ឯកអគ្គរដ្ឋទូតនៃសហព័ន្ធអាល្លឺម៉ង់ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម Igor Driesmans ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដោយមានការចូលរួមពីឯកឧត្តម **សុខ ពិសិដ្ឋ** អនុប្រធានក្រុមការងារចំពោះកិច្ចទទួលបន្ទុកសិក្សា និងផ្តល់យោបល់លើស្ថានភាពពន្ធនិងអាករ និងបរិយាកាសវិនិយោគក្នុងព្រះរាជាណាចក្រកម្ពុជា។

ជំនួបពិភាក្សាការងារនេះត្រូវបានរៀបចំឡើងក្នុងគោលដៅពង្រឹងបន្ថែមកិច្ចសហប្រតិបត្តិការអន្តរជាតិរវាងកម្ពុជា និងសហភាពអឺរ៉ុប ដើម្បីធ្វើឱ្យបរិយាកាសវិនិយោគនៅព្រះរាជាណាចក្រកម្ពុជាកាន់តែប្រសើរឡើងថែមទៀត តាមរយៈ ការបន្តពង្រឹងនិងសម្រួលកិច្ចការធុរកិច្ច (Ease of Doing Business) និងបង្កើនការទាក់ទាញវិនិយោគិនសហភាពអឺរ៉ុបមកវិនិយោគនៅព្រះរាជាណាចក្រកម្ពុជា ស្របតាមលទ្ធផលដ៏ត្រចះត្រចង់នៃដំណើរទស្សនកិច្ចរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ទៅកាន់សហភាពអឺរ៉ុបកាលពីថ្ងៃទី១៣ ដល់ថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៤។



ឯកឧត្តម **Stefan Messerer** ឯកអគ្គរដ្ឋទូតនៃសហព័ន្ធអាល្លឺម៉ង់ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា



ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ



ឯកឧត្តម **Igor Driesmans** ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំនៅព្រះរាជាណាចក្រកម្ពុជា



ឯកឧត្តម **Jacques PELLET** ឯកអគ្គរដ្ឋទូតសាធារណរដ្ឋបារាំងប្រចាំនៅព្រះរាជាណាចក្រកម្ពុជា



ឯកឧត្តម **សុខ ពិសិដ្ឋ**



លោក **Davide BERTON**
















អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

# សិក្ខាសាលាផ្សព្វផ្សាយផ្ទៃក្នុងស្តីពី សៀវភៅណែនាំស្តីពីបែបបទនិងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារសម្រាប់មន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ និងសៀវភៅណែនាំស្តីពីការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ




នាព្រឹកថ្ងៃអង្គារ ទី៧ ខែឧសភា ឆ្នាំ២០២៤ នៅសាលាជាតិពន្ធដារ មានរៀបចំសិក្ខាសាលាផ្សព្វផ្សាយផ្ទៃក្នុងស្តីពី "សៀវភៅណែនាំស្តីពីបែបបទនិងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារសម្រាប់មន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ និងសៀវភៅណែនាំស្តីពីការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានការចូលរួមពីថ្នាក់ដឹកនាំអគ្គនាយកដ្ឋានពន្ធដារ តំណាងនាយកដ្ឋានថ្នាក់កណ្តាល សាខាពន្ធដារខេត្ត-ខណ្ឌ និងមន្ត្រីរាជការពន្ធដារពាក់ព័ន្ធចូលរួមដោយផ្ទាល់ និងតាមអនឡាញ។

ថ្លែងក្នុងចំណាប់អារម្មណ៍និងសុន្ទរកថាបើកសិក្ខាសាលា ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូ បានលើកឡើងថា ស្របតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងអនុលោមតាមយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ដែលផ្តោតលើការកែទម្រង់និងការពង្រឹងអភិបាលកិច្ចល្អជាស្នូល អគ្គនាយកដ្ឋានពន្ធដារបានរៀបចំសៀវភៅណែនាំស្តីពីបែបបទ និងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារសម្រាប់មន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ និងសៀវភៅណែនាំស្តីពីការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ក្នុងគោលដៅចូលរួមធានាឱ្យបាននូវតម្លាភាព សមធម៌ គណនេយ្យភាព និងភាពប្រាកដប្រជា ក្នុងការងារសវនកម្ម និងការងារស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ព្រមទាំងជានិយាមនីតិវិធីប្រតិបត្តិការងារ (Standard Operating Procedure - SOP) សម្រាប់អនុវត្តមុខងារនិងភារកិច្ចរបស់មន្ត្រីពន្ធដារ ដើម្បីផ្សព្វផ្សាយជូនអ្នកជាប់ពន្ធនិងសាធារណជនឱ្យបានយល់ដឹងអំពីបែបបទនិងនីតិវិធីនៃការអនុវត្ត និងជាឯកសារដែលកំណត់ច្បាស់អំពីក្រមសីលធម៌ វិន័យ និងវិជ្ជាជីវៈក្នុងពេលបំពេញការងារទាំងនោះ។ ការរៀបចំចងក្រងសៀវភៅណែនាំទាំងពីរនេះ ក៏ជាការកែទម្រង់រដ្ឋបាលសារពើពន្ធ ដើម្បីសម្រួលបរិយាកាសធុរកិច្ចនិងការវិនិយោគ ដោយចៀសវាងការធ្វើសវនកម្មត្រួតគ្នាច្រើនលើកច្រើនសា និងបង្កើតស្តង់ដាររួមឱ្យបានច្បាស់លាស់ ប្រកបដោយតម្លាភាពសម្រាប់ការអនុវត្តរវាងមន្ត្រីពន្ធដារ និងអ្នកជាប់ពន្ធ។

ក្នុងកម្មវិធីសិក្ខាសាលានេះ មានការធ្វើបទបង្ហាញលើប្រធានបទសំខាន់ចំនួន២ គឺប្រធានបទទី១ ស្តីពី "សៀវភៅណែនាំស្តីពីបែបបទនិងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារសម្រាប់មន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ" ដោយ លោក **ជួរ សៃ** អនុប្រធាននាយកដ្ឋានសវនកម្មសហគ្រាស និងប្រធានបទទី២ ស្តីពី "សៀវភៅណែនាំស្តីពីការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ" ដោយលោក **ស្រ៊ុន អឧត្តរ៉េន** ប្រធាននាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ ដោយពន្យល់ និងបកស្រាយយ៉ាងក្បោះក្បាយ ព្រមទាំងមានការចូលរួមលើកជាសំណួរយ៉ាងផុលផុសពីសិក្ខាកាមដែលចូលរួម៕









# កិច្ចប្រជុំពិភាក្សាកម្រិតបច្ចេកទេស លើកទី៣ របស់អនុក្រុមការងារ សមាគមពាណិជ្ជកម្មកម្ពុជា-ជប៉ុន និងអគ្គនាយកដ្ឋានពន្ធដារ



នារសៀលថ្ងៃពុធ ទី៣ ខែមេសា ឆ្នាំ២០២៤ នៅអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំកិច្ចប្រជុំពិភាក្សាកម្រិតបច្ចេកទេស លើកទី៣ របស់អនុក្រុមការងារសមាគមពាណិជ្ជកម្មកម្ពុជា-ជប៉ុន និងអគ្គនាយកដ្ឋានពន្ធដារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ និងលោក **FUKUHARA Koji** ប្រធានសមាគមពាណិជ្ជកម្មកម្ពុជា-ជប៉ុន (JABC) ព្រមទាំងមានការចូលរួមពីថ្នាក់ដឹកនាំនិងមន្ត្រីជំនាញនៃអគ្គនាយកដ្ឋានពន្ធដារ និងសមាជិក JBAC។

កិច្ចប្រជុំនេះត្រូវបានរៀបចំឡើងដើម្បីពិភាក្សា និងដោះស្រាយនូវបញ្ហាប្រឈមមួយចំនួនដែលសមាជិក JBAC បាន និងកំពុងជួបប្រទះក្នុងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារដែលមានរបៀបវារៈចំនួនពីរ៖ គឺ១.ការកំណត់ប្រាក់បៀវត្សរបស់អភិបាលជាអនិវាសនជន និង២.ការផ្ទេរអាជីវកម្ម ឬការផ្ទេរភាគហ៊ុន។ អគ្គនាយកដ្ឋានពន្ធដារបានយកចិត្តទុកដាក់ស្តាប់នូវការលើកឡើងអំពីបញ្ហាប្រឈមនីមួយៗពី JBAC លើរបៀបវារៈទាំងពីរ និងមានលទ្ធផលលម្អិតដូចខាងក្រោម៖

១. ការកំណត់ប្រាក់បៀវត្សរបស់អភិបាលជាអនិវាសនជន៖ អគ្គនាយកដ្ឋានពន្ធដារស្នើ JBAC សុំការបញ្ជាក់ការអនុវត្តពន្ធពីអាជ្ញាធរពន្ធដារ (National Tax Agent) នៅប្រទេសជប៉ុនលើក្រុមប្រឹក្សាភិបាលជាអនិវាសនជនដែលមានលក្ខខណ្ឌដូចនឹងលក្ខខណ្ឌដែល JBAC កំពុងជួបប្រទះនៅកម្ពុជា ហើយអគ្គនាយកដ្ឋានពន្ធដារនឹងសិក្សាលទ្ធភាពអនុវត្តន៍ការយកពន្ធដូចគ្នានឹងប្រទេសជប៉ុន។ ជាមួយគ្នានេះ អគ្គនាយកដ្ឋានពន្ធដារពិនិត្យឃើញថា បញ្ហាប្រឈមគឺមិនមែនបណ្តាលមកពីបទប្បញ្ញត្តិពាក់ព័ន្ធនឹងពន្ធដារនោះទេ ប៉ុន្តែជាបញ្ហាដែលកើតចេញពីការធ្វើសវនកម្ម។ ដូច្នេះដើម្បីដោះស្រាយបញ្ហាប្រឈមគឺមិនតម្រូវឱ្យមានការកែសម្រួលបទប្បញ្ញត្តិពាក់ព័ន្ធនឹងពន្ធដារទេ។ ក្នុងន័យនេះ អគ្គនាយកដ្ឋានពន្ធដារបានស្នើ JBAC ប្រមូលយកបញ្ហាប្រឈមជាក់ស្តែងដែលកើតឡើងក្នុងការធ្វើសវនកម្មមកអគ្គនាយកដ្ឋានពន្ធដារដើម្បីពិនិត្យលម្អិត និងដោះស្រាយជូន។

២. ការផ្ទេរអាជីវកម្ម ឬការផ្ទេរភាគហ៊ុន៖ អគ្គនាយកដ្ឋានពន្ធដារបានបញ្ជាក់ថា មុនធ្វើការផ្ទេរអាជីវកម្ម ឬផ្ទេរភាគហ៊ុនម្ចាស់កម្មសិទ្ធិ ឬម្ចាស់ភាគហ៊ុនថ្មី ត្រូវស្នើសុំឱ្យមានការបញ្ជាក់ពីស្ថានភាពបំណុលពន្ធមកអគ្គនាយក-ដ្ឋានពន្ធដារ (Due Diligence) ដូច្នេះម្ចាស់កម្មសិទ្ធិ ឬម្ចាស់ភាគហ៊ុនចាស់ត្រូវស្នើសុំជម្រះបញ្ជីសារពើពន្ធមកអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងត្រូវជម្រះបំណុលពន្ធទាំងអស់ដែលកើតមានឡើងមុនប្រតិបត្តិការផ្ទេរអាជីវកម្ម ឬផ្ទេរភាគហ៊ុនឱ្យបានចប់សព្វគ្រប់។ ស្របជាមួយគ្នានេះដែរ អគ្គនាយកដ្ឋានពន្ធដារ បានឯកភាពតាមការស្នើសុំរបស់ JBAC រៀបចំសេចក្តីណែនាំបន្ថែមលើការផ្ទេរអាជីវកម្ម ឬការផ្ទេរភាគហ៊ុន ដែលនឹងត្រូវផ្តល់ធាតុចូលបន្ថែមពីវិស័យឯកជនដើម្បីឱ្យសេចក្តីណែនាំនេះមានលក្ខណៈគ្រប់ជ្រុងជ្រោយដែលអាចដោះស្រាយបញ្ហាប្រឈមនេះបាន៕



*លោក **FUKUHARA Koji***
*ប្រធានសមាគមពាណិជ្ជកម្មកម្ពុជា-ជប៉ុន*



*ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ*







# ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នូវអគារសាខាពន្ធដារខេត្តកំពង់ធំ



*ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ ជាផ្លូវការនូវអគារសាខាពន្ធដារខេត្តកំពង់ធំ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ*

នាព្រឹកថ្ងៃអង្គារ ទី២៣ ខែមេសា ឆ្នាំ២០២៤ នៅសាខាពន្ធដារខេត្តកំពង់ធំ មានរៀបចំពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវអគារសាខាពន្ធដារខេត្តកំពង់ធំ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងមានការចូលរួមពីឯកឧត្តម **ខួន រតនៈ** អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានពន្ធដារ សមាជិកក្រុមប្រឹក្សាខេត្តកំពង់ធំ និងតំណាងអង្គភាពជំនាញជុំវិញរដ្ឋបាលខេត្តកំពង់ធំ។

ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** អគាររដ្ឋបាលថ្មីនៃសាខាពន្ធដារខេត្តកំពង់ធំត្រូវបានសាងសង់នៅលើទីតាំងចាស់ស្ថិតនៅភូមិបល្ល័ង្គខាងលិច សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ មានផ្ទៃក្រឡាសាងសង់សរុបចំនួន ២៨០២,៣៦ ម៉ែត្រការ៉េ កម្ពស់ ២៨ ម៉ែត្រ ស្មើនឹង ៥ជាន់ ដោយគិតរួមទាំងចំណតរថយន្តនៅជាន់ផ្ទាល់ដី ហើយជាន់នីមួយៗមានទំហំ ៤៨១ ម៉ែត្រការ៉េ ស្មើៗគ្នា ក្នុងនោះ៖

- ជាន់ផ្ទាល់ដី ជាចំណតយានយន្តក្រោមអគារដែលមានចំនួន ១៣ ចំណត និងខាងក្រោយអគារជាចំណតធំទូលាយសម្រាប់យានជំនិះផ្សេងៗទៀត
- ជាន់ទី១ ត្រូវបានរៀបចំដោយមានបញ្ជរផ្តល់សេវាអ្នកជាប់ពន្ធចំនួន ១០ និងបន្ទប់ផ្តល់សេវាចំនួន ១ ព្រមទាំងមានកន្លែងរង់ចាំដែលអាចទទួលអ្នកជាប់ពន្ធបានចំនួន ៤០ នាក់ និងមានបន្ទប់ការិយាល័យធ្វើការចំនួន ១ ដែលអាចឱ្យមន្ត្រីបំពេញការងារបានប្រមាណ ២០ នាក់
- ជាន់ទី២ ត្រូវបានរៀបចំដោយមានបន្ទប់ការិយាល័យធ្វើការចំនួន ៣ ដែលអាចឱ្យមន្ត្រីបំពេញការងារបាន

ប្រមាណ ២៥ នាក់ មានបន្ទប់ការិយាល័យសម្រាប់ប្រធានសាខាចំនួន ១ បន្ទប់ Server ចំនួន ១ និងបន្ទប់សាលប្រជុំ VIP ចំនួន ១

- ជាន់ទី៣ ត្រូវបានរៀបចំដោយមានបន្ទប់ការិយាល័យធ្វើការចំនួន ៤ ដែលអាចឱ្យមន្ត្រីបំពេញការងារបានប្រមាណ ២៤ នាក់ បន្ទប់ការិយាល័យសម្រាប់អនុប្រធានសាខាចំនួន ៣ និងបន្ទប់ឃ្លាំងឯកសារចំនួន ១
- ជាន់ទី៤ ត្រូវបានរៀបចំដោយមានសាលប្រជុំធំចំនួន ១ ដែលអាចផ្ទុកមនុស្សបានប្រមាណជា ១២០ នាក់ បន្ទប់រង់ចាំ (VIP Waiting Room) ចំនួន ១ និងបន្ទប់ទទួលទានអាហារសម្រន់ (Refreshment Room) ចំនួន ១ សម្រាប់ប្រើប្រាស់ក្នុងការផ្តល់សេវាអ្នកជាប់ពន្ធ ជាពិសេសសម្រាប់ការផ្សព្វផ្សាយ ការបណ្តុះបណ្តាល និងកិច្ចប្រជុំនានា។

ក្នុងពិធីនេះ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូ បានលើកឡើងថា អគាររដ្ឋបាលថ្មីនៃសាខាពន្ធដារខេត្តកំពង់ធំនេះ ត្រូវបានសាងសង់ឡើង ក្នុងគោលបំណងពង្រឹង និងពង្រីកការផ្តល់សេវាជូនអ្នកជាប់ពន្ធឱ្យកាន់តែទូលំទូលាយនិងមានប្រសិទ្ធភាពខ្ពស់ ដោយសាងសង់ឡើងស្របតាមរចនាបទ ក៏ដូចជាស្តង់ដាបច្ចេកទេសដូចគ្នាទៅនឹងអគារសាខាពន្ធដារដែលបានសាងសង់នៅខេត្តកែប និងមណ្ឌលគិរី គឺជាការរក្សានូវឯកសណ្ឋានភាពនៃរចនាបថតែមួយសម្រាប់អគារសាខាពន្ធដារខេត្ត-ខណ្ឌ។ ជាមួយគ្នានេះ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូ បានក្រើនរំលឹកដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការពន្ធដារនៃសាខាពន្ធដារខេត្តកំពង់ធំទាំងអស់ ត្រូវបន្តខិតខំ និងយកចិត្តទុកដាក់សហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរពាក់ព័ន្ធ ព្រមទាំងពង្រឹងគុណភាពនៃការផ្តល់សេវា ដោយប្រើប្រាស់នូវហេដ្ឋារចនាសម្ព័ន្ធនិងឧបករណ៍បរិក្ខារទំនើប ដែលបានរៀបចំជាមួយនឹងអគារសាខាពន្ធដារថ្មីប្រកបដោយសក្តានុពល សំដៅធ្វើយ៉ាងណាឱ្យការផ្តល់សេវាជូនអ្នកជាប់ពន្ធមានគុណភាពខ្ពស់ និងប្រកបដោយវិជ្ជាជីវៈ៕
























អបអរសាទរ
ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគារសាខាពន្ធដារខេត្តកំពង់ធំ
ថ្ងៃអង្គារ ១៥កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧






សាខាពន្ធដារខេត្តកំពង់ធំ







# ផ្នែកទី១
# ស្ថានភាពនៃការគ្រប់គ្រងការប្រមូលចំណូលពន្ធ

១. លទ្ធផលការងារប្រមូលចំណូលពន្ធ
២. ស្ថានភាពចំណូលពន្ធតាមប្រភេទអ្នកជាប់ពន្ធ
៣. ស្ថានភាពចំណូលពន្ធតាមប្រភេទពន្ធសំខាន់ៗ
៤. ស្ថានភាពចំណូលពន្ធតាមសកម្មភាពអាជីវកម្មសំខាន់ៗ

# ๒

## ១. លទ្ធផលការងារប្រមូលចំណូលពន្ធ

សរុបរយៈពេល ៦ខែដើមឆ្នាំ២០២៤ ចំណូលពន្ធអាករ ដែលប្រមូលបានជាក់ស្តែងតាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ មានចំនួន **៧ ៧៦៧,៧៣ ប៊ីលានរៀល** (ប្រមាណជា **១ ៩១៧,៩៦ លានដុល្លារ**) ស្មើនឹង **៤៦,០៦%** នៃផែនការដែលបានកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤។

**ចំណូលពន្ធអាករគ្រប់ប្រភេទ រយៈពេល ៦ខែដើមឆ្នាំ២០២៤**




## ២. ស្ថានភាពចំណូលពន្ធតាមប្រភេទអ្នកជាប់ពន្ធ

**ចំណូលពន្ធអាករតាមប្រភេទអ្នកជាប់ពន្ធ រយៈពេល ៦ខែដើមឆ្នាំ២០២៤**



សរុបរយៈពេល ៦ខែដើមឆ្នាំ២០២៤ ចំណូលពន្ធអាករតាមប្រភេទអ្នកជាប់ពន្ធ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបានក្នុងនោះរួមមាន៖

- ចំណូលពន្ធអាករពីអ្នកជាប់ពន្ធធំ ចំនួន **៦ ០៥៦,៧៤ ប៊ីលានរៀល ស្មើនឹង ៧៧,៩៧%** ធៀបនឹងចំណូលពន្ធអាករសរុប
- ចំណូលពន្ធអាករពីអ្នកជាប់ពន្ធមធ្យម ចំនួន **១ ២៥៧,៥០ ប៊ីលានរៀល ស្មើនឹង ១៦,១៩%** ធៀបនឹងចំណូលពន្ធអាករសរុប
- ចំណូលពន្ធអាករពីអ្នកជាប់ពន្ធតូច ចំនួន **៥២,៣២ ប៊ីលានរៀល ស្មើនឹង ០,៦៧%** ធៀបនឹងចំណូលពន្ធអាករសរុប
- ចំណូលពន្ធអាករពីប្រភេទពន្ធផ្សេងៗ (ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ ពន្ធលើអចលនទ្រព្យ និងពន្ធផ្សេងៗ) ចំនួន **៤០១,១៧ ប៊ីលានរៀល ស្មើនឹង ៥,១៦%** ធៀបនឹងចំណូលពន្ធអាករសរុប។

## ៣. ស្ថានភាពចំណូលពន្ធតាមប្រភេទពន្ធសំខាន់ៗ

**ចំណូលពន្ធអាករតាមប្រភេទពន្ធសំខាន់ៗ រយៈពេល ៦ខែដើមឆ្នាំ២០២៤**




សរុបរយៈពេល ៦ខែដើមឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារប្រមូលចំណូលតាមប្រភេទពន្ធសំខាន់ៗរួមមាន៖

- ពន្ធលើប្រាក់ចំណូលចំនួន **២ ៧២០,៣០ ប៊ីលានរៀល**
- អាករលើតម្លៃបន្ថែមចំនួន **១ ៧៤៤,០២ ប៊ីលានរៀល**
- អាករពិសេសចំនួន **៥៤០,៩២ ប៊ីលានរៀល**
- ពន្ធលើប្រាក់បៀវត្សចំនួន **៧៥៣,៩១ ប៊ីលានរៀល**
- ពន្ធប្រថាប់ត្រាសរុប (ផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យ) ចំនួន **៣២៩,៣២ ប៊ីលានរៀល**
- ពន្ធកាត់ទុកទូទៅចំនួន **១ ៣៧៩,៦៣ ប៊ីលានរៀល**។

# ៤. ស្ថានភាពចំណូលពន្ធតាមសកម្មភាពអាជីវកម្មសំខាន់ៗ

ក្នុងរយៈពេល ៦ខែដើមឆ្នាំ២០២៤ ចំណូលពន្ធពីសកម្មភាពសេវាហិរញ្ញវត្ថុនិងធានារ៉ាប់រង អាហារ័ណ-នីហារ័ណ និងសកម្មភាពកម្មន្តសាល គឺជាចំណូលពន្ធចម្បង និងលេចធ្លោជាងគេ។ ជាក់ស្តែង ចំណូលពន្ធអាករពីសកម្មភាពសេវាហិរញ្ញវត្ថុនិងធានារ៉ាប់រងមានចំនួន **១ ៧៨៤,២១ ប៊ីលានរៀល** ចំណូលពន្ធអាករពីសកម្មភាពអាហារ័ណ-នីហារ័ណមានចំនួន **១ ១៤៩,៨៧ ប៊ីលានរៀល** និងចំណូលពន្ធពីសកម្មភាពកម្មន្តសាលមានចំនួន **១ ៧៥៩,០៣ ប៊ីលានរៀល**។ ទន្ទឹមនឹងនេះ ចំណូលពន្ធអាករដែលកើនឡើងគួរឱ្យកត់សម្គាល់សម្រាប់រយៈពេល ៦ខែដើមឆ្នាំ២០២៤ គឺចំណូលពន្ធអាករបានមកពីសកម្មភាពកម្មន្តសាល ដែលមានចំនួន **១ ៧៥៩,០៣ ប៊ីលានរៀល** បើធៀបនឹងរយៈពេលនិងសកម្មភាពដូចគ្នានៃឆ្នាំ២០២៣ កើនឡើងចំនួន **១១៦,០៦ ប៊ីលានរៀល ស្មើនឹង ៧,០៦%**។ តារាងចំណូលពន្ធអាករតាមសកម្មភាពអាជីវកម្មសំខាន់ៗដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបាន ជាក់ស្តែង ក្នុងរយៈពេល ៦ខែដើមឆ្នាំ២០២៤ មានបង្ហាញដូចខាងក្រោម៖

**តារាងចំណូលពន្ធអាករតាមសកម្មភាពអាជីវកម្មសំខាន់ៗ រយៈពេល៦ខែដើមឆ្នាំ២០២៤**

(តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញ Online របស់អគ្គនាយកដ្ឋានពន្ធដារ)

| បរិយាយ | រយៈពេល៣ខែ | ខែមេសា | ខែឧសភា | ខែមិថុនា | សរុបរួម |
|---|---|---|---|---|---|
| អាហារ័ណ-នីហារ័ណ(រួមបញ្ចូលការលក់ផលិតផលគេលសិលា) | ៦៨០,៩១ | ១៥៧,៨៣ | ១៤៧,៨៥ | ១៦២,០៨ | ១ ១៤៩,៨៧ |
| សេវាហិរញ្ញវត្ថុ និងធានារ៉ាប់រង | ១ ២៦៣,៧៣ | ១៨២,៣៩ | ១៧៣,៩៨ | ១៦៤,០១ | ១ ៧៨៤,២១ |
| កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៤២,៥៣ | ១២,៦៣ | ៧,២៧ | ៩,៥៦ | ៧២,០០ |
| ប្រតិបត្តិការ និងអាជីវកម្មធនធានរ៉ែ | ១១២,៤៨ | ៦,៥៣ | ៧,២០ | ៧,៧៥ | ១៣៣,៩៦ |
| កម្មន្តសាល | ៩៩៩,៣៤ | ២៦៤,០៣ | ២៤៧,៨៤ | ២៤៦,២៨ | ១ ៧៥៩,០៣ |
| សកម្មភាពអចលនវត្ថុ | ២១៤,៧២ | ៤៦,៣១ | ៤៧,១០ | ៦៧,០៥ | ៣៧៥,៣៣ |
| ការដឹកជញ្ជូន និងការស្តុកទុក | ២២៥,៩៣ | ៥០,៤៥ | ៥៧,៩២ | ៦២,៤៦ | ៣៩៦,៨៧ |
| ព័ត៌មានវិទ្យា និងទូរគមនាគមន៍ | ៣២៣,៩៩ | ៥៨,៤៧ | ៥៨,៦៨ | ៥៤,៥៧ | ៤៩៥,៨៤ |
| ការអប់រំ | ២៨,៦២ | ៧,១៤ | ៧,៣៤ | ៧,៩៣ | ៥១,១១ |
| សេវាកម្មស្នាក់នៅ និងអាហារ | ១០៧,៣៤ | ៣១,៤៥ | ២៧,៦៤ | ២៥,៧១ | ១៩២,២១ |
| ការសាងសង់ | ២១៤,៩៦ | ៤៣,០៤ | ៥៤,៣៣ | ៥០,៥៧ | ៣៦៣,២១ |

* សម្គាល់ ៖ ចំណូលឯកតាគិតជាប៊ីលានរៀល។

# ផ្នែកទី២
# វឌ្ឍនភាពការងារនៃមុខងារប្រតិបត្តិការស្នូល និងមុខងារគាំទ្រ

១. ការចុះបញ្ជីពន្ធដារ
២. ការផ្តល់សេវាអ្នកជាប់ពន្ធ
៣. ការចាត់ចែងលិខិតប្រកាសពន្ធ
៤. ការធ្វើសវនកម្មពន្ធដារ
៥. ការប្រមូលបំណុលពន្ធ និងបណ្តឹងតវ៉ា
៦. បច្ចេកវិទ្យាព័ត៌មាន

# ១.ការចុះបញ្ជីពន្ធដារ

ក្នុងរយៈពេល ៦ខែដើមឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានអនុញ្ញាតឱ្យចុះបញ្ជីសរុបចំនួន **៦ ២៦៣ សហគ្រាស** (ពន្ធធំ ៣២៧ ពន្ធមធ្យម ២ ៩៨០ និងពន្ធតូច ២ ៩៥៦) ក្នុងនោះតាមថ្នាលប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានចំនួន **៥ ៨៧១** សហគ្រាស (ពន្ធធំ ៣០៤ ពន្ធមធ្យម ២ ៧៩៧ និងពន្ធតូច ២ ៧៧០) ។ ដោយឡែក គិតត្រឹមខែមិថុនា ឆ្នាំ២០២៤ ចំពោះប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មានអ្នកជាប់ពន្ធដែលបានមកចុះបញ្ជីសរុបចំនួន **៦ សហគ្រាស** (គិតចាប់ពីឆ្នាំ២០២២ ដល់ខែមិថុនា ឆ្នាំ២០២៤ សរុបចំនួន **៩០ សហគ្រាស**)៕

# ២.ការផ្តល់សេវាអ្នកជាប់ពន្ធ

## មជ្ឈមណ្ឌលពិគ្រោះយោបល់

ក្នុងរយៈពេល ៦ខែដើមឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានផ្តល់សេវាអ្នកជាប់ពន្ធសរុបចំនួន **៥១ ៩៥០ ករណី** បើធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២៣ ឃើញថាថយចុះ **-៣ ០៤៦ ករណី** ស្មើនឹង **-៥,៥៤%** ក្នុងនោះមានការថយចុះករណីនៃការផ្តល់សេវាស្ទើរតែទាំងអស់ លើកលែងតែការផ្តល់សេវាតាមរយៈទូរស័ព្ទ (១២៧៧) មានការកើនឡើង **១ ១៤៨ ករណី** ស្មើនឹង **៣,៥២%**។ ការថយចុះនៃការសាកសួរសំណួរតាមរយៈការផ្តល់សេវាអ្នកជាប់ពន្ធគឺឆ្លុះបញ្ចាំងអំពីការយល់ដឹងរបស់អ្នកជាប់ពន្ធមានការកើនឡើង៕

**ការផ្តល់សេវាពិគ្រោះយោបល់ រយៈពេល ៦ខែដើមឆ្នាំ២០២៤ ធៀបនឹងរយៈពេលដូចគ្នា ក្នុងឆ្នាំ២០២៣**

| បរិយាយ | ឆ្នាំ២០២៣ | ឆ្នាំ២០២៤ | %កើន/ថយ |
|---|---|---|---|
| ទូរស័ព្ទ (១២៧៧) | ៣២ ៥៨៧ | ៣៣ ៧៣៥ | ៣,៥២% |
| GDT Live Chat | ១៦ ០៦២ | ១៥ ២៤៣ | -៥,១០% |
| បណ្តាញសង្គម Facebook | ៥ ០៨៧ | ២ ៣២៧ | -៥៤,២៦% |
| កម្មវិធី "ពន្ធដារកម្ពុជា" | ២៥ | ២២ | -១២,០០% |
| កម្មវិធី "រៀនអំពីពន្ធដារតាមអនឡាញ" | ២៤ | ១៦ | -៣៣,៣៣% |
| តេឡេក្រាម "ព័ត៌មានពន្ធដារកម្ពុជា" | ១ ២១១ | ៦០៧ | -៤៩,៨៨% |
| **សរុបរួម** | ៥៤ ៩៩៦ | ៥១ ៩៥០ | -៥,៥៤% |

## ការផ្តល់សេវាអ្នកជាប់ពន្ធចំពោះ "ការគាំទ្រប្រព័ន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ (e-Tax Service)"

ក្នុងរយៈពេល ៦ខែដើមឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានផ្តល់សេវាដោះស្រាយបញ្ហាប្រឈមនានា ក្នុងការប្រើប្រាស់ប្រព័ន្ធនិងកម្មវិធីតាមរយៈអនឡាញ (e-Tax Service) សរុបចំនួន **១៨ ៥៣៥ ដង** ដែលក្នុងនោះការស្នើសុំតាមរយៈ GDT Live Chat ចំនួន **៧ ០៨៦ ដង**, សារអេឡិចត្រូនិក (E-Mail) ចំនួន **៣២១ ករណី**, ទូរស័ព្ទ (១២៧៧) ចំនួន **៧ ៦៧០ ដង**, ហ្វេសប៊ុកចំនួន **២ ដង** និងក្រុមតេឡេក្រាម (Telegram) ចំនួន **៣ ៤៥៦ ដង**៕

# កម្មវិធីពន្ធដារកម្ពុជា

កម្មវិធីពន្ធដារកម្ពុជា គឺជាកម្មវិធីដែលអគ្គនាយកដ្ឋានពន្ធដារបានរៀបចំឡើងដើម្បីចែករំលែកចំណេះដឹង ព័ត៌មានទាក់ទងនឹងពន្ធដារ ជាពិសេសផ្តល់ឱកាសឱ្យសាធារណជនចូលរួមមតិយោបល់ ឬលើកឡើងនូវចម្ងល់នានាពាក់ព័ន្ធនឹងប្រធានបទនីមួយៗ ដែលធ្វើការផ្សាយផ្ទាល់តាមរយៈទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ រៀងរាល់ថ្ងៃព្រហស្បតិ៍ វេលាម៉ោង ១១:០០ ដល់ម៉ោង ១២:០០ថ្ងៃត្រង់។ កម្មវិធីនេះ ទទួលបានការគាំទ្រយ៉ាងខ្លាំងពីសំណាក់អ្នកជាប់ពន្ធ និងសាធារណជន ដែលទស្សនិកជនអាចផ្តល់មតិយោបល់ ឬសួរសំណួរតាមរយៈទូរស័ព្ទមកលេខ ១២៧៧ ដោយឥតគិតថ្លៃ ឬអាចចូលទៅផ្តល់មតិយោបល់ (Comment) នៅលើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារភ្លាមៗក្នុងពេលផ្សាយផ្ទាល់ នោះវាគ្មិននឹងធ្វើការឆ្លើយតបផ្ទាល់ក្នុងកម្មវិធីតែម្តង។ ក្នុងករណីខកខានមិនបានទស្សនាការផ្សាយផ្ទាល់ ទស្សនិកជនក៏អាចទស្សនាឡើងវិញ ព្រមទាំងអាចសួរសំណួរតាមរយៈ Comments ក្នុងវីដេអូនោះ ក្រុមការងារ GDT Call Center របស់អគ្គនាយកដ្ឋានពន្ធដារ នឹងធ្វើការឆ្លើយតបជូនតាមលំដាប់លំដោយ។ ក្រៅពីការចូលទៅទស្សនាឡើងវិញនៅលើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ ទស្សនិកជនក៏អាចចូលទៅទស្សនាក្នុងបណ្តាញយូធូប (YouTube) "General Department of Taxation, Cambodia" របស់អគ្គនាយកដ្ឋានពន្ធដារ ផងដែរ។

ក្នុងត្រីមាសទី២ ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារ បានរៀបចំកម្មវិធីពន្ធដារកម្ពុជាសរុបចំនួន ១៣ លើក ដោយផ្តោតលើប្រធានបទសំខាន់ៗរួមមាន ១.ពន្ធលើប្រាក់បៀវត្ស ២.អាករពិសេស អាករសម្រាប់បំភ្លឺសាធារណៈនិងកាតព្វកិច្ចបិទតែមប្រិ៍អាករសម្រាប់បារី ៣.ពន្ធលើអចលនទ្រព្យ ៤.ពន្ធប្រថាប់ត្រា ៥.ពន្ធប្រថាប់ត្រាលើការផ្ទេរភាគហ៊ុនកិច្ចសន្យាប្រើប្រាស់ថវិការដ្ឋ និងលិខិតមានលក្ខណៈគតិយុត្ត ៦.វិធានវិក្កយបត្រនិងការអនុវត្តអត្រាប្តូរប្រាក់ ៧.កិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា (DTA) និងការអនុវត្តកាតព្វកិច្ចរាយការណ៍របាយការណ៍ស្តីពី FATCA ៨.អាករលើតម្លៃបន្ថែម ៩.វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈពន្ធដារ ១០.អាករលើតម្លៃបន្ថែមចំពោះប្រតិបត្តិការពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិក ១១.នីតិវិធីនៃការដាក់លិខិតស្នើសុំនានា មកអគ្គនាយកដ្ឋានពន្ធដារ ១២.ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មតាមអនឡាញ (e-Filing) និង១៣.ពន្ធលើមធ្យោបាយដឹកជញ្ជូន៕



## កម្មវិធីពន្ធដារកម្ពុជាស្ដីពី “ពន្ធលើប្រាក់បៀវត្ស”




ស្កេន ដើម្បីចូលទៅទស្សនាវីដេអូដើម

កម្មវិធីនេះមានលោក **សុខ កុសល** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ និងលោក **ទូច ជាភាជ្ជ** ប្រធានការិយាល័យនៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការ របស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី២ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុកមានមតិយោបល់ (Comments) ចំនួន ៦២ អ្នកចូលទស្សនាចំនួន ៥២ ១០០ ដង និងមានការចែករំលែកបន្តចំនួន ៣៨១ ដង៕

## កម្មវិធីពន្ធដារកម្ពុជាស្ដីពី “អាករពិសេស អាករសម្រាប់បំភ្លឺសាធារណៈនិងកាតព្វកិច្ចបិទតែមប្រើអាករសម្រាប់បារី”




ស្កេន ដើម្បីចូលទៅទស្សនាវីដេអូដើម

កម្មវិធីនេះមានលោក **អេង រតនា** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ និងលោក **ម៉ឹង សុខឡៅ** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការ របស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី២ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុកមានមតិយោបល់ (Comments) ចំនួន ៣៦ អ្នកចូលទស្សនាចំនួន ១៥ ៥០០ ដង និងមានការចែករំលែកបន្តចំនួន ១២៣ ដង៕

## កម្មវិធីពន្ធដារកម្ពុជាស្ដីពី “ពន្ធលើអចលនទ្រព្យ”




ស្កេន ដើម្បីចូលទៅទស្សនាវីដេអូដើម

កម្មវិធីនេះមានលោក **សុវណ្ណ សម្បូរណ៍** ប្រធានការិយាល័យនៃនាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ និងលោក **ម៉ែន ពេជ្រដារ៉ូ** អនុប្រធានការិយាល័យនៃនាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការ របស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី២ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុកមានមតិយោបល់ (Comments) ចំនួន ៤០ អ្នកចូលទស្សនាចំនួន ៣៣ ២០០ ដង និងមានការចែករំលែកបន្តចំនួន ២៣៩ ដង៕

## កម្មវិធីពន្ធដារកម្ពុជាស្តីពី "ពន្ធប្រថាប់ត្រា"




ស្កេន ដើម្បីចូលទៅទស្សនាវីដេអូដើម

កម្មវិធីនេះមានលោក **ខែត លាភ** អនុប្រធាននាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ និងលោក **ជួប ចាន់ដារ៉ា** អនុប្រធានការិយាល័យនៃនាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការ របស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី២ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុកមាន មតិ យោបល់ (Comments) ចំនួន ៣១ អ្នកចូលទស្សនាចំនួន ២០ ៤០០ ដង និងមានការចែករំលែកបន្តចំនួន ១៧៧ ដង។

## កម្មវិធីពន្ធដារកម្ពុជាស្តីពី "ពន្ធប្រថាប់ត្រាលើការផ្ទេរភាគហ៊ុន កិច្ចសន្យាប្រើប្រាស់ធនធានរដ្ឋ និងលិខិតមានលក្ខណៈគតិយុត្ត"




ស្កេន ដើម្បីចូលទៅទស្សនាវីដេអូដើម

កម្មវិធីនេះមានលោក **ស៊ាង សុធារ៉ា** ប្រធានការិយាល័យនៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ និងលោក **ប៉ុម ចន្ថា** អនុប្រធានការិយាល័យនៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការ របស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី២ ឆ្នាំ២០២៤ តាមស្ថិតិ នៅលើទំព័រហ្វេសប៊ុកមានមតិយោបល់ (Comments) ចំនួន ៣៩ អ្នកចូលទស្សនាចំនួន ៣៩ ៥០០ ដង និងមានការចែករំលែកបន្តចំនួន ២៤៨ ដង។

## កម្មវិធីពន្ធដារកម្ពុជាស្តីពី "វិធានវិក្កយបត្រនិងការអនុវត្តអត្រាប្តូរប្រាក់"




ស្កេន ដើម្បីចូលទៅទស្សនាវីដេអូដើម

កម្មវិធីនេះមានលោក **ឆាយ ដារ៉ាហេង** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ និងលោក **ម៉ា ប៊ូរ៉ា** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការ របស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី២ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុកមានមតិយោបល់ (Comments) ចំនួន ៣២ អ្នកចូលទស្សនាចំនួន ២៥ ៦០០ ដង និងមានការចែករំលែកបន្តចំនួន ១៧២ ដង។

## កម្មវិធីពន្ធដារកម្ពុជាស្ដីពី “កិច្ចព្រមព្រៀងស្ដីពីការចៀសវាងការយកពន្ធត្រួតគ្នា (DTA) និងការអនុវត្តភាតព្វកិច្ចរាយការណ៍របាយការណ៍ស្ដីពី FATCA”



ស្កេន ដើម្បីចូលទៅទស្សនាវីដេអូដើម

កម្មវិធីនេះមានលោក **ស៊ឹម សុលីន** អនុប្រធាននាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធនិងសហប្រតិបត្តិការពន្ធដារអន្តរជាតិ និងលោក **ហុង សេរីវុឌ្ឍ** ប្រធានការិយាល័យនៃនាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធនិងសហប្រតិបត្តិការពន្ធដារអន្តរជាតិ ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការ របស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤ ដោយទទួល បានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី២ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុកមានមតិយោបល់ (Comments) ចំនួន ១៨ អ្នកចូលទស្សនាចំនួន ១៦ ៩០០ ដង និងមានការចែករំលែកបន្តចំនួន ៩៨ ដង។

## កម្មវិធីពន្ធដារកម្ពុជាស្ដីពី “អាករលើតម្លៃបន្ថែម”



ស្កេន ដើម្បីចូលទៅទស្សនាវីដេអូដើម

កម្មវិធីនេះមានលោក **ឆាយ ជាហេង** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ និងលោក **ឯក ពិសិដ្ឋ** ប្រធានការិយាល័យនៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការ របស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី២៣ខែឧសភា ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី២ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុក មានមតិយោបល់ (Comments) ចំនួន ៥៨ អ្នកចូលទស្សនាចំនួន ២០ ៧០០ ដង និងមានការចែករំលែកបន្តចំនួន ១៣៨ ដង។

## កម្មវិធីពន្ធដារកម្ពុជាស្ដីពី “វគ្គបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈពន្ធដារ”



ស្កេន ដើម្បីចូលទៅទស្សនាវីដេអូដើម

កម្មវិធីនេះមានលោក **ស៊ុន វុទ្ធី** នាយកសាលាជាតិពន្ធដារ និងលោក **ស៊ីវ ស៊ុនហួច** អនុប្រធានការិយាល័យនៃនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការ របស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី២ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុកមានមតិយោបល់ (Comments) ចំនួន ៥៣ អ្នកចូលទស្សនាចំនួន ៣៩ ៨០០ ដង និងមានការចែករំលែកបន្តចំនួន ២៣៣ ដង។

## កម្មវិធីពន្ធដារកម្ពុជាស្តីពី “អាករលើតម្លៃបន្ថែម ចំពោះប្រតិបត្តិការពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិក”

កម្មវិធីនេះមានឯកឧត្តមបណ្ឌិត **កែន សម្បត្តិ** អគ្គនាយករង និងលោកបណ្ឌិត **អេខ រតនា** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការ របស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី២ ឆ្នាំ២០២៤ តាមស្ថិតិ នៅលើទំព័រហ្វេសប៊ុកមានមតិយោបល់ (Comments) ចំនួន ៥១ អ្នកចូលទស្សនាចំនួន ២០ ៦០០ ដង និងមានការចែករំលែកបន្តចំនួន ១៩០ ដង៕



ស្កេន ដើម្បីចូលទៅទស្សនាវីដេអូដើម

## កម្មវិធីពន្ធដារកម្ពុជាស្តីពី “នីតិវិធីនៃការដាក់លិខិតស្នើសុំនានា មកអគ្គនាយកដ្ឋានពន្ធដារ”

កម្មវិធីនេះមានលោក **កែ ឈុំបញ្ញា** អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ និងលោក **ខៀវ វិទ្យា** អនុប្រធានការិយាល័យនៃនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី២ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុកមានមតិយោបល់ (Comments) ចំនួន ៦៩ អ្នកចូលទស្សនាចំនួន ៤៨ ៥០០ ដង និងមានការចែករំលែកបន្តចំនួន ២៥៩ ដង៕



ស្កេន ដើម្បីចូលទៅទស្សនាវីដេអូដើម

## កម្មវិធីពន្ធដារកម្ពុជាស្តីពី “ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធ អាជីវកម្មតាមអនឡាញ (e-Filing)”

កម្មវិធីនេះមានលោក **ស៊ីវ ស៊ុនហួច** អនុប្រធានការិយាល័យនៃនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន និងលោក **សុធី គីរី** អនុប្រធានការិយាល័យនៃនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការ របស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី២ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុកមានមតិយោបល់ (Comments) ចំនួន ៣៧ អ្នកចូលទស្សនាចំនួន ៣៣ ៧០០ ដង និងមានការចែករំលែកបន្តចំនួន ៤០៩ ដង៕



ស្កេន ដើម្បីចូលទៅទស្សនាវីដេអូដើម

## កម្មវិធីពន្ធដារកម្ពុជាស្តីពី “ពន្ធលើមធ្យោបាយដឹកជញ្ជូន”




ស្កេន ដើម្បីចូលទៅទស្សនាវីដេអូដើម

កម្មវិធីនេះមានលោក **ជួប ចាន់ដារ៉ា** អនុប្រធានការិយាល័យនៃនាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ និងលោក **អ៊ុក ដាវិសុទ្ធ** មន្ត្រីនៃនាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។បើគិតមកដល់ដំណាច់ត្រីមាសទី២ ឆ្នាំ២០២៤តាមស្ថិតិនៅលើទំព័រហ្វេសប៊ុកមានមតិយោបល់ (Comments) ចំនួន ២២ អ្នកចូលទស្សនាចំនួន ១៣ ៦០០ ដង និងមានការចែករំលែកបន្តចំនួន ១១៥ ដង៕



## ៣.ការចាត់ចែងលិខិតប្រកាសពន្ធ

អគ្គនាយកដ្ឋានពន្ធដារ បាននិងកំពុងដាក់ឱ្យប្រើប្រាស់កម្មវិធីប្រកាសពន្ធសម្រាប់អ្នកជាប់ពន្ធតូចលើទូរស័ព្ទដៃ ឈ្មោះ GDT Tax Prefiling App ដែលមានមុខងារ ១.កត់ត្រាទិន្នន័យទិញ-លក់ ២.ប្រកាសពន្ធប្រចាំខែ-ប្រចាំឆ្នាំ ៣.មើលប្រវត្តិប្រកាសពន្ធ-ប្រវត្តិបង់ប្រាក់ពន្ធ និង៤.ពិនិត្យមើលបំណុលពន្ធរបស់ក្រុមហ៊ុនលោកអ្នកអាចចូលទៅទាញយកនៅក្នុង Play Store ឬ App Store។ សម្រាប់អ្នកជាប់ពន្ធមធ្យមនិងធំ ចាប់តាំងពីខែកញ្ញា ឆ្នាំ២០២២ អគ្គនាយកដ្ឋានពន្ធដារ បានដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញ (e-Filing) និងប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI e-Filing) ដែលមានលក្ខណៈពេញលេញភ្ជាប់ជាមួយនឹងមុខងារទូទាត់ប្រាក់ពន្ធតាមរយៈប្រព័ន្ធអេឡិចត្រូនិក និងប្រព័ន្ធធនាគារ ដើម្បីផ្តល់ភាពងាយស្រួលជូនអ្នកជាប់ពន្ធកាត់បន្ថយពេលវេលា និងដោះស្រាយបញ្ហាប្រឈមក្នុងការបំពេញលិខិតប្រកាសនិងទូទាត់ប្រាក់ពន្ធ។ បន្ថែមពីនេះ នាថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៣ អគ្គនាយកដ្ឋានពន្ធដារ បានចេញសេចក្តីណែនាំលេខ ៤៥៤១៧ អពដ ស្តីពីនីតិវិធីនៃការកែតម្រូវលិខិតប្រកាសពន្ធប្រចាំខែតាមអនឡាញ ក្នុងគោលបំណងផ្តល់ជូនអ្នកជាប់ពន្ធក្នុងការកែតម្រូវលិខិតប្រកាសពន្ធប្រចាំខែកន្លងមក ដែលបានប្រកាសខុសទិន្នន័យដោយផ្អែកលើមូលដ្ឋាន នៃការភាន់ច្រឡំ ឬភ្លាំងភ្លាត់ ឬមានបំណងធ្វើបច្ចុប្បន្នភាពទិន្នន័យ ព្រមទាំងបញ្ចូលមុខងារថ្មី រួមមាន ការភ្ជាប់លិខិតផ្ទេរសិទ្ធិនិងប័ណ្ណសម្គាល់សម្រាប់គណនីប្រើប្រាស់ជាភ្នាក់ងារសេវាកម្មពន្ធដារនិងតំណាងសហគ្រាស ភ្ជាប់របាយការណ៍ហិរញ្ញវត្ថុ និងការកែតម្រូវលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំដែលបានប្រកាសរួចរាល់៕

***ដើម្បីឈ្វេងយល់កាន់តែច្បាស់អំពីនីតិវិធីក្នុងការដាក់ពាក្យស្នើសុំកែតម្រូវលិខិតប្រកាសពន្ធប្រចាំខែ សូមលោក លោកស្រីស្កេននូវ QR Code នេះ***



# ៤.ការធ្វើសវនកម្មពន្ធដារ

ក្នុងរយៈពេល ៦ខែដើមឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានធ្វើសវនកម្មគ្រប់ប្រភេទលើសហគ្រាសសរុបបាន ចំនួន **៦ ៤១៨ ករណី** មានប្រាក់ពន្ធចំនួន **៣ ៥៣៩,០៣ ប៊ីលានរៀល**។ បើប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៣ ឃើញថាការធ្វើសវនកម្មមានការថយចុះចំនួន **១២៨ ករណី** ស្មើនឹង **១,៩៦%**។

**ចំនួនករណី និងប្រាក់ពន្ធអាករ ដែលបានមកពីការធ្វើសវនកម្ម រយៈពេល ៦ខែដើមឆ្នាំ២០២៤ ធៀបនឹងរយៈពេលដូចគ្នា ក្នុងឆ្នាំ២០២៣**

| បរិយាយ | ចំនួនករណី | ប្រាក់ពន្ធអាករ (ប៊ីលានរៀល) |
|---|---|---|
| ឆ្នាំ២០២៤ | ៦ ៤១៨ | ៣ ៥៣៩,០៣ |
| ឆ្នាំ២០២៣ | ៦ ៥៤៦ | ៦ ២៧៤,៤០ |

# ៥.ការប្រមូលបំណុលពន្ធ និងបណ្ដឹងតវ៉ា

## ការប្រមូលបំណុលពន្ធ

ក្នុងរយៈពេល ៦ខែដើមឆ្នាំ២០២៤ បំណុលពន្ធប្រមូលបានមានចំនួន **៣៤៧,៨៥ ប៊ីលានរៀល** (ប្រមាណជា **៨៥,៨៩ លានដុល្លារ**) បើប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៣ មានចំនួន **៤៧០,៥៩ ប៊ីលានរៀល** (ប្រមាណជា **១១៦,១៩ លានដុល្លារ**) ៕

**លទ្ធផលប្រមូលបំណុលពន្ធ រយៈពេល ៦ខែដើមឆ្នាំ២០២៤ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៣**

ឯកតាគិតជាប៊ីលានរៀល

| បរិយាយ | រយៈពេល៣ខែ | មេសា | ឧសភា | មិថុនា | សរុបរួម |
|---|---|---|---|---|---|
| ឆ្នាំ២០២៤ | ១៧៣,២៩ | ៥៥,៣៣ | ៦០,៤៦ | ៥៨,៧៨ | ៣៤៧,៨៥ |
| ឆ្នាំ២០២៣ | ២២៨,៤៦ | ៨៥,៣២ | ៧២,៤៤ | ៨៤,៣៧ | ៤៧០,៥៩ |
| %ថយ | -២៤,១៥% | -៣៥,១៥% | -១៦,៥៤% | -៣០,៣៣% | -២៦,០៨% |

*សម្គាល់៖ តួលេខប្រមូលបំណុលពន្ធ "សរុបរួម" មានការកែតម្រូវឡើងវិញ និងកត់ត្រាបន្ថែមនូវតួលេខបំណុលពន្ធទារបានក្នុងខែមេសា-មិថុនា មួយចំនួន ដោយអ្នកជាប់ពន្ធមិនបានយកបង្កាន់ដៃទូទាត់ប្រាក់ពន្ធទៅប្រកាស ដើម្បីកត់ត្រា។

## បណ្ដឹងតវ៉ា

ក្នុងរយៈពេល ៦ខែដើមឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានដោះស្រាយសំណុំឯកសារបណ្ដឹងតវ៉ា ចំនួន **៥១៨ ករណី** មានប្រាក់ពន្ធ **៩៩៣,០៦ ប៊ីលានរៀល** បើប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៣ គឺមានការកើនឡើង ចំនួន **៣១៧ ករណី** ប្រាក់ពន្ធកើនឡើងចំនួន **៩៤៧,៥៣ ប៊ីលានរៀល**។ បំណុលពន្ធបានបង់ក្នុងរយៈពេល ៦ខែ ដើមឆ្នាំ២០២៤ មានចំនួន **១៥,២៦ ប៊ីលានរៀល** ប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៣ កើនឡើងចំនួន **៦,៧៤ ប៊ីលានរៀល**៕

# ៦.បច្ចេកវិទ្យាព័ត៌មាន

អគ្គនាយកដ្ឋានពន្ធដារបានបន្តធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មានពន្ធដារ សម្រាប់គាំទ្រដល់ការគ្រប់គ្រងការប្រមូលចំណូលពន្ធ ការផ្តល់សេវាអ្នកជាប់ពន្ធ ចាប់ពីឆ្នាំ២០១៤ ដល់បច្ចុប្បន្នសរុបចំនួន **៨២ ប្រព័ន្ធ-កម្មវិធី** និងគេហទំព័រ។

**ការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ ពីឆ្នាំ ២០១៤ ដល់បច្ចុប្បន្ន**

| បរិយាយ | ប្រព័ន្ធ | កម្មវិធី | គេហទំព័រ | សរុបរួម |
|---|---|---|---|---|
| ឆ្នាំ២០១៤ | ០៣ | ០១ | ០០ | ០៤ |
| ឆ្នាំ២០១៥ | ០៣ | ០២ | ០០ | ០៥ |
| ឆ្នាំ២០១៦ | ០៣ | ០១ | ០០ | ០៤ |
| ឆ្នាំ២០១៧ | ១០ | ០១ | ០១ | ១២ |
| ឆ្នាំ២០១៨ | ០៤ | ០៤ | ០០ | ០៨ |
| ឆ្នាំ២០១៩ | ០១ | ០០ | ០០ | ០១ |
| ឆ្នាំ២០២០ | ១៣ | ០៤ | ០១ | ១៨ |
| ឆ្នាំ២០២១ | ០៧ | ០២ | ០០ | ០៩ |
| ឆ្នាំ២០២២ | ១១ | ០៣ | ០០ | ១៤ |
| ឆ្នាំ២០២៣ | ០៣ | ០៣ | ០០ | ០៦ |
| ឆ្នាំ២០២៤ | ០១ | ០០ | ០០ | ០១ |
| **សរុបរួម** | ៥៩ | ២១ | ០២ | ៨២ |

**ប្រព័ន្ធ-កម្មវិធីអភិវឌ្ឍថ្មី ដែលសម្រេចបាន ក្នុងរយៈពេល ៦ខែដើមឆ្នាំ២០២៤**

| បរិយាយ | ប្រភេទ | ជំនាន់ទី | វឌ្ឍនភាព |
|---|---|---|---|
| ប្រព័ន្ធគ្រប់គ្រងសហគ្រាសដើមនិងភ្នាក់ងារផ្គត់ផ្គង់បន្ត | ប្រព័ន្ធ | ១.០.០ | សម្រេច |
| ប្រព័ន្ធគ្រប់គ្រងពន្ធលើចំណេញមូលធន | ប្រព័ន្ធ | ១.០.០ | ៩០% |
| កម្មវិធីឆាតបូត | ប្រព័ន្ធ | ១.០.០ | ៩០% |

## ការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ ពីឆ្នាំ ២០១៤ ដល់បច្ចុប្បន្ន

### ឆ្នាំ២០១៤

១.កម្មវិធីគណនាពន្ធលើមធ្យោបាយដឹកជញ្ជូន
២.ប្រព័ន្ធគ្រប់គ្រងពន្ធមធ្យោបាយដឹកជញ្ជូន
៣.ប្រព័ន្ធគ្រប់គ្រងការចុះបញ្ជីសហគ្រាស
៤.ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស

### ឆ្នាំ២០១៥

៥.កម្មវិធីគណនាពន្ធលើប្រាក់បៀវត្ស
៦.កម្មវិធីប្រតិទិនពន្ធដារ
៧.ប្រព័ន្ធសុវត្ថិភាពច្រកចេញ-ចូល
៨.ប្រព័ន្ធគ្រប់គ្រងពន្ធអចលនទ្រព្យ និងប្រថាប់ត្រា
៩.ប្រព័ន្ធគ្រប់គ្រងពាក្យស្នើសុំប្រឡងចូលបម្រើការងារ

### ឆ្នាំ២០១៦

១០.កម្មវិធីអង្កេតសហគ្រាស
១១.ប្រព័ន្ធគ្រប់គ្រងសន្និធិបង្កាន់ដៃទទួលប្រាក់ពន្ធ
១២.ប្រព័ន្ធគ្រប់គ្រងការទទួលប្រាក់ពន្ធ
១៣.ប្រព័ន្ធគ្រប់គ្រងលើការជួលអចលនទ្រព្យ

### ឆ្នាំ២០១៧

១៤.គេហទំព័របញ្ជូនរបាយការណ៍ព័ត៌មាន(FATCA)
១៥.ប្រព័ន្ធត្រួតពិនិត្យពន្ធមធ្យោបាយតាមRFID
១៦.ប្រព័ន្ធគ្រប់គ្រងកម្មវិធីប្រជុំរបស់អពដ
១៧.ប្រព័ន្ធគ្រប់គ្រងបំណុលពន្ធ
១៨.ប្រព័ន្ធគ្រប់គ្រងគណនីរបស់មន្ត្រីនិងដៃគូសហការ
១៩.ប្រព័ន្ធរក្សាទុកនិងចែកចាយឯកសារផ្ទៃក្នុង
២០.ប្រព័ន្ធគ្រប់គ្រងអ៊ីម៉ែលរបស់អពដ
២១.ប្រព័ន្ធគ្រប់គ្រងសន្លឹកតែមប្រិ៍បារី
២២.ប្រព័ន្ធគ្រប់គ្រងសវនកម្មសហគ្រាស
២៣.ប្រព័ន្ធគ្រប់គ្រងមជ្ឈមណ្ឌលពិគ្រោះយោបល់
២៤.ប្រព័ន្ធគ្រប់គ្រងការបង់ពន្ធតាមអនឡាញ
២៥.កម្មវិធីត្រួតពិនិត្យតែមប្រិ៍បារី

### ឆ្នាំ២០១៨

២៦.ប្រព័ន្ធគ្រប់គ្រងព័ត៌មានសហគ្រាស
២៧.ប្រព័ន្ធគ្រប់គ្រងព័ត៌មានបុគ្គល
២៨.ប្រព័ន្ធគ្រប់គ្រងតាមដានឯកសារ
២៩.ប្រព័ន្ធតាមដានចំណូលពន្ធដារ
៣០.កម្មវិធីព័ត៌មានស្តីពីពន្ធដារ
៣១.កម្មវិធីត្រួតពិនិត្យបេក្ខជនប្រឡង
៣២.កម្មវិធីជជែកជាមួយពន្ធដារ
៣៣.កម្មវិធីអង្កេតអចលនទ្រព្យ

### ឆ្នាំ២០១៩

៣៤.ប្រព័ន្ធគ្រប់គ្រងការស្នើសុំបង្វិលសង អតប

### ឆ្នាំ២០២០

៣៥.គេហទំព័រអគ្គនាយកដ្ឋានពន្ធដារ
៣៦.ប្រព័ន្ធគ្រប់គ្រងរបាយការណ៍នៃការធ្វើសារខ្មី
៣៧.ប្រព័ន្ធបញ្ជូនឯកសារលិខិតប្រកាសរបស់អពដ
៣៨.ប្រព័ន្ធសន្ទានកម្មទិន្នន័យរវាងប្រព័ន្ធអពដ និងអគរក
៣៩.ប្រព័ន្ធសន្ទានកម្មទិន្នន័យរវាងប្រព័ន្ធអពដ និងដឹកជញ្ជូនផ្លូវគោក នៃក្រសួងសាធារណការនិងដឹកជញ្ជូន
៤០.ប្រព័ន្ធសន្ទានកម្មទិន្នន័យចំណូលពន្ធរវាង FMIS
៤១.ប្រព័ន្ធគ្រប់គ្រងស្នើសុំការលើកទឹកចិត្តពន្ធដារ
៤២.ប្រព័ន្ធគ្រប់គ្រងការសិក្សាពន្ធដារ
៤៣.ប្រព័ន្ធគ្រប់គ្រងគណនីអ្នកជាប់ពន្ធ
៤៤.ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មតាមអនឡាញ
៤៥.ប្រព័ន្ធគ្រប់គ្រងសន្និធិរបស់អគ្គនាយកដ្ឋានពន្ធដារ
៤៦.ប្រព័ន្ធគ្រប់គ្រងការចៀសវាងយកពន្ធត្រួតគ្នា
៤៧.ប្រព័ន្ធគ្រប់គ្រងចុះបញ្ជីសហគ្រាសតាមថ្នាលបច្ចេកវិទ្យា
៤៨.ប្រព័ន្ធគ្រប់គ្រងបង់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិយានយន្ត
៤៩.កម្មវិធីការប្រកាសពន្ធអាជីវកម្មសម្រាប់អ្នកជាប់ពន្ធតូច
៥០.កម្មវិធីត្រួតពិនិត្យនិងតាមដានឯកសារ
៥១.កម្មវិធីទូរស័ព្ទដៃអ្នកជាប់ពន្ធ
៥២.កម្មវិធីគ្រប់គ្រងលិខិតរដ្ឋបាលពន្ធដារ

### ឆ្នាំ២០២១

៥៣.ប្រព័ន្ធស្វ័យប្រវត្តិកម្មផ្ទៀងផ្ទាត់ការបង់ពន្ធ
៥៤.ប្រព័ន្ធគ្រប់គ្រងរបាយការណ៍ពន្ធដារ
៥៥.ប្រព័ន្ធគ្រប់គ្រងសវនកម្មអាករលើតម្លៃបន្ថែម
៥៦.ប្រព័ន្ធគាំទ្រការបង់ពន្ធមធ្យោបាយដឹកជញ្ជូន
៥៧.ប្រព័ន្ធគ្រប់គ្រងការស្នើសុំលិខិតបញ្ជាក់និងវិញ្ញាបនបត្រ
៥៨.ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធTOIអនឡាញ
៥៩.កម្មវិធីបញ្ជូនឯកសារអេឡិចត្រូនិក
៦០.កម្មវិធីដឹកជញ្ជូនរបស់អគ្គនាយកដ្ឋានពន្ធដារ
៦១.កម្មវិធីផ្ទៀងផ្ទាត់ព័ត៌មាននិងប្រគល់ឯកសារពន្ធដារ

### ឆ្នាំ២០២២

៦២.ប្រព័ន្ធគ្រប់គ្រងនិងគាំទ្រកម្មវិធីទូរស័ព្ទដៃ-ពន្ធតែមប្រិ៍
៦៣.ប្រព័ន្ធគ្រប់គ្រងនិងគាំទ្រកម្មវិធីទូរស័ព្ទដៃ-ពន្ធមធ្យោបាយ
៦៤.ប្រព័ន្ធគ្រប់គ្រងគណនីអ្នកប្រើប្រាស់តាមអនឡាញ
៦៥.ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្ម
៦៦.ប្រព័ន្ធគ្រប់គ្រងនិងគាំទ្រកម្មវិធីទូរស័ព្ទដៃ-ពន្ធអចលនទ្រព្យ
៦៧.ប្រព័ន្ធគ្រប់គ្រងអត្រាប្តូរប្រាក់
៦៨.ប្រព័ន្ធស្នូលនៃអគ្គនាយកដ្ឋានពន្ធដារ(CoreSystem)
៦៩.ប្រព័ន្ធគ្រប់គ្រងកម្មវិធីក្លៃយបត្រនាំសំណាង
៧០.ប្រព័ន្ធគ្រប់គ្រងទិន្នន័យអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក
៧១.ប្រព័ន្ធគ្រប់គ្រងទិន្នន័យឧបករណ៍វាស់ចំណុះស្រាបៀរនិងភេសជ្ជៈ
៧២.ប្រព័ន្ធគ្រប់គ្រងចំណាត់ថ្នាក់(MeritandDemerit_MDS)
៧៣.កម្មវិធីក្លៃយបត្រនាំសំណាង
៧៤.កម្មវិធីសទ្ទានុក្រមពន្ធដារ
៧៥.កម្មវិធីផ្ទៀងផ្ទាត់ព័ត៌មានសិស្ស(សម្រាប់ការបណ្តុះបណ្តាល)

### ឆ្នាំ២០២៣

៧៦.កម្មវិធីអនុម័តតាមប្រព័ន្ធអេឡិចត្រូនិក
៧៧.ប្រព័ន្ធគ្រប់គ្រងការអនុម័តតាមប្រព័ន្ធអេឡិចត្រូនិក(សម្រាប់មន្ត្រី)
៧៨.ប្រព័ន្ធគ្រប់គ្រងនិងគាំទ្រកម្មវិធីទូរស័ព្ទដៃ-ពន្ធលើផ្ទាំងផ្សព្វផ្សាយ
៧៩.ប្រព័ន្ធកំណត់ផែនការចំណូលពន្ធ
៨០.កម្មវិធីលិខិតរដ្ឋបាលអេឡិចត្រូនិក
៨១.កម្មវិធីផ្ទាំងព័ត៌មានលិខិតរដ្ឋបាលអេឡិចត្រូនិក

### ឆ្នាំ២០២៤

៨២.ប្រព័ន្ធគ្រប់គ្រងសហគ្រាសដើម និងភ្នាក់ងារផ្គត់ផ្គង់បន្ត

# QR Code វីដេអូណែនាំអំពីការប្រើប្រាស់ប្រព័ន្ធនិងកម្មវិធីនាក់ទងនឹងពន្ធដារ

## កម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ (GDT e-Administration)



**ទស្សនាតាមផ្នែក៖**

- 03:49 : សម្រាប់បុគ្គលទូទៅ
- 07:33 : សម្រាប់ភ្នាក់ងារសេវាកម្មពន្ធដារ
- 11:46 : សម្រាប់អ្នកតំណាងសហគ្រាស

សូមស្កេន QR Code

## កម្មវិធីទូរស័ព្ទដៃអ្នកជាប់ពន្ធ (GDT Taxpayer App)



មុខងារបង់ពន្ធលើផ្ទាំងផ្សព្វផ្សាយ

**ទស្សនាតាមផ្នែក៖**

- 00:46 : ការបង្កើតគណនីប្រើប្រាស់កម្មវិធី
- 02:03 : ការចូលប្រើប្រាស់កម្មវិធី
- 02:38 : ការបំពេញលិខិតប្រកាសពន្ធលើផ្ទាំងផ្សព្វផ្សាយ

សូមស្កេន QR Code




មុខងារបន្ថែមយានយន្តថ្មី

**ទស្សនាតាមផ្នែក៖**

- 00:26 : ការចូលប្រើប្រាស់កម្មវិធី
- 02:03 : ការបំពេញបន្ថែមយានយន្តថ្មី

សូមស្កេន QR Code




មុខងារបង់ពន្ធអចលនទ្រព្យ រហ័ស

**ទស្សនាតាមផ្នែក៖**

- 01:00 : ការចូលប្រើប្រាស់កម្មវិធី
- 02:03 : របៀបបង់ពន្ធអចលនទ្រព្យ

សូមស្កេន QR Code

## ប្រព័ន្ធបង់ប្រាក់ពន្ធតាមអនឡាញ (E-Payment)




**ទស្សនាតាមផ្នែក៖**

- 00:30 : ការចូលប្រើប្រាស់កម្មវិធី
- 00:40 : ការបង្កើតគណនីប្រើប្រាស់កម្មវិធី
- 01:40 : របៀបបង់ពន្ធតាមអនឡាញ

សូមស្កេន QR Code

# QR Code វីដេអូណែនាំអំពីការប្រើប្រាស់ប្រព័ន្ធនិងកម្មវិធីទាក់ទងនឹងពន្ធដារ

## ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មតាមអនឡាញ សម្រាប់អ្នកជាប់ពន្ធមធ្យម និង ធំ (e-Filing)




**ទស្សនាតាមផ្នែក៖**

- 00:50 : ការចុះឈ្មោះដើម្បីប្រើប្រាស់ប្រព័ន្ធ
- 01:54 : ការចូលប្រើប្រាស់ប្រព័ន្ធ
- 07:05 : ការប្រកាសពន្ធប្រចាំខែ

សូមស្កេន QR Code




មុខងារ (Reverse Charge)

**ទស្សនាតាមផ្នែក៖**

- 00:50 : ការចូលប្រើប្រាស់ប្រព័ន្ធ
- 01:30 : ការប្រកាសពន្ធ

សូមស្កេន QR Code

## កម្មវិធីប្រកាសពន្ធសម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Prefiling App)




**ទស្សនាតាមផ្នែក៖**

- 00:50 : ការបង្កើតគណនីប្រើប្រាស់កម្មវិធី
- 02:10 : ការចូលប្រើប្រាស់កម្មវិធី

សូមស្កេន QR Code



មុខងារប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ

**ទស្សនាតាមផ្នែក៖**

- 00:40 : ការចូលប្រើប្រាស់កម្មវិធី
- 00:50 : ការប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ

សូមស្កេន QR Code

## ប្រព័ន្ធគ្រប់គ្រងទិន្នន័យអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក (E-Commerce Tax System)




(Khmer Version) (English Version)

# QR Code វីដេអូណែនាំអំពីការប្រើប្រាស់ប្រព័ន្ធនិងកម្មវិធីទាក់ទងនឹងពន្ធដារ

## កម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw App)




ទស្សនាតាមផ្នែក៖

- 00:20 : ការបង្កើតគណនីប្រើប្រាស់កម្មវិធី
- 01:50 : ការចូលប្រើប្រាស់កម្មវិធី
- 02:30 : ការបញ្ចូលវិក្កយបត្រថ្មី

សូមស្កេន QR Code

## ប្រព័ន្ធគ្រប់គ្រងការស្នើសុំវិញ្ញាបនបត្រពន្ធដារ



មុខងារស្នើសុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ

ទស្សនាតាមផ្នែក៖

- 01:00 : ការបង្កើតគណនីថ្មី
- 02:20 : ការចូលប្រើប្រាស់ប្រព័ន្ធ
- 02:55 : ការដាក់ពាក្យស្នើសុំនិងបោះពុម្ពវិញ្ញាបនបត្រពន្ធដារ

សូមស្កេន QR Code



មុខងារស្នើសុំការផ្អាកអាជីវកម្ម ឬបើកដំណើរការឡើងវិញ

ទស្សនាតាមផ្នែក៖

- 00:45 : ការស្នើសុំផ្អាកសកម្មភាពអាជីវកម្មបណ្តោះអាសន្ន
- 02:40 : បន្តស្នើសុំផ្អាកសកម្មភាពអាជីវកម្ម
- 05:00 : ស្នើសុំបើកដំណើរការឡើងវិញ

សូមស្កេន QR Code

## កម្មវិធីត្រួតពិនិត្យ និងតាមដានឯកសារ (GDT Check & Track) ជំនាន់ថ្មី



ទស្សនាតាមផ្នែក៖

- 00:20 : ការប្រើប្រាស់កម្មវិធី
- 00:45 : មុខងារផ្សេងៗ

សូមស្កេន QR Code

## កម្មវិធីសទ្ទានុក្រមពន្ធដារ (Tax Glossary App)




ទស្សនាតាមផ្នែក៖

- 00:40 : ការប្រើប្រាស់កម្មវិធី
- 02:00 : មុខងារផ្សេងៗ

សូមស្កេន QR Code

# ផ្នែកទី៣
# បច្ចុប្បន្នភាពច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយសារពើពន្ធ

១. ប្រកាស

២. សេចក្តីណែនាំ

៣. សេចក្តីជូនដំណឹង

# បច្ចុប្បន្នភាពច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយសារពើពន្ធ

សរុបក្នុងរយៈពេល ៦ខែដើមឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងកែលម្អគោលនយោបាយសារពើពន្ធ តាមរយៈការដាក់ចេញឱ្យអនុវត្តនូវលិខិតបទដ្ឋានគតិយុត្តនានាស្ដីពីពន្ធដារ ដូចមានក្នុងតារាងនិងអត្ថបទខាងក្រោម៖

**បច្ចុប្បន្នភាពច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយសារពើពន្ធ រយៈពេល ៦ខែដើមឆ្នាំ២០២៤**

| បរិយាយ | រយៈពេល៣ខែ | ខែមេសា | ខែឧសភា | ខែមិថុនា | សរុបរួម |
|---|---|---|---|---|---|
| ច្បាប់ | ០០ | ០០ | ០០ | ០០ | ០០ |
| អនុក្រឹត្យ | ០៣ | ០០ | ០០ | ០០ | ០៣ |
| ប្រកាស | ១២ | ០០ | ០១ | ០១ | ១៤ |
| សារាចរណែនាំ | ០០ | ០០ | ០០ | ០០ | ០០ |
| សេចក្ដីណែនាំ | ០៣ | ០១ | ០០ | ០០ | ០៤ |
| សេចក្ដីជូនដំណឹង | ០៤ | ០១ | ០៣ | ០០ | ០៨ |
| សេចក្ដីសម្រេច | ០០ | ០០ | ០០ | ០០ | ០០ |
| **សរុបរួម** | ២២ | ០២ | ០៤ | ០១ | ២៩ |

## ១.ប្រកាស

### ប្រកាស ស្ដីពីការលើកទឹកចិត្តពន្ធលើប្រាក់ចំណូល ចំពោះគម្រោងពង្រីកនៃគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់

នាថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាសលេខ ៣១៣ សហវ.ប្រក.អពដ ស្ដីពីការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលចំពោះគម្រោងពង្រីកនៃគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ "គ.ព.គ.ល.គ"។ ក្នុងគោលបំណងណែនាំអនុវត្តការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលចំពោះ គ.ព.គ.ល.គ ដូចមានចែងក្នុងមាត្រា១៦ នៃអនុក្រឹត្យលេខ ១៣៩ អនក្រ.បក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣ ស្ដីពីការអនុវត្តច្បាប់ ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។ ប្រកាសនេះបានលើកឡើងនូវពាក្យគន្លឹះ៖ លក្ខខណ្ឌទទួលបានការលើកលែងពន្ធលើប្រាក់ចំណូលចំពោះ គ.ព.គ.ល.គ. ការគណនាប្រាក់ចំណូលដែលត្រូវបានលើកលែងពន្ធចំពោះ គ.ព.គ.ល.គ. ការលើកលែងប្រាក់រំដោះពន្ធលើប្រាក់ចំណូល ១% និងពន្ធអប្បបរមា និងការដកហូតការលើកទឹកចិត្ត។

ដើម្បីទទួលបានឯកសារ ឬអានលម្អិត សូមស្កេន QR Code

## ប្រកាស ស្ដីពីការណែនាំអនុវត្តអនុក្រឹត្យស្ដីពីការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ

នាថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាសលេខ ៣៦០ សហវ.ប្រក.អពដ ស្ដីពីការណែនាំអនុវត្តអនុក្រឹត្យស្ដីពីការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ ប្រកាសនេះ មានគោលបំណងកំណត់អំពីវិធាននិងនីតិវិធាននៃការលើកទឹកចិត្តផ្នែកពន្ធដារ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ចំពោះសហគ្រាសស្ថិតក្នុងវិស័យអាទិភាព។ ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះសហគ្រាសធុនមីក្រូតូច និងមធ្យម ដែលចុះបញ្ជីដោយស្ម័គ្រចិត្តដើម្បីប្រកបអាជីវកម្មក្នុងវិស័យអាទិភាពមួយចំនួន រួមមាន លក់ដុំ លក់រាយ និងជួសជុល សេវាកម្មស្នាក់នៅនិងអាហារ សិប្បកម្ម និងសហគមន៍កសិកម្ម ដែលអាចទទួលបានការលើកទឹកចិត្តផ្នែកពន្ធដារ ត្រូវចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្ត (ដែលមិនមែនជាការចុះបញ្ជីដោយឯកតោភាគីរបស់រដ្ឋបាលសារពើពន្ធ) តាមរយៈគេហទំព័រចុះបញ្ជីអាជីវកម្ម https://www.registrationservices.gov.kh (CamDX) ឬមកចុះបញ្ជីដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ៕

ដើម្បីទទួលបានឯកសារ ឬអានលម្អិត សូមស្កេន QR Code

# ២.សេចក្ដីណែនាំ

## សេចក្ដីណែនាំ ស្ដីពីការលើកលែងពន្ធអប្បបរមា ដល់សហគ្រាសជាគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់

នាថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានចេញសេចក្ដីណែនាំលេខ ១៣៨០៤ អពដ ស្ដីពីការលើកលែងពន្ធអប្បបរមាដល់សហគ្រាសជាគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់។ ក្នុងគោលបំណងធ្វើការណែនាំដល់សហគ្រាសដែលជាគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ (គ.ល.គ-QIP) ដែលទទួលបានការលើកលែងពន្ធអប្បបរមា ត្រូវមានរបាយការណ៍សវនកម្មឯករាជ្យ និងកាន់បញ្ជិកាគណនេយ្យឱ្យបានត្រឹមត្រូវ។ ចំពោះ សហគ្រាសជា គ.ល.គ. ដែលទើបចុះបញ្ជីថ្មីនឹងទទួលបានការលើកលែងពន្ធអប្បបរមាសម្រាប់ឆ្នាំដំបូង ដោយមិនតម្រូវផ្ដល់របាយការណ៍សវនកម្មឯករាជ្យមកអគ្គនាយកដ្ឋានពន្ធដារឡើយ។ នៅឆ្នាំបន្ទាប់ សហគ្រាស គ.ល.គ ត្រូវមានកាតព្វកិច្ចផ្ដល់របាយការណ៍សវនកម្មឯករាជ្យមកអគ្គនាយកដ្ឋានពន្ធដារយ៉ាងយូរត្រឹមដំណាច់ខែមិថុនា នៃឆ្នាំបន្ទាប់នីមួយៗ៕

ដើម្បីទទួលបានឯកសារ ឬអានលម្អិត សូមស្កេន QR Code

# ៣.សេចក្ដីជូនដំណឹង

## សេចក្ដីជូនដំណឹង ស្ដីពីការលុបចោលអាជ្ញាបណ្ណ ភ្នាក់ងារសេវាកម្មពន្ធដាររបស់ក្រុមហ៊ុន ជីអាយស៊ីធីហ្វកធ៍ ខនសាល់ធេនស៊ី & សឺវីស ឯ.ក

នាថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានចេញសេចក្ដីជូនដំណឹងលេខ ១៣៤០០ អពដ ស្ដីពីការលុបចោលអាជ្ញាបណ្ណភ្នាក់ងារសេវាកម្មពន្ធដាររបស់ក្រុមហ៊ុន ជីអាយស៊ីធីហ្វកធ៍ ខនសាល់ធេនស៊ី & សឺវីស ឯ.ក។ ការចេញសេចក្ដីជូនដំណឹងនេះ គឺដើម្បីជូនដំណឹងដល់លោក លោកស្រីជាអភិបាលក្រុមហ៊ុន អ្នកជាប់ពន្ធ និងសាធារណជនទូទៅដែលកំពុង ឬមានបំណងប្រើប្រាស់សេវាកម្មពាក់ព័ន្ធនឹងពន្ធដារពីក្រុមហ៊ុននេះ សូមផ្អាកឬកុំប្រើប្រាស់សេវាកម្មពាក់ព័ន្ធនឹងពន្ធដារ ដើម្បីចៀសវាងការទទួលរងទណ្ឌកម្មរដ្ឋបាលផ្សេងៗ ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្ដីពីពន្ធដារជាធរមាន៕

ដើម្បីទទួលបានឯកសារ ឬអានលម្អិត សូមស្កេន QR Code

## សេចក្ដីជូនដំណឹង ស្ដីពីកាលបរិច្ឆេទបញ្ជូលរបាយការណ៍ព័ត៌មាន គណនីជនជាតិអាមេរិកដែលត្រូវរាយការណ៍ (U.S. Reportable Accounts) សម្រាប់ឆ្នាំប្រតិទិន២០២៣ របស់គ្រឹះស្ថានហិរញ្ញវត្ថុ

នាថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានចេញសេចក្ដីជូនដំណឹងលេខ ១៧៥៦០ អពដ ស្ដីពីកាលបរិច្ឆេទបញ្ជូលរបាយការណ៍ព័ត៌មានគណនីជនជាតិអាមេរិកដែលត្រូវរាយការណ៍ (U.S. Reportable Accounts) សម្រាប់ឆ្នាំប្រតិទិន២០២៣របស់គ្រឹះស្ថានហិរញ្ញវត្ថុ។ ការចេញសេចក្ដីជូនដំណឹងនេះ គឺដើម្បីជូនដំណឹងដល់ធនាគារសហគ្រាសជានាវ៉ាប់រង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនមូលបត្រ និងស្ថាប័នប្រហាក់ប្រហែលដទៃទៀត ត្រូវបញ្ជូនរបាយការណ៍គណនីជនជាតិអាមេរិកដែលត្រូវរាយការណ៍សម្រាប់ឆ្នាំប្រតិទិន ២០២៣ ទៅអាជ្ញាធរចំណូលផ្ទៃក្នុងសហរដ្ឋអាមេរិក (U.S. Internal Revenue Service IRS) តាមរយៈអគ្គនាយកដ្ឋានពន្ធដារ ឱ្យបានត្រឹមថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤ ជាកំហិត៕

ដើម្បីទទួលបានឯកសារ ឬអានលម្អិត សូមស្កេន QR Code

## សេចក្ដីជូនដំណឹង ស្ដីពីការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា ចំនួន ៦៣ នាក់ សម្រាប់បម្រើការងារនៅនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាននៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

នាថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានចេញសេចក្ដីជូនដំណឹងលេខ ១៨៤៦៥ អពដ ស្ដីពីការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា ចំនួន ៦៣ នាក់ សម្រាប់បម្រើការងារនៅនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាននៃអគ្គនាយក-ដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ការចេញសេចក្ដីជូនដំណឹងនេះ គឺដើម្បីជូនដំណឹងដល់សាធារណជនដែលមានចំណាប់អារម្មណ៍ចង់ចូលបម្រើការងារនៅនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន លើផ្នែកចំនួន ៦ រួមមាន៖ ១.ផ្នែករដ្ឋបាល (Administration) ២.ផ្នែកបំប្លែងទិន្នន័យ (Data Processing) ៣.ផ្នែកគាំទ្រការដឹកជញ្ជូន (Delivery) ៤.ផ្នែកគាំទ្របច្ចេកទេស (Technical Support) ៥.ផ្នែកគាំទ្រសេវាអេឡិចត្រូនិកពន្ធដារ (e-Tax Service Support) និង ៦. ផ្នែកពហុព័ត៌មាន (Multimedia) ដោយត្រូវទាញយក (Download) ទម្រង់ពាក្យស្នើសុំចុះឈ្មោះប្រឡង និងទម្រង់ប្រវត្តិរូបសង្ខេបពីគេហទំព័រអគ្គនាយកដ្ឋានពន្ធដារ www.tax.gov.kh រួចបំពេញព័ត៌មានទាំងអស់និងចុះហត្ថលេខាសាមីខ្លួន ព្រមទាំងស្កេន (Scan) ឯកសារភ្ជាប់តម្រូវតាមការកំណត់ជា PDF File រួចផ្ញើទៅកាន់សារអេឡិច-ត្រូនិកដែលមានអាសយដ្ឋាន recruit@tax.gov.kh យ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៤៕

ដើម្បីទទួលបានឯកសារ ឬអានលម្អិត សូមស្កេន QR Code

## សេចក្ដីជូនដំណឹង ស្ដីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូនសម្រាប់ឆ្នាំ២០២៤

នាថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានចេញសេចក្ដីជូនដំណឹងលេខ ១៩១០៩ អពដ ស្ដីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូនសម្រាប់ឆ្នាំ២០២៤។ ការចេញសេចក្ដីជូនដំណឹងនេះ គឺដើម្បីជូនដំណឹងដល់ម្ចាស់យានយន្តទាំងអស់ឱ្យបានជ្រាបថា ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូនសម្រាប់ឆ្នាំ២០២៤នឹងត្រូវចាប់ផ្ដើមពីថ្ងៃទី១ ខែមិថុនា រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៤ តទៅ។ ម្ចាស់យានយន្តអាចធ្វើការបង់ពន្ធនៅអគ្គនាយកដ្ឋានពន្ធដារ ឬសាខាពន្ធដារខេត្ត-ខណ្ឌ ឬនៅតាមបណ្ដាសាខាធនាគារពាណិជ្ជដែលបានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬអាចបង់ពន្ធតាមកម្មវិធីទូរស័ព្ទដៃអ្នកជាប់ពន្ធ (GDT Taxpayer App) ដែលអាចទាញយកពី App Store សម្រាប់ iOS ឬ Play Store សម្រាប់ Android ចំពោះយានយន្តដែលធ្លាប់បានប្រកាសនិងបង់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូនឆ្នាំកន្លងមក៕

ដើម្បីទទួលបានឯកសារ ឬអានលម្អិត សូមស្កេន QR Code

# ផ្នែកទី៤
# កិច្ចសហប្រតិបត្តិការក្របខ័ណ្ឌជាតិ-អន្តរជាតិ

១. សកម្មភាពផ្សេងៗរបស់អគ្គនាយកដ្ឋានពន្ធដារ

២. កិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័ន

៣. កិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន អង្គការ សមាគម និងស្ថាប័នអន្តរជាតិ

៤. កិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា ( Double Taxation Agreement-DTA )

# ១. សកម្មភាពផ្សេងៗរបស់អគ្គនាយកដ្ឋានពន្ធដារ

## កិច្ចប្រជុំពិនិត្យនិងពិភាក្សាលើការស្នើសុំ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាក្នុងការបន្ថែមទិន្នន័យ ព័ត៌មានទៅក្នុងមុខងារសន្ទានកម្មប្រព័ន្ធស្វ័យប្រវត្តិកម្ម



នារសៀលថ្ងៃចន្ទ ទី២៩ ខែមេសា ឆ្នាំ២០២៤ នៅអគ្គនាយកដ្ឋានពន្ធដារ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារបានអញ្ជើញចូលរួមជាអធិបតីក្នុងកិច្ចប្រជុំពិនិត្យនិងពិភាក្សាលើការស្នើសុំរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្នុងការបន្ថែមទិន្នន័យព័ត៌មានទៅក្នុងមុខងារសន្ទានកម្ម ប្រព័ន្ធស្វ័យប្រវត្តិកម្ម រវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៃអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា៕



# កិច្ចប្រជុំពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យ និងសេចក្តីព្រាងប្រកាសពាក់ព័ន្ធនឹងច្បាប់ស្តីពីសារពើពន្ធ




នារសៀលថ្ងៃអង្គារ ទី៣០ ខែមេសា ឆ្នាំ២០២៤ នៅអគ្គនាយកដ្ឋានពន្ធដារ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានអញ្ជើញចូលរួមជាអធិបតីក្នុងកិច្ចប្រជុំពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យ និងសេចក្តីព្រាងប្រកាសពាក់ព័ន្ធនឹងច្បាប់ស្តីពីសារពើពន្ធ៕







# កិច្ចប្រជុំក្រុមការងារចំពោះកិច្ចទទួលបន្ទុកសិក្សា និងផ្តល់យោបល់លើស្ថានភាពពន្ធអាករ និងបរិយាកាសវិនិយោគ ក្នុងព្រះរាជាណាចក្រកម្ពុជា




នាព្រឹកថ្ងៃព្រហស្បតិ៍ ទី២៣ ខែឧសភា ឆ្នាំ២០២៤ នៅអគ្គនាយកដ្ឋានពន្ធដារ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំក្រុមការងារ ចំពោះកិច្ចទទួលបន្ទុកសិក្សានិងផ្តល់យោបល់លើស្ថានភាពពន្ធអាករ និងបរិយាកាសវិនិយោគក្នុងព្រះរាជាណាចក្រកម្ពុជា ដែលដឹកនាំដោយឯកឧត្តម **សុខ សារាវុឌ្ឍ**៕


ឯកឧត្តម *សុខ សារាវុឌ្ឍ*


ឯកឧត្តម *គង់ វិបុល*



# កិច្ចប្រជុំពិភាក្សាផ្ទៃក្នុងអគ្គនាយកដ្ឋានពន្ធដារ ដើម្បីពិនិត្យនិងផ្តល់ធាតុចូលបន្ថែមលើសេចក្តីព្រាងប្រកាសស្តីពី វិធាន និងនីតិវិធីសម្រាប់អនុវត្តកាតព្វកិច្ចសារពើពន្ធចំពោះ សហគ្រាសប្រកបអាជីវកម្មដឹកជញ្ជូនអន្តរជាតិតាមផ្លូវទឹក



នាព្រឹកថ្ងៃសុក្រ ទី៣១ ខែឧសភា ឆ្នាំ២០២៤ នៅអគ្គនាយកដ្ឋានពន្ធដារ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ សម្របសម្រួលកិច្ចប្រជុំពិភាក្សាផ្ទៃក្នុងអគ្គនាយកដ្ឋានពន្ធដារ ដើម្បីពិនិត្យនិងផ្តល់ធាតុចូលបន្ថែមលើសេចក្តីព្រាងប្រកាសស្តីពីវិធាន និងនីតិវិធីសម្រាប់អនុវត្តកាតព្វកិច្ចសារពើពន្ធចំពោះសហគ្រាសប្រកបអាជីវកម្មដឹកជញ្ជូនអន្តរជាតិតាមផ្លូវទឹក៕



# កិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រមូលចំណូលពន្ធ ប្រចាំខែមីនា និងប្រចាំត្រីមាសទី១ ព្រមទាំងទិសដៅសម្រាប់ អនុវត្តបន្តរបស់អគ្គនាយកដ្ឋានពន្ធដារ



*ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ*

នាព្រឹកថ្ងៃពុធ ទី២៤ ខែមេសា ឆ្នាំ២០២៤ នៅអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារគ្រប់គ្រងប្រមូលចំណូលពន្ធប្រចាំខែមីនា និងប្រចាំត្រីមាសទី១ ព្រមទាំងទិសដៅសម្រាប់អនុវត្តបន្តរបស់អគ្គនាយកដ្ឋានពន្ធដារ។







# កិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រមូលចំណូលពន្ធ ប្រចាំខែមេសា ខែឧសភា និងសម្រាប់រយៈពេល ៥ខែ ឆ្នាំ២០២៤ ព្រមទាំងទិសដៅសម្រាប់អនុវត្តបន្តរបស់អគ្គនាយកដ្ឋានពន្ធដារ



ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ

នាព្រឹកថ្ងៃព្រហស្បតិ៍ ទី២០ ខែមិថុនា ឆ្នាំ២០២៤ នៅអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារគ្រប់គ្រងប្រមូលចំណូលពន្ធប្រចាំខែមេសា ខែឧសភា និងសម្រាប់រយៈពេល ៥ខែ ឆ្នាំ២០២៤ ព្រមទាំងទិសដៅសម្រាប់អនុវត្តបន្តរបស់អគ្គនាយកដ្ឋានពន្ធដារ។







# កិច្ចប្រជុំពិនិត្យ ពិភាក្សា ប្រកាសស្តីពីកាតព្វកិច្ចសារពើពន្ធ ចំពោះសកម្មភាពអាជីវកម្មដឹកជញ្ជូនទំនិញតាមផ្លូវទឹកជាអន្តរជាតិ




នាព្រឹកថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤ នៅអគ្គនាយកដ្ឋានពន្ធដារ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយក-រដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានអញ្ជើញចូលរួមជាអធិបតីក្នុងកិច្ចប្រជុំពិនិត្យ ពិភាក្សា ប្រកាសស្តីពីកាតព្វកិច្ចសារពើពន្ធចំពោះសកម្មភាពអាជីវកម្មដឹកជញ្ជូនទំនិញតាមផ្លូវទឹកជាអន្តរជាតិ ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធ នៃអគ្គនាយកដ្ឋានពន្ធដារ៕








# ២. កិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័ន

## ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា (MOU) ស្តីពីការផ្លាស់ប្តូរក្រេឌីតសិក្សាជំនាញវិជ្ជាជីវៈពន្ធដារ រវាងអគ្គនាយកដ្ឋានពន្ធដារ និងវិទ្យាស្ថានខេមរអេដ



នាព្រឹកថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៤ នៅសាលាជាតិពន្ធដារ មានរៀបចំពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពី "ការផ្លាស់ប្តូរក្រេឌីតសិក្សាជំនាញវិជ្ជាជីវៈ ពន្ធដារ" រវាងអគ្គនាយកដ្ឋានពន្ធដារ និងវិទ្យាស្ថានខេមរអេដ (CamEd) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ និងលោក Casey Barnett នាយកវិទ្យាស្ថានខេមរអេដ (CamEd) ដោយមានការចូលរួមពីថ្នាក់ដឹកនាំ មន្ត្រីនៃអគ្គនាយកដ្ឋានពន្ធដារ ថ្នាក់ដឹកនាំ និងនិស្សិតនៃវិទ្យាស្ថានខេមរអេដ (CamEd) សរុបចំនួន **១៦៥ នាក់**។

ជាកិច្ចចាប់ផ្តើមលោក Casey Barnett នាយកវិទ្យាស្ថានខេមរអេដបានផ្តល់មតិអំពីការផ្លាស់ប្តូរក្រេឌីតសិក្សា ជំនាញវិជ្ជាជីវៈពន្ធដារ និងគោរពថ្លែងអំណរគុណចំពោះឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ដែលបានផ្តល់កិច្ចសហការល្អ និងជ្រើសរើសវិទ្យាស្ថានខេមរអេដ ក្នុងការអនុវត្តការផ្លាស់ប្តូរក្រេឌីតសិក្សាជំនាញវិជ្ជាជីវៈពន្ធដារ សម្រាប់និស្សិត នៃវិទ្យាស្ថានខេមរអេដ និងសិក្ខាកាមដែលបានសិក្សាជំនាញវិជ្ជាជីវៈពន្ធដារនៅសាលាជាតិពន្ធដារ ក្នុងន័យចូលរួមក្នុងការពង្រឹងគុណភាពសិក្សារបស់និស្សិតលើជំនាញវិជ្ជាជីវៈពន្ធដារ។ បន្ថែមពីនេះលោក Casey Barnett បានលើកសរសើរ និងគាំទ្រយ៉ាងពេញទំហឹង អំពីការកែទម្រង់របស់អគ្គនាយកដ្ឋានពន្ធដាររួមមាន ការរៀបចំសៀវភៅណែនាំ ស្តីពីបែបបទ និងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារសម្រាប់មន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ និងសៀវភៅណែនាំ ស្តីពីការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ព្រមទាំងការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធដែលផ្តល់ ភាពងាយស្រួល និងអត្ថប្រយោជន៍ជូនអ្នកជាប់ពន្ធ និងសាធារណជនក្នុងន័យចូលរួមចំណែកគាំទ្រនូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជាឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០ ក្នុងការប្រែក្លាយខ្លួនជាប្រទេសដែលមានចំណូលកម្រិតខ្ពស់។ អនុស្សរណៈ

នៃការយោគយល់គ្នានេះ នឹងអនុញ្ញាតឱ្យនិស្សិត ឬសិក្ខាកាមដែលបានសិក្សា និងប្រឡងជាប់មុខវិជ្ជាពន្ធដារកម្ពុជា នៅវិទ្យាស្ថានខេមអេដ អាចផ្លាស់ប្តូរក្រេឌីតនៃមុខវិជ្ជានៅក្នុងវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈពន្ធដារ នៅសាលាជាតិពន្ធដារ និងសិក្ខាកាមដែលប្រឡងជាប់វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈពន្ធដារ អាចផ្លាស់ប្តូរក្រេឌីតនៅវិទ្យាស្ថានខេមអេដ ចៀសវាងការសិក្សាលើមុខវិជ្ជាដដែលៗ។ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី បានលើកឡើងអំពីការកែទម្រង់ស៊ីជម្រៅ របស់អគ្គនាយកដ្ឋានពន្ធដារលើគ្រប់ផ្នែក ជាពិសេសផ្នែកបច្ចេកវិទ្យាព័ត៌មាន ដែលចូលរួមក្នុងការពង្រឹងអភិបាលកិច្ច និងរដ្ឋបាលកិច្ចក្នុងវិស័យពន្ធដារ និងបានមានមតិផ្តាំផ្ញើដល់ប្អូនៗនិស្សិត ក្នុងការពង្រឹងសមត្ថភាព ដើម្បីបំពេញការងារពាក់ព័ន្ធនឹងពន្ធដារប្រកបដោយគុណភាព និងក្រមសីលធម៌វិជ្ជាជីវៈខ្ពស់៕



*លោក* **Casey Barnett**
*នាយកវិទ្យាស្ថាន ខេមអេដ* (CamEd)



*ឯកឧត្តម* ***គង់ វិបុល*** *រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ*








# ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា (MOU) ស្តីពីការផ្លាស់ប្តូរក្រេឌីតសិក្សាជំនាញវិជ្ជាជីវៈពន្ធដារ រវាងអគ្គនាយកដ្ឋានពន្ធដារ និងវិទ្យាស្ថាន វ៉ាន់ដា




ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា (MOU) ស្តីពីការផ្លាស់ប្តូរក្រេឌីតសិក្សាជំនាញវិជ្ជាជីវៈពន្ធដារ រវាងអគ្គនាយកដ្ឋានពន្ធដារ និងវិទ្យាស្ថានវ៉ាន់ដា នៅសាលាជាតិពន្ធដារនៃអគ្គនាយកដ្ឋានពន្ធដារ ត្រូវបានរៀបចំឡើង នាថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ និងឯកឧត្តម បណ្ឌិត **ហោង វ៉ាន់ដា** ប្រធានក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថាន វ៉ាន់ដា៕



# ការចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ប្រកាសស្តីពីការគ្រប់គ្រងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម និងការស្នើសុំអាជ្ញាបណ្ណតាមប្រព័ន្ធអនឡាញ"




នាព្រឹកថ្ងៃចន្ទ ទី២៩ ខែមេសា ឆ្នាំ២០២៤ លោក **ស៊ុន ឧត្តិ** នាយកសាលាជាតិពន្ធដារ តំណាងឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី **"ប្រកាសស្តីពីការគ្រប់គ្រងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម និងការស្នើសុំអាជ្ញាបណ្ណតាមប្រព័ន្ធអនឡាញ"** ក្រោមអធិបតីភាព ឯកឧត្តម **ឌុំ ថារិន** អគ្គនាយកនិយ័តករគណនេយ្យនិងសវនកម្ម នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញ ភូគីត្រា។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលបំណងបញ្ជ្រាបការយល់ដឹងឱ្យបានកាន់តែទូលំទូលាយនូវច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ជូនដល់ម្ចាស់អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្មភ្នាក់ងារសេវាកម្មពន្ធដារនិងសាធារណជនដើម្បីចៀសវាងមានទណ្ឌកម្មទោសទណ្ឌដូចមានចែងក្នុងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន និងដើម្បីបញ្ជ្រាបការយល់ដឹងដល់ភ្នាក់ងារសេវាកម្មពន្ធដារ អំពីបទប្បញ្ញត្តិ និងបែបបទ នីតិវិធី នៃការស្នើសុំអាជ្ញាបណ្ណពីនិយ័តករគណនេយ្យនិងសវនកម្ម ជាប្រយោជន៍ក្នុងការប្រកបវិជ្ជាជីវៈរបស់ខ្លួនអនុលោមតាមច្បាប់ ប្រកបដោយតម្លាភាព និងប្រសិទ្ធភាពខ្ពស់។

ក្នុងកម្មវិធីសិក្ខាសាលានេះ មានការធ្វើបទបង្ហាញនិងពិភាក្សាយ៉ាងផុសផុល តាមរយៈកម្មវិធីសំណួរ-ចម្លើយ និងប្រធានបទសំខាន់ៗចំនួន៣ រួមមាន ១.ប្រកាសស្តីពីការគ្រប់គ្រងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ២.ការចុះឈ្មោះជាសមាជិកភាពរបស់វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា និង៣.នីតិវិធីក្នុងការស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្មតាមប្រព័ន្ធអនឡាញ (E-License System)៕

# ៣. កិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន អង្គការ សមាគម និងស្ថាប័នអន្តរជាតិ

## កិច្ចប្រជុំជាមួយក្រុមហ៊ុន Heineken Cambodia ដើម្បីពិភាក្សាអំពីនិន្នាការឧស្សាហកម្ម និងវិធាននយោបាយ



នាព្រឹកថ្ងៃអង្គារ ទី៣០ ខែមេសា ឆ្នាំ២០២៤ នៅអគ្គនាយកដ្ឋានពន្ធដារ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានអញ្ជើញចូលរួមជាអធិបតីក្នុងកិច្ចប្រជុំជាមួយក្រុមហ៊ុន Heineken Cambodia ដើម្បីពិភាក្សាអំពីនិន្នាការឧស្សហកម្មនិងវិធាននយោបាយ៕







# សិក្ខាសាលាស្ដីពី "អនុសាសន៍គន្លឹះលើចក្ខុវិស័យផ្នែកពន្ធដារ"




ឯកឧត្តម ***កែន សម្បត្តិ*** ឯកឧត្តម ***គង់ វិបុល*** និងលោកបណ្ឌិត ***ព្រុំ វីរៈ*** *(រូបពីឆ្វេងទៅស្ដាំ)*

នារសៀលថ្ងៃពុធ ទី៨ ខែឧសភា ឆ្នាំ២០២៤ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានអញ្ជើញចូលរួមជាវាគ្មិនកិត្តិយសផ្ដល់អនុសាសន៍គន្លឹះលើចក្ខុវិស័យផ្នែកពន្ធដារ ក្នុងសិក្ខាសាលានៅវិទ្យាស្ថានខេមអេដ (CamEd Business School) ដោយមានការចូលរួមពីថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងលោកបណ្ឌិត **ព្រុំ វីរៈ** ប្រធានក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថាន CamEd លោក **Casey Barnett** នាយកវិទ្យាស្ថាន CamEd វត្តមានចូលរួមពីថ្នាក់ដឹកនាំ សាស្ត្រាចារ្យ បុគ្គលិក និងសិស្សនិស្សិតនៃវិទ្យាស្ថាន CamEd។

ក្នុងអនុសាសន៍គន្លឹះ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូ បានលើកឡើងថា អគ្គនាយកដ្ឋានពន្ធដារ បានកំណត់យកការបន្តធ្វើបរិវត្តកម្មឌីជីថលរដ្ឋបាលសារពើពន្ធ ជាគោលបំណងចម្បងមួយនៃផែនការយុទ្ធសាស្ត្ររបស់អគ្គនាយកដ្ឋានពន្ធដារ ក្នុងនោះការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានគឺជាផ្នែកមួយដ៏សំខាន់ក្នុងការពង្រឹងអភិបាលកិច្ច តាមរយៈការបង្កើតនិងដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធ កម្មវិធីបច្ចេកវិទ្យាព័ត៌មាននានា សំដៅជានាគ្រប់គ្រងប្រមូលចំណូលពន្ធ និងការផ្តល់សេវាអ្នកជាប់ពន្ធ ប្រកបដោយប្រសិទ្ធភាពខ្ពស់។ ជាមួយគ្នា ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ក៏បានលើកឡើងពីសារប្រយោជន៍នៃកម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ (GDTe-Administration) ព្រមទាំងអំពាវនាវឱ្យសាធារណជន និងអ្នកជាប់ពន្ធចូលរួមប្រើប្រាស់កម្មវិធីនេះឱ្យបានផុលផុស ដើម្បីសម្រួលដល់ការធ្វើធុរកិច្ចរបស់ខ្លួនឱ្យកាន់តែមានភាពងាយស្រួល មានប្រសិទ្ធភាពខ្ពស់ និងឆាប់រហ័សក្នុងការទំនាក់ទំនងជាមួយរដ្ឋបាលសារពើពន្ធ។

សូមបញ្ជាក់ថាចក្ខុវិស័យរបស់អគ្គនាយកដ្ឋានពន្ធដារ គឺប្រែក្លាយជា អង្គភាពសាធារណៈ ដែលត្រូវបានជឿជាក់ គោរព និងទទួលស្គាល់លើគុណភាពនិងជំនាញក្នុងការប្រមូលចំណូលពន្ធក្នុងស្រុក ដើម្បីចូលរួមអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព។ ការសម្រេចបាននូវកំណើនចំណូលពន្ធដារ ឬពន្ធផ្ទៃក្នុងកន្លងមក គឺអាស្រ័យដោយសារការលើកស្ទួយពង្រឹងវប្បធម៌និងកាតព្វកិច្ចបង់ពន្ធ តាមរយៈការអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍អភិបាលកិច្ចនិងរដ្ឋបាលកិច្ចល្អ ដែលទាំងនេះ គឺជាលទ្ធផលនៃការខិតខំធ្វើទំនើបកម្ម និងបរិវត្តកម្មដើម្បីប្រែក្លាយអគ្គនាយកដ្ឋានពន្ធដារទៅជារដ្ឋបាលសារពើពន្ធទំនើបទាន់សម័យ៕



លោក **Casey Barnett**
នាយកវិទ្យាស្ថាន ខេមអេដ (CamEd)



ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជា
ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ













# កិច្ចប្រជុំក្រុមការងាររវាងអគ្គនាយកដ្ឋានពន្ធដារ និងផ្នែកឯកជន



នាព្រឹកថ្ងៃសុក្រ ទី១៣ ខែឧសភា ឆ្នាំ២០២៤ ២០២៤ នៅអគ្គនាយកដ្ឋានពន្ធដារ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានអញ្ជើញចូលរួមជាអធិបតីក្នុងកិច្ចប្រជុំក្រុមការងាររវាងអគ្គនាយកដ្ឋានពន្ធដារ និងផ្នែកឯកជន តំណាងដោយឧកញ៉ា **សុខ ពិសិដ្ឋ**។










## កិច្ចប្រជុំជាមួយក្រុមហ៊ុន Total Energies Cambodia (TEMC)



នាព្រឹកថ្ងៃព្រហស្បតិ៍ ទី៣០ ខែឧសភា ឆ្នាំ២០២៤ នៅអគ្គនាយកដ្ឋានពន្ធដារ ឯកឧត្តម **គង់ ទិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានអញ្ជើញចូលរួមជាអធិបតីក្នុងកិច្ចប្រជុំជាមួយក្រុមហ៊ុន Total Energies Cambodia ( TEMC )៕







# ពិធីសម្ពោធជាផ្លូវការលើកិច្ចសហការ រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារ វីង (ខេមបូឌា) ម.ក




នាព្រឹកថ្ងៃពុធ ទី២៩ ខែឧសភា ឆ្នាំ២០២៤ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានអញ្ជើញចូលរួមជាអធិបតីក្នុងពិធីសម្ពោធជាផ្លូវការលើកិច្ចសហការរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារ វីង (ខេមបូឌា) ម.ក ស្តីពីការប្រើប្រាស់សេវាកម្ម របស់ធនាគារ វីង សម្រាប់ប្រតិបត្តិការទទួលប្រាក់ពន្ធអាករគ្រប់ប្រភេទដែលប្រមូលដោយអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងមានការចូលរួមពីថ្នាក់ដឹកនាំអគ្គនាយកដ្ឋានពន្ធដារ ថ្នាក់ដឹកនាំធនាគារ វីង និងមន្ត្រីពាក់ព័ន្ធផ្សេងៗទៀត។

គួរបញ្ជាក់ផងដែរថា បច្ចុប្បន្នធនាគារពាណិជ្ជដែលបានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការផ្តល់សេវាទទួលប្រាក់ពន្ធអាករដែលប្រមូលដោយអគ្គនាយកដ្ឋានពន្ធដារ រួមមាន ធនាគារ កាណាឌីយ៉ា, ធនាគារ អេស៊ីលីដា, ធនាគារ វឌ្ឍនៈ, ធនាគារ កម្ពុជាសាធារណៈ, ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់, ធនាគារ វឌ្ឍនៈ អាស៊ី ចំកាត់, ធនាគារ ប្រៃសណីយ៍កម្ពុជា, ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា, ធនាគារ ស្ថាបនា និងធនាគារ វីង ដោយអ្នកជាប់ពន្ធអាចអញ្ជើញទៅបង់ប្រាក់ពន្ធអាករនៅសាខាធនាគារទាំងនេះដែលនៅជិតបំផុត ឬ អាចបង់ប្រាក់ពន្ធអាករតាមរយៈប្រព័ន្ធអនឡាញe-Payment ឬកម្មវិធីទូរស័ព្ទដៃអ្នកជាប់ពន្ធ (GDT Taxpayer App)៕





## កិច្ចប្រជុំជួបជាមួយក្រុមហ៊ុន Smart Axiata



នាព្រឹកថ្ងៃអង្គារ ទី១៨ ខែមិថុនា ឆ្នាំ២០២៤ នៅអគ្គនាយកដ្ឋានពន្ធដារ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារបានអញ្ជើញចូលរួមជាអធិបតីក្នុងកិច្ចប្រជុំជាមួយ CEO របស់ក្រុមហ៊ុន Smart Axiata៕







# សន្និសីទពន្ធដារកម្រិតខ្ពស់ លើកទី១៣ នៃមូលនិធិរូបិយវត្ថុអន្តរជាតិ-ជប៉ុន សម្រាប់ប្រទេសក្នុងតំបន់អាស៊ី (The Thirteenth IMF-Japan High-Level Tax Conference for Asian Countries)



នាព្រឹកថ្ងៃព្រហស្បតិ៍ ទី២៥ ដល់ថ្ងៃសុក្រ ទី២៦ ខែមេសា ឆ្នាំ២០២៤ គណៈប្រតិភូក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដឹកនាំដោយលោក **សេខ ជាសិទ្ធ** ប្រធាននាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ អមដោយមន្ត្រីជំនាញនៃអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគោលនយោបាយនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានចូលរួមសន្និសីទពន្ធដារកម្រិតខ្ពស់ លើកទី១៣ នៃមូលនិធិរូបិយវត្ថុអន្តរជាតិ-ជប៉ុន សម្រាប់ប្រទេសក្នុងតំបន់អាស៊ី (The Thirteenth IMF-Japan High-Level Tax Conference for Asian Countries) ជាលក្ខណៈរូបវន្ត នៅទីក្រុងតូក្យូ ប្រទេសជប៉ុន។

សន្និសីទនេះត្រូវបានរៀបចំឡើងដោយរាជរដ្ឋាភិបាលជប៉ុន និងមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ដោយមានការចូលរួមពីថ្នាក់ដឹកនាំនិងជំនាញការនៃរដ្ឋបាលសារពើពន្ធ និងក្រសួងហិរញ្ញវត្ថុ នៃប្រទេស-តំបន់រដ្ឋបាលពិសេស ចំនួន ២១ នៅទ្វីបអាស៊ី ព្រមទាំងមានការចូលរួមពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងអង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ (OECD) ព្រមទាំងសាស្ត្រាចារ្យនៃសាកលវិទ្យាល័យ ដើម្បីពិភាក្សាលើខ្លឹមសារសំខាន់ៗនៃបញ្ហាប្រឈមផ្នែកពន្ធដែលកំពុងលេចឡើងជាសកល រួមមាន៖

- និន្នាការពន្ធដារនៅតំបន់អាស៊ី ដោយផ្តោតលើបញ្ហាប្រឈមក្នុងការប្រមូលចំណូល ស្របពេលដែលការចំណាយមានការកើនឡើង
- បញ្ហាពន្ធអន្តរជាតិ ដែលផ្តោតលើផលប៉ះពាល់និងគោលនយោបាយសារពើពន្ធក្នុងស្រុក ឆ្លើយតបទៅនឹងការអនុវត្តសសរស្តម្ភទី២ នៃក្របខ័ណ្ឌប្រកបដោយបរិយាបន្ន (Inclusive Framework) និងបញ្ហាប្រឈមចំពោះរដ្ឋបាលសារពើពន្ធអន្តរជាតិ
- ការប្រមូលពន្ធលើរូបវន្តបុគ្គលដែលមានចំណូលខ្ពស់ ដែលជាការឆ្លើយតបទៅនឹងការកើនឡើងនៃគម្លាតប្រាក់

ចំណូលរបស់បុគ្គល

- ការកំណត់តម្លៃកាបូនឆ្លើយតបទៅនឹងផលប៉ះពាល់ពីបម្រែបម្រួលអាកាសធាតុ មកលើកំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍជាសកល
- ការកសាងសមត្ថភាពជំនាញពន្ធដារ តាមរយៈអភិបាលកិច្ចនិងគណនេយ្យភាព ដែលផ្តោតលើបញ្ហាប្រឈមក្នុងការអនុវត្តគោលនយោបាយសារពើពន្ធ និងរដ្ឋបាលសារពើពន្ធ
- បច្ច័យនៃឌីជីថលូបនីយកម្មនិងបញ្ញាសិប្បនិម្មិត (AI)
- បញ្ហាប្រឈមនៃឌីជីថលូបនីយកម្មសម្រាប់រដ្ឋបាលសារពើពន្ធ។

ជាមួយគ្នានេះ គណៈប្រតិភូក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជាបានចូលរួមធ្វើបទបង្ហាញចំនួន ២ ស្តីពី៖ ១.ការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល ធ្វើបទបង្ហាញដោយមន្ត្រីជំនាញនៃអគ្គនាយកដ្ឋានគោលនយោបាយ និង២.ការកសាងសមត្ថភាពជំនាញពន្ធដារ តាមរយៈអភិបាលកិច្ចនិងគណនេយ្យភាព ធ្វើបទបង្ហាញដោយមន្ត្រីជំនាញនៃអគ្គនាយកដ្ឋានពន្ធដារ៕








# ទស្សនកិច្ចសិក្សាឈ្វេងយល់អំពីដំណើរការនៃការប្រើប្រាស់បច្ចេកវិទ្យាបោះពុម្ពកូដនៅបាតកំប៉ុង និងលើគម្របដបស្រាបៀរ និងភេសជ្ជៈគ្មានជាតិសុរា (Direct Coding System) នៅព្រះរាជាណាចក្រថៃ



តបតាមការអញ្ជើញរួមគ្នារបស់ក្រុមហ៊ុន SICPA TH និងក្រុមហ៊ុន SAMART ដែលជាសហគ្នាក់ងាររបស់នាយកដ្ឋានអាករពិសេសនៃព្រះរាជាណាចក្រថៃ នាថ្ងៃទី២៤ ដល់ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤ ឯកឧត្តម **លឹម ហ៊ុយឌីច** និងលោក **លឹម ជឹលុច** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានដឹកនាំគណៈប្រតិភូនៃអគ្គនាយកដ្ឋានពន្ធដារ ទៅទស្សនកិច្ចសិក្សាដើម្បីឈ្វេងយល់ពីការផ្គត់ផ្គង់ ដំឡើង ត្រួតពិនិត្យ និងថែទាំបច្ចេកវិទ្យាបោះពុម្ពកូដ ( Direct Coding System ) នៅបាតកំប៉ុង និងលើគម្របដបស្រាបៀរ និងភេសជ្ជៈគ្មានជាតិសុរា នៅតាមបណ្តារោងចក្រផលិតស្រាបៀរ និងភេសជ្ជៈគ្មានជាតិសុរា ក្នុងព្រះរាជាណាចក្រថៃ។

ក្នុងដំណើរទស្សនកិច្ចនេះ គណៈប្រតិភូនៃអគ្គនាយកដ្ឋានពន្ធដារ បានជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំនាយកដ្ឋានអាករពិសេសនៃព្រះរាជាណាចក្រថៃ លើវឌ្ឍនភាពនិងបច្ចុប្បន្នភាពនៃកម្មវិធីកំណែទម្រង់របស់នាយកដ្ឋានអាករពិសេសនៃព្រះរាជាណាចក្រថៃលើប្រព័ន្ធគ្រប់គ្រង និងមធ្យោបាយនៃការគ្រប់គ្រងការប្រមូលចំណូលអាករពិសេសស្របតាមការប្រែប្រួលឥតឈប់ឈរនៃនិន្នាការពិភពលោក ព្រមទាំងការកែសម្រួលគោលនយោបាយ និងគោលការណ៍ច្បាប់ បញ្ញាបច្ចេកទេស និងនីតិវិធីប្រតិបត្តិនានាជុំវិញការប្តូរពីការប្រើប្រាស់ប្រព័ន្ធ Flowmeter មកការប្រើប្រាស់បច្ចេកវិទ្យាបោះពុម្ពកូដ ( Direct Coding System )។ បន្ទាប់ពីកិច្ចពិភាក្សា គណៈប្រតិភូនៃអគ្គនាយកដ្ឋានពន្ធដារ បានអញ្ជើញចុះទៅពិនិត្យនិងសិក្សាឈ្វេងយល់អំពីការគ្រប់គ្រង ព្រមទាំងដំណើរប្រតិបត្តិការនៃបច្ចេកវិទ្យាបោះពុម្ពកូដនៅបាតកំប៉ុងនិងលើគម្របដបស្រាបៀរ និងភេសជ្ជៈគ្មានជាតិសុរា តាមបណ្តាខ្សែច្រវាក់ផលិតកម្មនៅទីតាំងរោងចក្រផលិតស្រាបៀរ Thai Asia Pacific ( Heineken ) និងទីតាំងរោងចក្រ Singha Brewery។

ក្នុងដំណើរទស្សនកិច្ចសិក្សាដ៏មានសារៈសំខាន់នេះ គណៈប្រតិភូនៃអគ្គនាយកដ្ឋានពន្ធដារ បានដកស្រង់បទពិសោធន៍ និងទិដ្ឋភាពទាំងស្រុងនៃការប្រើប្រាស់បច្ចេកវិទ្យាបោះពុម្ពកូដ (Direct Coding System) នៅបាតកំប៉ុង និងលើគម្របដបស្រាបៀរ និងភេសជ្ជៈគ្មានជាតិសុរាផលិតក្នុងស្រុក ដែលជាមធ្យោបាយដ៏ល្អប្រសើរសម្រាប់ការបង្កើនប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងតម្លាភាព នៃការគ្រប់គ្រងការប្រមូលចំណូលអាករពិសេសប្រកបដោយចីរភាព៕











# ទស្សនកិច្ចសិក្សារបស់គណៈប្រតិភូនៃអគ្គនាយកដ្ឋានពន្ធដារនៅសាធារណរដ្ឋកូរ៉េ ដើម្បីសិក្សាឈ្វេងយល់ពីការរៀបចំគំរូប្លង់ និងការរៀបចំដាក់ឱ្យដំណើរការសារមន្ទីរពន្ធដារជាតិ



នាថ្ងៃចន្ទទី២២ ដល់ថ្ងៃសុក្រ ទី២៦ ខែមេសា ឆ្នាំ២០២៤ លោក **ហ៊ឹម ម៉ុនធឿន** ប្រធាននាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានដឹកនាំគណៈប្រតិភូនៃអគ្គនាយកដ្ឋានពន្ធដារ ធ្វើទស្សនកិច្ចសិក្សានៅរដ្ឋបាលសារពើពន្ធនៃសាធារណរដ្ឋកូរ៉េ។

គោលបំណងចម្បងនៃដំណើរទស្សនកិច្ចនេះ ដើម្បីសិក្សាឈ្វេងយល់ពីការរៀបចំគំរូប្លង់ និងការរៀបចំដាក់ឱ្យដំណើរការសារមន្ទីរពន្ធដារជាតិ សម្រាប់ជាបទពិសោធន៍ក្នុងការរៀបចំផែនការនៃការរៀបចំសារមន្ទីរជាតិពន្ធដារ នៃអគ្គនាយកដ្ឋានពន្ធដារ។ ក្នុងដំណើរទស្សនកិច្ចនេះ គណៈប្រតិភូនៃអគ្គនាយកដ្ឋានពន្ធដារ ត្រូវបានទទួលស្វាគមន៍ដោយថ្នាក់ដឹកនាំរដ្ឋបាលសារពើពន្ធនៃសាធារណរដ្ឋកូរ៉េ និងបានទៅទស្សនកិច្ចផ្ទាល់នៅសារមន្ទីរជាច្រើនរួមមាន៖ ១.សារមន្ទីរពន្ធដារជាតិនៃសាធារណរដ្ឋកូរ៉េ (National Tax Museum of Korea) ២.សារមន្ទីរជាតិកូរ៉េ (National Museum of Korea) ៣.សារមន្ទីរប្រធានាធិបតី (Presidential Archives) ៤.សារមន្ទីរជាតិកុងជូ (Gongju National Museum) ៥.សារមន្ទីរជាតិ Buyeo (Buyeo National Museum) និង៦.សាលពិព័រណ៍រដ្ឋាភិបាលឌីជីថល (Digital Government Exhibition Hall)។

ក្នុងដំណើរបេសកកម្មដែលមានរយៈពេល៥ថ្ងៃ របស់គណៈប្រតិភូនៃអគ្គនាយកដ្ឋានពន្ធដារ ទទួលបាននូវចំណេះដឹង គំនិតច្នៃប្រឌិតថ្មីៗ បទពិសោធន៍ល្អៗ សម្រាប់ជាមូលដ្ឋានក្នុងការរៀបចំគំរូប្លង់និងការរៀបចំដាក់ឱ្យដំណើរការសារមន្ទីរជាតិពន្ធដារ នៃអគ្គនាយកដ្ឋានពន្ធដារ។










기획전시실
Special Exhibition Hall




National Tax Museum of Korea

# វេទិកាស្ដីពី "ការឈ្វេងយល់អំពីដំណើរវិវត្តន៍នៃទិដ្ឋភាពពន្ធដារក្នុងព្រះរាជាណាចក្រកម្ពុជា"




នាព្រឹកថ្ងៃព្រហស្បតិ៍ ទី៣០ ខែឧសភា ឆ្នាំ២០២៤ នៅសណ្ឋាគារ Hyatt Regency Phnom Penh លោកជំទាវ **ម៉ុន នារី** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ បានចូលរួមជាវាគ្មិនកិត្តិយសក្នុងវេទិកាស្ដីពី "ការឈ្វេងយល់អំពីដំណើរវិវត្តន៍នៃទិដ្ឋភាពពន្ធដារក្នុងព្រះរាជាណាចក្រកម្ពុជា Navigating The evolving Tax Landscape in Cambodia" រៀបចំដោយក្រុមហ៊ុន ឌីអេហ្វឌីអិល មេគង្គ។ វេទិកានេះមានវត្តមានចូលរួមពីលោក CLINT O'CONNELL Partner Managing Director and Head of Cambodia Tax and Accounting Practice នៃក្រុមហ៊ុន DFDL ព្រមទាំងថ្នាក់ដឹកនាំនិងមន្ត្រីជំនាញពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ និងតំណាងសហគ្រាស វិនិយោគិនក្នុងស្រុក និងក្រៅស្រុក ប្រមាណជាង ៣០០ នាក់។

ថ្លែងក្នុងសុន្ទរកថាគន្លឹះ លោកជំទាវ **ម៉ុន នារី** បានលើកឡើងពីវឌ្ឍនភាពថ្មីនៃទិដ្ឋភាពពន្ធដារក្នុងព្រះរាជាណាចក្រកម្ពុជាដូចខាងក្រោម៖

- យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ គឺជាមូលដ្ឋានគ្រឹះមួយដើម្បីសម្រេចបាននូវចក្ខុវិស័យរបស់កម្ពុជាឆ្នាំ២០៥០ជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់។ យុទ្ធសាស្ត្រនេះ គឺផ្ដោតលើការធានានូវប្រសិទ្ធភាពនៃការអនុវត្តតាមរយៈការពង្រឹងអភិបាលកិច្ចល្អ និងប្រព័ន្ធថាមវន្តនៃភាគីពាក់ព័ន្ធ ដែលជាក្របខ័ណ្ឌគោលនយោបាយមុតស្រួចលើកកម្ពស់ការប្រកួតប្រជែង បង្កើនពិពិធកម្ម និងការបង្កើនភាពធន់សម្រាប់កំណើនសេដ្ឋកិច្ច
- វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៩ បានដាក់ចេញនូវវិធានការពន្ធដារសំខាន់ៗ ដើម្បីដោះស្រាយនូវកង្វល់ សម្រួលធុរកិច្ច និងការប្រកួតប្រជែង ដោយបន្តផ្ដល់ការលើកទឹកចិត្តដែលមានជាធរមាន ការលើកទឹកចិត្តបន្ថែមចំពោះវិស័យ និងសកម្មភាពគន្លឹះមួយចំនួន
- អគ្គនាយកដ្ឋានពន្ធដារ បាននិងកំពុងកែសម្រួលលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដើម្បីធ្វើឱ្យមានសង្គតិភាព ភាពច្បាស់លាស់ និងងាយស្រួលអនុវត្ត ក្នុងនោះលិខិតបទដ្ឋានគតិយុត្តចំនួន ៣១ បាននិងកំពុងរៀបចំ និងដាក់ឱ្យអនុវត្តជាបន្តបន្ទាប់

- អគ្គនាយកដ្ឋានពន្ធដារ បានដាក់ឱ្យអនុវត្តកម្មវិធី GDT e-Administration ដែលនឹងរួមចំណែកប្រកបដោយប្រសិទ្ធភាពដល់ការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ និងពង្រឹងអភិបាលកិច្ចល្អ
- ចំពោះទិដ្ឋភាពអន្តរជាតិនៃគោលនយោបាយពន្ធដារ រាជរដ្ឋាភិបាលបានខិតខំសម្រេចឱ្យបាននូវការប្តេជ្ញាចិត្តរបស់ខ្លួនជាមួយបណ្តាប្រទេសអាស៊ាន ក៏ដូចជាសហគមន៍អន្តរជាតិ ដោយពង្រីកបណ្តាញកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា (DTA)៕













# ៤. កិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា (Double Taxation Agreement-DTA)

## កិច្ចប្រជុំចរចាលើកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា (Double Taxation Agreement-DTA) ជុំទី២ ជាមួយសាធារណរដ្ឋបារាំង



នាថ្ងៃអង្គារ ទី២៣ ដល់ថ្ងៃព្រហស្បតិ៍ ទី២៥ ខែមេសា ឆ្នាំ២០២៤ គណៈប្រតិភូនៃអគ្គនាយកដ្ឋានពន្ធដារ ដឹកនាំដោយ លោកជំទាវ **ម៉ុន នារី** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រី ប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានចូលរួម កិច្ចប្រជុំចរចាលើកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា (Double Taxation Agreement-DTA) ជុំទី២ នៅទីក្រុងបារីស រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋបារាំង ដែលមានគណៈប្រតិភូនៃសាធារណរដ្ឋបារាំង ក្នុងនាមជាម្ចាស់ផ្ទះ ដឹកនាំដោយ លោក Florian De Filippo ប្រធានអង្គភាពសន្ធិសញ្ញាពន្ធ (Head of Tax Treaty Unit) នៃក្រសួងហិរញ្ញវត្ថុ នៃសាធារណរដ្ឋបារាំង។

កិច្ចប្រជុំចរចាលើកទី២ ត្រូវបានរៀបចំឡើងតបតាមការអញ្ជើញរបស់ក្រសួងហិរញ្ញវត្ថុបារាំង ដើម្បីបន្តពិភាក្សាលម្អិត លើកិច្ចព្រមព្រៀង DTA រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋបារាំង។ បន្ទាប់ពីបានចាប់ផ្តើមកិច្ចចរចាទៅ តាមរបៀបវារៈដែលបានគ្រោងទុក ភាគីទាំងពីរបានផ្តល់ភាពទន់ភ្លន់ឱ្យគ្នាទៅវិញទៅមក ក្នុងស្មារតី ទទួលខុសត្រូវ ខ្ពស់ និងជាលទ្ធផល បានដោះស្រាយបញ្ហាដែលនៅសេសសល់ជាច្រើន ដោយមានមាត្រា និងចំណុចមួយចំនួនធំនៃ កិច្ចព្រមព្រៀង ត្រូវបានឯកភាពទាំងស្រុង។ សម្រាប់មាត្រា និងចំណុចដែលពុំទាន់បានឯកភាពគ្នា ភាគីទាំងពីរនឹងបន្ត ការចរចាដើម្បីឈានទៅបញ្ចប់ការចរចាទាំងស្រុងឱ្យបានឆាប់។



*លោកជំទាវ **ប៊ុន នារី***
*អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ*



*លោក Florian De Filippo ប្រធានអង្គភាពសន្ធិសញ្ញាពន្ធ*
*នៃក្រសួងហិរញ្ញវត្ថុ នៃសាធារណរដ្ឋបារាំង*











# កិច្ចប្រជុំចរចាលើកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា (Double Taxation Agreement-DTA) ជុំទី៣ ជាមួយសាធារណរដ្ឋហ្វីលីពីន



នាព្រឹកថ្ងៃពុធ ទី១៧ ដល់ថ្ងៃសុក្រ ទី១៩ ខែមេសា ឆ្នាំ២០២៤ គណៈប្រតិភូនៃអគ្គនាយកដ្ឋានពន្ធដារ ដឹកនាំដោយលោក **សេង ជាសិទ្ធ** ប្រធាននាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានចូលរួមកិច្ចប្រជុំចរចាកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា ( Double Taxation Agreement- DTA ) ជុំទី៣ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋហ្វីលីពីន នៅរដ្ឋធានីម៉ានីល សាធារណរដ្ឋហ្វីលីពីន។ គណៈប្រតិភូនៃសាធារណរដ្ឋហ្វីលីពីនដែលចូលរួមកិច្ចចរចានេះក្នុងនាមម្ចាស់ផ្ទះ ដឹកនាំដោយលោក Dakila Elteen M. Napao ឧបការីរដ្ឋមន្ត្រីនៃក្រសួងហិរញ្ញវត្ថុហ្វីលីពីន និងមានការចូលរួមជា អធិបតី និងថ្លែងសុន្ទរកថាបើកកិច្ចប្រជុំដោយ ឯកឧត្តម Gerald Alan A. Quebal អនុរដ្ឋមន្ត្រីនៃក្រសួងហិរញ្ញវត្ថុហ្វីលីពីន។

បន្ទាប់ពីភាគីទាំងពីរបានស្តាប់សេចក្តីរាយការណ៍ដោយសង្ខេបអំពីលទ្ធផលនៃការចរចាជុំទី១ និងជុំទី២ ភាគីទាំងពីរបានចាប់ដំណើរការកិច្ចចរចាទៅតាមរបៀបវារៈដែលបានគ្រោងទុក ក្នុងនោះ គ្រប់ចំណុចសេសសល់ដែលពុំទាន់ឯកភាពក្នុងជុំទី១ និងទី២ កន្លងមកត្រូវបានបន្តលើកយកមកពិភាក្សាលម្អិត និងបានពិនិត្យនិងពិភាក្សាបន្ថែមលើចំណុចដែលភាគីហ្វីលីពីនស្នើសុំធ្វើបច្ចុប្បន្នភាពតាមគំរូកិច្ចព្រមព្រៀង DTA របស់ខ្លួនផងដែរ ហើយជាលទ្ធផលនៃកិច្ចចរចាជុំទី៣នេះ មាត្រាទាំងអស់នៃកិច្ចព្រមព្រៀង DTA ត្រូវបានឯកភាពគ្នាទាំងស្រុង៕













# ផ្នែកទី៥

# ការផ្សព្វផ្សាយ និងបញ្ជ្រាបវប្បធម៌បង់ពន្ធ

១. កិច្ចការបណ្តុះបណ្តាល និងសិក្ខាសាលារបស់សាលាជាតិពន្ធដារ

២. ការស្រាវជ្រាវ អភិវឌ្ឍន៍កម្មវិធី និងបណ្ណាល័យ

៣. សិក្ខាសាលាសំខាន់ៗ

# ការផ្សព្វផ្សាយ និងបញ្ជ្រាបវប្បធម៌បង់ពន្ធ

ក្នុងគោលដៅពង្រឹងការយល់ដឹងអំពីពន្ធដារ ពាក់ព័ន្ធនឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ការធ្វើទំនើបកម្មពន្ធដារ និងវឌ្ឍនភាពថ្មីៗ ជាពិសេសពាក់ព័ន្ធការផ្តល់សេវាអ្នកជាប់ពន្ធ ក្នុងខែមិថុនា ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយនិងវគ្គបណ្តុះបណ្តាលចំនួន **៦៤ លើក** មានសិក្ខាកាមចូលរួមចំនួន **៧ ២៣៣ រូប** ក្នុងនោះ វគ្គបណ្តុះបណ្តាលចំនួន **២៥ លើក** មានសិក្ខាកាមចូលរួមចំនួន **៤ ៦៣២ រូប** និងសិក្ខាសាលាចំនួន **៣៩ លើក** មានសិក្ខាកាមចូលរួមចំនួន **២ ៦០១ រូប**។

សរុបរយៈពេល ៦ខែដើមឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយនិងវគ្គបណ្តុះបណ្តាលចំនួន **៤០០ លើក** មានសិក្ខាកាមចូលរួមចំនួន **៥៦ ១៧៣ រូប** ក្នុងនោះវគ្គបណ្តុះបណ្តាលចំនួន **១២៦ លើក** មានសិក្ខាកាមចូលរួមចំនួន **២៨ ៧២៨ រូប** និងសិក្ខាសាលាចំនួន **២៧៤ លើក** មានសិក្ខាកាមចូលរួមចំនួន **២៧ ៤៤៥ រូប**៕

**របាយការណ៍ ស្តីពីការរៀបចំវគ្គបណ្តុះបណ្តាលនិងសិក្ខាសាលា ក្នុងរយៈពេល ៦ខែដើមឆ្នាំ២០២៤**

| បរិយាយ | ចំនួនដង ក្នុងខែមេសា | ចំនួនសិក្ខាកាម ក្នុងខែមេសា | ចំនួនដង ក្នុងខែឧសភា | ចំនួនសិក្ខាកាម ក្នុងខែឧសភា | ចំនួនដង ក្នុងខែមិថុនា | ចំនួនសិក្ខាកាម ក្នុងខែមិថុនា | ចំនួនដង រយៈពេល៦ខែ | ចំនួនសិក្ខាកាម រយៈពេល៦ខែ |
|---|---|---|---|---|---|---|---|---|
| **I.វគ្គបណ្តុះបណ្តាល** | | | | | | | | |
| មន្ត្រីធនាគារដៃគូ | ០០ | ០០ | ០៨ | ១ ៧៧៦ | ០០ | ០០ | ២៤ | ៩ ០០០ |
| មន្ត្រីរាជការពន្ធដារ | ១៧ | ២ ៥៧៧ | ០៧ | ៨៧៧ | ២៥ | ៤ ៦៣២ | ១០២ | ១៩ ៧២៨ |
| អ្នកជាប់ពន្ធ | ០០ | ០០ | ០០ | ០០ | ០០ | ០០ | ០០ | ០០ |
| **សរុបវគ្គបណ្តុះបណ្តាល** | **១៧** | **២ ៥៧៧** | **១៥** | **២ ៦៥៣** | **២៥** | **៤ ៦៣២** | **១២៦** | **២៨ ៧២៨** |
| **II.សិក្ខាសាលា** | | | | | | | | |
| អ្នកជាប់ពន្ធ | ០៤ | ២៨០ | ២២ | ១ ៦១៤ | ៣០ | ១ ៨៤២ | ១៩០ | ១៧ ០៩៥ |
| មន្ត្រីរាជការពន្ធដារ | ០០ | ០០ | ២៥ | ៦ ៦០៥ | ០៥ | ៤៥៣ | ៥៩ | ៨ ១៦៩ |
| សិស្ស-និស្សិត | ០០ | ០០ | ០១ | ២០០ | ០០ | ៣០៦ | ០១ | ២០០ |
| សាធារណជន | ០៥ | ៣៩៣ | ០៧ | ៦០៦ | ០៤ | ០០ | ២៤ | ១ ៩៨១ |
| មន្ត្រីធនាគារដៃគូ | ០០ | ០០ | ០០ | ០០ | ០០ | ០០ | ០០ | ០០ |
| **សរុបសិក្ខាសាលា** | **០៩** | **៦៧៣** | **៥៥** | **៩ ០២៥** | **៣៩** | **២ ៦០១** | **២៧៤** | **២៧ ៤៤៥** |
| **សរុបរួម** (I+II) | ២៦ | ៣ ២៥០ | ៧០ | ១១ ៦៧៨ | ៦៤ | ៧ ២៣៣ | ៤០០ | ៥៦ ១៧៣ |





# ១.កិច្ចការបណ្ដុះបណ្ដាល និងសិក្ខាសាលារបស់សាលាជាតិពន្ធដារ

## វគ្គបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈពន្ធដារ

ក្នុងត្រីមាសទី២ ឆ្នាំ២០២៤ នេះ សាលាជាតិពន្ធដារនៃអគ្គនាយកដ្ឋានពន្ធដារ បានបន្តបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈពន្ធដារជំនាន់ទី១៨ ជូនសិក្ខាកាមដែលបានចុះឈ្មោះចូលរៀន ចំនួន **៥២ ក្រុម** សរុបចំនួន **៩០៧ នាក់**៕



## វគ្គបណ្ដុះបណ្ដាលខ្លីៗសម្រាប់អ្នកជាប់ពន្ធ និងសាធារណជនទូទៅ

ស្របតាមផែនការប្រតិបត្តិឆ្នាំ២០២៤ របស់សាលាជាតិពន្ធដារ នៅក្នុងត្រីមាសទី២ នេះ សាលាជាតិពន្ធដារបានបន្តបើកវគ្គបណ្ដុះបណ្ដាលខ្លីៗសរុបចំនួន **៥ ក្រុម** ដែលមានសិក្ខាកាមចុះឈ្មោះសិក្សាចំនួន **១៦២ នាក់**។



## សិក្ខាសាលាជូនភ្នាក់ងារសេវាកម្មពន្ធដារ អ្នកជាប់ពន្ធ និងសាធារណជនទូទៅ

ក្នុងត្រីមាសទី២ នេះសាលាជាតិពន្ធដារបានសហការជាមួយបណ្ដាសាខាពន្ធដារខណ្ឌ ខេត្ត ចំនួន **១១** ក្នុងការរៀបចំសិក្ខាសាលាជូនភ្នាក់ងារសេវាកម្មពន្ធដារ និងអ្នកជាប់ពន្ធ ចំនួន **៤ លើក** នៅថ្ងៃទី២៨ ខែឧសភា និងថ្ងៃទី១១ ១៩ ២៦ ខែមិថុនា ឆ្នាំ២០២៤ ក្រោមប្រធានបទ "**ការប្រើប្រាស់សេវាកម្មពាក់ព័ន្ធនឹងពន្ធដារពីសហគ្រាសភ្នាក់ងារសេវាកម្មពន្ធដារ កម្មវិធីសម្រាប់បង់ប្រាក់ពន្ធតាមអនឡាញ (GD Taxpayer App) លើមុខងារបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងពន្ធលើអចលនទ្រព្យ កម្មវិធីទូរស័ព្ទដៃសម្រាប់ត្រួតពិនិត្យ និងតាមដានឯកសារ (GDT Check & Track App) និងកម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw App)**" តាមអនឡាញ ក្រោមអធិបតីភាពលោកស្រី **ឆាយ៉ា ឆព័ណ្ណា** នាយករងសាលាជាតិពន្ធដារ និងជាតំណាងរបស់ថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានការចូលរួមផងដែរពីថ្នាក់ដឹកនាំ និងមន្ត្រីនៃសាលាជាតិពន្ធដារ ព្រមទាំងអ្នកជាប់ពន្ធ និងភ្នាក់ងារសេវាកម្មពន្ធដារ សរុបចំនួន **៤៦៣** នាក់៕



# ២.ការស្រាវជ្រាវ អភិវឌ្ឍន៍កម្មវិធី និងបណ្ណាល័យ

## ការផ្ដល់សេវាបណ្ណាល័យសាលាជាតិពន្ធដារ

នៅក្នុងត្រីមាសទី២ ឆ្នាំ២០២៤ សាលាជាតិពន្ធដារបានផ្ដល់សេវាបណ្ណាល័យរួមមាន៖ ការចូលអាន ការខ្ចី និងការទទួលសងសៀវភៅ និងឯកសារផ្សេងៗ ជូនដល់មន្ត្រីរាជការ សិក្ខាកាម សិស្ស-និស្សិត និងសាធារណជនទូទៅ បានចំនួន **៦០ នាក់** (ស្រីចំនួន ១៩ នាក់)។ ក្រៅពីការងារផ្ដល់សេវាទាំងនេះ សាលាជាតិពន្ធដារក៏បានខិតខំស្រាវជ្រាវប្រមូល និងបានទទួលសៀវភៅថ្មីៗពាក់ព័ន្ធច្បាប់និងលិខិតបទដ្ឋានគតិយុត្តពីអគ្គនាយកដ្ឋានពន្ធដារ និងស្ថាប័នផ្សេងៗ បានចំនួន ១៣១ ក្បាល បន្ថែមទៀត ដើម្បីបំពេញការខ្វះខាត ក៏ដូចជាតម្រូវការរបស់អ្នកអាន បន្ថែមលើឯកសារដែលមានស្រាប់ផងដែរ។ គិតមកដល់បច្ចុប្បន្ន បណ្ណាល័យសាលាជាតិពន្ធដាររក្សាទុកសៀវភៅ ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងឯកសារសំខាន់ៗផ្សេងៗទៀត ជាច្រើនសរុបចំនួន **៧ ៤៧៨ ក្បាល** ក្នុងនោះឯកសាររឹងមានចំនួន **៥ ៥៥៤ ឯកសារ** និងឯកសារទន់មានចំនួន **១ ៩២៤ ឯកសារ**។

### ក. ការងារស្រាវជ្រាវប្រមូលឯកសារ និងរក្សាទុកឯកសារ

ក្នុងត្រីមាសទី២ ឆ្នាំ២០២៤ ការិយាល័យស្រាវជ្រាវ អភិវឌ្ឍន៍កម្មវិធី និងបណ្ណាល័យ បានស្រាវជ្រាវ និងប្រមូលឯកសារសម្រាប់រក្សាទុកក្នុងបណ្ណាល័យសរុប **១៣១ ឯកសារ** ក្នុងនោះរួមមាន៖

| **បរិយាយ** | **ប្រភេទ** | | **ចំនួន** |
|---|---|---|---|
| | **Hard Copy** | **Soft Copy** | |
| ចំណេះដឹងវិស័យពន្ធដារ | ៥៨ | ៦២ | ១២០ |
| ផ្សេងៗ | ១១ | ០ | ១១ |
| សរុបឯកសារត្រឹមត្រីមាសទី២ ឆ្នាំ២០២៤ | ៦៩ | ៦២ | ១៣១ |

### ខ. ការងារគ្រប់គ្រងអ្នកមកទទួលសេវាពីបណ្ណាល័យ

ក្នុងត្រីមាសទី២ ឆ្នាំ២០២៤ ការិយាល័យស្រាវជ្រាវ អភិវឌ្ឍន៍កម្មវិធី និងបណ្ណាល័យ បានកត់ត្រានូវចំនួនអ្នកមកទទួលសេវាពីបណ្ណាល័យ (អាន ខ្ចី/សង និងទទួលយកឯកសារ) **១៣៤ នាក់** ក្នុងនោះ៖

| **បរិយាយ** | **ប្រភេទ** | | **ចំនួន** |
|---|---|---|---|
| | **ប្រុស** | **ស្រី** | |
| ចំនួនអ្នកចូលអានសៀវភៅ/ឯកសារ ក្នុងបណ្ណាល័យ | ៣២ | ៥ | ៣៧ |
| ចំនួនអ្នកចូលខ្ចី/សង សៀវភៅ/ឯកសារ ពីបណ្ណាល័យ | ៣៧ | ២១ | ៥៨ |
| ចំនួនអ្នកទទួលយកឯកសារ ពីបណ្ណាល័យ | ១៨ | ២១ | ៣៩ |
| សរុប | ៨៧ | ៤៧ | ១៣៤ |

### គ. ការងារគ្រប់គ្រង ខ្ចី/សង សៀវភៅក្នុងបណ្ណាល័យ

ក្នុងត្រីមាសទី២ ឆ្នាំ២០២៤ ការិយាល័យស្រាវជ្រាវ អភិវឌ្ឍន៍កម្មវិធី និងបណ្ណាល័យ បានកត់ត្រានូវចំនួនសៀវភៅ ខ្ចី/សង ក្នុងបណ្ណាល័យដូចខាងក្រោម៖

| **បរិយាយ** | **ខ្ចី** | **សង** |
|---|---|---|
| ផ្តល់ជូនមន្ត្រីរាជការពន្ធដារ | ៩ | ៩ |
| ផ្តល់ជូនមន្ត្រីកិច្ចសន្យានៃអគ្គនាយកដ្ឋានពន្ធដារ | ១៨ | ១៨ |
| ផ្តល់ជូនសាធារណជនទូទៅ | ៨៧ | ៨៧ |
| សរុប | ១១៤ | ១១៤ |

# ៣.សិក្ខាសាលាសំខាន់ៗ

## សិក្ខាសាលាស្តីពី "សិទ្ធិនិងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ និង ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មតាមអនឡាញ (e-Filing)"




នាព្រឹកថ្ងៃព្រហស្បតិ៍ ទី១៦ ខែឧសភា ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារ បានរៀបចំសិក្ខាសាលាស្តីពី "សិទ្ធិនិងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ និងប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មតាមអនឡាញ (e-Filing)" សម្រាប់សហគ្រាស អ្នកជាប់ពន្ធមធ្យម ដែលបានចុះបញ្ជីពន្ធដារថ្មីៗ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់សាខាពន្ធដារខណ្ឌចំការមន ពោធិ៍សែនជ័យ ដង្កោ ៧មករា និងមានជ័យ ក្រោមអធិបតីភាពរបស់ឯកឧត្តម **ហេង សុខណាង** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានការចូលរួមពីថ្នាក់ដឹកនាំនិងមន្ត្រីរាជការពន្ធដារពាក់ព័ន្ធ តំណាងមកពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានគោលនយោបាយនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ សម្ព័ន្ធសមាគមសហគ្រាសធុនតូចនិងមធ្យមកម្ពុជា និងផ្នែកឯកជន ព្រមទាំងអភិបាល បណ្ណាធិការ តំណាងសហគ្រាស សរុបចំនួន ២៥១ នាក់។ សិក្ខាសាលានេះ មានការធ្វើបទបង្ហាញលើប្រធានបទសំខាន់ៗចំនួន ៣ រួមមាន "សិទ្ធិនិងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ" "ការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ" និង "ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធអាជីវកម្មតាមអនឡាញ (e-Filing)" ។

ក្នុងសុន្ទរកថាបើកសិក្ខាសាលា ឯកឧត្តម **ហេង សុខណាង** បានវាយតម្លៃខ្ពស់ចំពោះវត្តមានរបស់គ្រប់ភាគីពាក់ព័ន្ធដែលបានចូលរួមក្នុងសិក្ខាសាលាដ៏មានសារៈសំខាន់នេះ ជាការឆ្លុះបញ្ចាំងឱ្យឃើញពីការយកចិត្តទុកដាក់ខ្ពស់ក្នុងការគោរពប្រតិបត្តិច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ដើម្បីឈ្វេងយល់ឱ្យបានកាន់តែស៊ីជម្រៅថែមទៀត ចំពោះសិទ្ធិរបស់អ្នកជាប់ពន្ធដែលត្រូវទទួលបាន និងកាតព្វកិច្ចសារពើពន្ធដែលអ្នកជាប់ពន្ធត្រូវអនុវត្តក្នុងការប្រកាស និងបង់ប្រាក់ពន្ធសម្រាប់សកម្មភាពអាជីវកម្មរបស់ខ្លួន។ ឯកឧត្តមអគ្គនាយករង ក៏បានលើកឡើងអំពីសារៈសំខាន់ និងភាពងាយស្រួលក្នុងការប្រើប្រាស់ប្រព័ន្ធនិងកម្មវិធីបច្ចេកវិទ្យាព័ត៌មានរបស់អគ្គនាយកដ្ឋានពន្ធដារ ពិសេសប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មតាមអនឡាញ (e-Filing) ដែលជំនួសឱ្យការដាក់លិខិតប្រកាសពន្ធដោយដៃ ប៉ុន្តែទាមទារឱ្យអ្នកជាប់ពន្ធសិក្សាឈ្វេងយល់អំពីការប្រើប្រាស់ប្រព័ន្ធនេះឱ្យបានច្បាស់លាស់៕

# សិក្ខាសាលាតាមខេត្ត-ខណ្ឌ

នាថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តកណ្ដាល** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្ដីពី "អាករលើតម្លៃបន្ថែមចំពោះប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (e-Commerce) និងកម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw App)" សម្រាប់អ្នកជាប់ពន្ធដែលជាតំណាងសហគ្រាសចំនួន**៦៩រូប**ក្រោមអធិបតីភាព លោក **ខួន សុវណ្ណា** ប្រធានសាខាពន្ធដារខេត្តកណ្ដាល។



នាថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៤ នៅ**សាខាពន្ធដារខេត្តកំពង់ស្ពឺ** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្ដីពី "ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធអាជីវកម្មតាមអនឡាញ (e-Filing) និងវិធាននៃការប្រើប្រាស់វិក្កយបត្រ" សម្រាប់អ្នកជាប់ពន្ធដែលជាតំណាងសហគ្រាស ចំនួន **៥០ រូប** ក្រោមអធិបតីភាព លោក **គង់ សុគន្ធ** អនុប្រធានសាខាពន្ធដារខេត្តកំពង់ស្ពឺ។



នាថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខណ្ឌមានជ័យ** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្ដីពី "ពន្ធលើអចលនទ្រព្យ ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ និងពន្ធលើចំណេញមូលធន" ជូនដល់មេភូមិ ចំនួន **៦១ រូប** ចំណុះរដ្ឋបាលខណ្ឌមានជ័យ ក្រោមអធិបតីភាព លោកស្រី **គាន រ៉ាមី** ប្រធានសាខាពន្ធដារខណ្ឌមានជ័យ។



នាថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តប៉ៃលិន** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្ដីពី "កម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ (GDT e-Administration) កម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw) និងកម្មវិធីតាមដាននិងត្រួតពិនិត្យឯកសារ (GDT Check & Track App)" សម្រាប់អ្នកជាប់ពន្ធដែលជាតំណាងសហគ្រាស ចំនួន **៧៩ រូប** ក្រោមអធិបតីភាព លោក **ផាវឌី ណារិន** ប្រធានសាខាពន្ធដារខេត្តប៉ៃលិន។



នាថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តពោធិ៍សាត់** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "កម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ(GDT e-Administration) និងប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មតាមអនឡាញ(e-Filing) លើមុខងារស្នើសុំកែតម្រូវលិខិតប្រកាសសារពើពន្ធ" សម្រាប់អ្នកជាប់ពន្ធដែលជាតំណាងសហគ្រាស ចំនួន **៣០ រូប** ក្រោមអធិបតីភាព លោក **ម៉ា សំអាត** ប្រធានសាខាពន្ធដារខេត្តពោធិ៍សាត់៕



នាថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តឧត្តរមានជ័យ** មានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "ការស្នើសុំកែតម្រូវលិខិតប្រកាសពន្ធប្រចាំខែនិងលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ ពន្ធលើផ្ទាំងផ្សព្វផ្សាយ និងកម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw App)" សម្រាប់អ្នកជាប់ពន្ធ ចំនួន **៥០ រូប** ក្រោមអធិបតីភាព លោក **ជុំ សំនិត** ប្រធានសាខាពន្ធដារខេត្តឧត្តរមានជ័យ៕



នាថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តត្បូងឃ្មុំ** មានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ពន្ធលើអចលនទ្រព្យនិងពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ" សម្រាប់អ្នកជាប់ពន្ធ ចំនួន **២៨ រូប** ក្រោមអធិបតីភាព លោក **ឡុង កុសល** អនុប្រធានសាខាពន្ធដារខេត្តត្បូងឃ្មុំ៕



នាថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តស្ទឹងត្រែង** មានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "សិទ្ធិនិងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធពាក់ព័ន្ធនឹងការធ្វើសវនកម្ម វិធាននៃការប្រើប្រាស់វិក្កយបត្រ និងកម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ (GDT e-Administration)" សម្រាប់អ្នកជាប់ពន្ធ ក្រោមអធិបតីភាព លោកស្រី **ស៊ើយ សុម៉ាលី** អនុប្រធានសាខាពន្ធដារខេត្តស្ទឹងត្រែង៕



នាថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តកែប** មានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការយល់ដឹងអំពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តថ្មីៗស្តីពីពន្ធដារ" ជូនដល់មន្ត្រីរាជការពន្ធដារនៃសាខាពន្ធដារខេត្តកែប កំពត ព្រះសីហនុ កោះកុង តាកែវ និងកំពង់ស្ពឺ ព្រមទាំងអាជ្ញាធរមូលដ្ឋាន តំណាងមន្ទីរ អង្គភាពជំនាញ សភាពាណិជ្ជកម្ម ភ្នាក់ងារកាត់ទុក និងអ្នកជាប់ពន្ធ សរុបប្រមាណ **១៥០ រូប** ក្រោមអធិបតីភាព លោក **សេខ ជាសិទ្ធ** ប្រធាននាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ និង ឯកឧត្តម **អ៊ឹម បញ្ញារិទ្ធិ** អភិបាលរងនៃគណៈអភិបាលខេត្តកែប។




នាថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តមណ្ឌលគិរី** មានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ពន្ធលើអចលនទ្រព្យ ពន្ធប្រថាប់ត្រាលើការផ្ទេរសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យនិងកម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ (GDT e-Administration)" ជូនដល់អាជ្ញាធរមូលដ្ឋាន ថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃរដ្ឋបាលខេត្តមណ្ឌលគិរីព្រមទាំងតំណាងមន្ទីរអង្គភាពជំនាញក្រោមអធិបតីភាព ឯកឧត្តម **ស៊ីន សារុន** អភិបាលរងនៃគណៈអភិបាលខេត្តមណ្ឌលគិរី ដោយមានការចូលរួមពី លោក **អ៊ុំខ តិចណិញ** ប្រធានសាខាពន្ធដារខេត្តមណ្ឌលគិរី។



នាថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តរតនគិរី** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "កម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ (GDT e-Administration) កម្មវិធីត្រួតពិនិត្យ និងតាមដានឯកសារ (GDT Check & Track) និងកាតព្វកិច្ចពន្ធលើអចលនទ្រព្យ" ជូនដល់អាជ្ញាធរមូលដ្ឋាន ថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃរដ្ឋបាលខេត្តរតនគិរីព្រមទាំងតំណាងមន្ទីរអង្គភាពជំនាញក្រោមអធិបតីភាព ឯកឧត្តម **ខិន ណៃណល** អភិបាលរងនៃគណៈអភិបាលខេត្តរតនគិរី ដោយមានការចូលរួមពី លោក **ផាត់ កែវមុនី** ប្រធានសាខាពន្ធដារខេត្តរតនគិរី។



នាថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តកំពង់ចាម** មានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "វិធាននៃការប្រើប្រាស់វិក្កយបត្រ បញ្ជីគណនេយ្យសាមញ្ញសម្រាប់អ្នកជាប់ពន្ធតូច និងកម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw App)" សម្រាប់អ្នកជាប់ពន្ធចំនួន **៧៨ រូប** ក្រោមអធិបតីភាព លោកស្រី **ចាន់ ស៊ីថា** អនុប្រធានសាខាពន្ធដារខេត្តកំពង់ចាម៕



នាថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តបន្ទាយមានជ័យ** មានរៀបចំសិក្ខាសាលាស្តីពី "ពន្ធលើផ្ទាំងផ្សព្វផ្សាយ និងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ" សម្រាប់អ្នកជាប់ពន្ធ ចំនួន **៥៤ រូប** ក្រោមអធិបតីភាព លោក **ឡាយ ហុង** អនុប្រធានសាខាពន្ធដារខេត្តបន្ទាយមានជ័យ៕



នាថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តសៀមរាប** មានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "សិទ្ធិនិងកាតព្វកិច្ចអ្នកជាប់ពន្ធ ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មតាមអនឡាញ (e-Filing) ប្រព័ន្ធបង់ប្រាក់ពន្ធតាមអនឡាញ (e-Payment) និងការប្រើប្រាស់កម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ (GDT e-Administration)" សម្រាប់អ្នកជាប់ពន្ធ ចំនួន **១២០ រូប** ក្រោមអធិបតីភាព លោក **អេង សុខា** អនុប្រធានសាខាពន្ធដារខេត្តសៀមរាប៕



នាថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តសៀមរាប** មានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "ការដាក់លិខិតប្រកាសពន្ធប្រចាំខែ ការប្រើប្រាស់កម្មវិធីប្រកាសពន្ធអាជីវកម្មសម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Prefiling App) និងការប្រើប្រាស់កម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ (GDT e-Administration)" សម្រាប់អ្នកជាប់ពន្ធ ប្រមាណ **១០០ រូប** ក្រោមអធិបតីភាព លោក **ហ៊ុយ លីច្រេង** អនុប្រធានសាខាពន្ធដារខេត្តសៀមរាប៕



នាថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តកណ្ដាល** មានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្ដីពី "បញ្ជីគណនេយ្យសាមញ្ញ កាតព្វកិច្ចសារពើពន្ធប្រចាំខែ និងប្រចាំឆ្នាំ និងកម្មវិធីប្រកាសពន្ធអាជីវកម្មសម្រាប់អ្នកជាប់ពន្ធតូច (GDTTaxPrefilingApp)" សម្រាប់អ្នកជាប់ពន្ធ ចំនួន **៨៨ រូប** ក្រោមអធិបតីភាព លោក **ខួន សុវណ្ណា** ប្រធានសាខាពន្ធដារខេត្តកណ្ដាល។



នាថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខណ្ឌពោធិ៍សែនជ័យ** មានរៀបចំសិក្ខាសាលា ស្ដីពី "វិធាន វិក្កយបត្រ និងកាតព្វកិច្ចសារពើពន្ធរបស់សហគ្រាសចុះបញ្ជីថ្មី សម្រាប់អ្នកជាប់ពន្ធមធ្យម" ដែលបានចំនួន **៤០ រូប** ក្រោមអធិបតីភាព លោក **មុត ណុច** ប្រធានសាខាពន្ធដារខណ្ឌពោធិ៍សែនជ័យ។



នាថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខណ្ឌដូនពេញ** មានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្ដីពី "ពង្រឹងការប្រើប្រាស់វិធានវិក្កយបត្រ សិទ្ធិនិងកាតព្វកិច្ចអ្នកជាប់ពន្ធ និងកម្មវិធីប្រកាសពន្ធអាជីវកម្មសម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Prefiling App)" សម្រាប់អ្នកជាប់ពន្ធមធ្យមដែលបានចុះបញ្ជីថ្មី ចំនួន **៤១ រូប** ក្រោមអធិបតីភាព លោក **ខា ម៉េងហួត** ប្រធានសាខាពន្ធដារខណ្ឌដូនពេញ។



នាថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តកំពង់ចាម** មានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្ដីពី "ពន្ធលើអចលនទ្រព្យ" សម្រាប់អាជ្ញាធរមូលដ្ឋាន រួមមាន ចៅសង្កាត់ មេភូមិ និងប្រជាពលរដ្ឋ ក្នុងក្រុងកំពង់ចាម ចំនួន **៧០ រូប** ក្រោមអធិបតីភាព លោក **ហោខ កុសលបុត្រ** ប្រធានសាខាពន្ធដារខេត្តកំពង់ចាម។



នាថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តព្រៃវែង** មានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "កម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ (GDT e-Administration) ការដាក់លិខិតប្រកាសពន្ធតាមអនឡាញ (e-Filing) និងមុខងារស្នើសុំកែតម្រូវលិខិតប្រកាសពន្ធតាមអនឡាញ" សម្រាប់អ្នកជាប់ពន្ធ ចំនួន **៤១ រូប** ក្រោមអធិបតីភាព លោក **សំ សារ៉ាវុធ** អនុប្រធានសាខាពន្ធដារខេត្តព្រៃវែង។



នាថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តកំពត** មានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "ការប្រកាសពន្ធអាជីវកម្មសម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Prefiling App) និងវិធានវិក្កយបត្រ" សម្រាប់អ្នកជាប់ពន្ធ ក្រោមអធិបតីភាព លោក **មាស សាម៉េត** អនុប្រធានសាខាពន្ធដារខេត្តកំពត។



នាថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តព្រះសីហនុ** មានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "ការប្រកាសពន្ធតាមអនឡាញសម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Prefiling App)" សម្រាប់អ្នកជាប់ពន្ធចំនួន **៦៨ រូប** ក្រោមអធិបតីភាព លោក **អ៊ុំ សុទ្ធា** អនុប្រធានសាខាពន្ធដារខេត្តព្រះសីហនុ។



នាថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តតាកែវ** មានរៀបចំសិក្ខាសាលាស្តីពី "កម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ (GDT e-Administration) និងកម្មវិធីទូរស័ព្ទដៃអ្នកជាប់ពន្ធ (GDT Taxpayer App)" សម្រាប់អ្នកជាប់ពន្ធតូច និងអ្នកជាប់ពន្ធមធ្យមចំនួន **៣៤ រូប** ក្រោមអធិបតីភាព លោក **ខួន ពុទ្ធី** អនុប្រធានសាខាពន្ធដារខេត្តតាកែវ។



# គម្រោងវិនិយោគ ៣ប្រភេទ នៅខេត្តព្រះសីហនុទទួលបាន ការលើកទឹកចិត្តផ្នែកពន្ធដារក្រោមកម្មវិធីពិសេសរបស់រាជរដ្ឋាភិបាលកម្ពុជា

រាជរដ្ឋាភិបាលនីតិកាលទី៧ បានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ក្នុងគោលដៅជំរុញការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចគ្រប់វិស័យ។ ក្នុងនោះមុំទី១ "ការអភិវឌ្ឍវិស័យគន្លឹះ និងប្រភពថ្មីនៃកំណើនសេដ្ឋកិច្ច" នៃបញ្ចកោណទី២ បានកំណត់អាទិភាពក្នុងការពន្លឿនការអភិវឌ្ឍខេត្តព្រះសីហនុ ឱ្យក្លាយទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង និងជាប៉ូលសេដ្ឋកិច្ចដ៏សំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចសម្រាប់កម្ពុជា។ ដើម្បីសម្រេចបាននូវគោលដៅជាយុទ្ធសាស្ត្រនេះ រាជរដ្ឋាភិបាលបានចេញសេចក្តីសម្រេចលេខ ០៧ សសរ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២៤ ស្តីពីការដាក់ចេញឱ្យអនុវត្តកម្មវិធីពិសេសជំរុញការវិនិយោគ ក្នុងខេត្តព្រះសីហនុ ឆ្នាំ២០២៤ ដោយផ្តល់ការលើកទឹកចិត្តជាច្រើន រួមទាំងការលើកទឹកចិត្តផ្នែកពន្ធដារផង ព្រមទាំងសម្រួលនីតិវិធីផ្សេងទៀតផង ជូនដល់វិនិយោគិនដែលមានបំណងវិនិយោគនៅខេត្តព្រះសីហនុ ទាំងវិនិយោគិនខ្មែរ និងបរទេស។

គម្រោងវិនិយោគ ៣ប្រភេទ រួមមាន ១.គម្រោងវិនិយោគពាក់ព័ន្ធអគារជាប់គាំង ពោលគឺគម្រោងនានាដែលបានសាងសង់ហើយបានផ្អាក ពន្យារ ឬបញ្ឈប់ការសាងសង់ក្នុងខេត្តព្រះសីហនុចាប់ពីឆ្នាំ២០១៦ ២.គម្រោងវិនិយោគដែលអាចចាប់ផ្តើមអនុវត្តបានភ្លាមៗនៅក្នុងឆ្នាំ២០២៤ និង ៣.ការពង្រីកគម្រោងដែលមានស្រាប់ គម្រោងទាំង៣ប្រភេទនឹងទទួលបានការលើកទឹកចិត្តផ្នែកពន្ធដារជាច្រើន ដែលជាអាទិ៍មានការលើកលែងនូវប្រភេទពន្ធអាករសំខាន់ៗមួយចំនួន លើកលែងកម្រៃសេវាចុះបញ្ជី សម្រួលនីតិវិធីបង់ពន្ធជាកញ្ចប់តាមដំណាក់កាល លើកលែងទណ្ឌកម្មរដ្ឋបាលចំពោះការធ្វើសវនកម្មពន្ធដារ ព្រមទាំងផ្តល់ការលើកទឹកចិត្ត ដោយពន្ធអាករជាបន្ទុករបស់រដ្ឋលើការផលិត និង/ឬការផ្សព្វផ្សាយអំពីផលិតផលទេសចរណ៍ គោលដៅទេសចរណ៍ក្នុងខេត្តព្រះសីហនុផងដែរ។

ដើម្បីទទួលបានការលើកទឹកចិត្តក្រោមកម្មវិធីពិសេសនេះ វិនិយោគិនខ្មែរ និងបរទេស និវាសនជន ឬអនិវាសនជនអាចដាក់ពាក្យស្នើសុំមកក្រុមការងារជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុដែលមានទីតាំង ២កន្លែងគឺ នៅខេត្តព្រះសីហនុស្ថិតនៅផ្លូវជាតិលេខ៤ ភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ឬនៅរាជធានីភ្នំពេញ ស្ថិតនៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច ជាន់ទី២១ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ។ ចំពោះព័ត៌មានបន្ថែមអំពីការលើកទឹកចិត្តផ្នែកពន្ធដារក្នុងកម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុក្នុងឆ្នាំ២០២៤ លោកអ្នកអាចអញ្ជើញមកកាន់បញ្ជរពិគ្រោះយោបល់ផ្នែកពន្ធដារ នៃសាខាពន្ធដារខេត្តព្រះសីហនុ ឬតាមរយៈមជ្ឈមណ្ឌលពិគ្រោះយោបល់របស់អគ្គនាយកដ្ឋានពន្ធដារដែលមានលេខ១២៧៧ ដោយឥតគិតថ្លៃ រៀងរាល់ម៉ោងធ្វើការ៕



បញ្ជរពិគ្រោះយោបល់ផ្នែកពន្ធដារ





លោកអ្នកអាចអញ្ជើញមកកាន់បញ្ជរពិគ្រោះយោបល់ ផ្នែកពន្ធដារនៃសាខាពន្ធដារខេត្តព្រះសីហនុ

( ទីតាំងសាខាពន្ធដារខេត្តព្រះសីហនុ )

សូមស្កេន ដើម្បីទស្សនាវីដេអូ ការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់ខេត្តព្រះសីហនុ

## កម្មវិធីទូរស័ព្ទដៃពេញនិយមទាំង ១០ របស់អគ្គនាយកដ្ឋានពន្ធដារ

**កម្មវិធីទូរស័ព្ទដៃអ្នកជាប់ពន្ធ (GDT Taxpayer App)**
សម្រាប់បង់ពន្ធលើអចលនទ្រព្យ ពន្ធលើមធ្យោបាយដឹកជញ្ជូន និងពន្ធលើផ្ទាំងផ្សព្វផ្សាយ

**កម្មវិធីប្រកាសពន្ធសម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Prefiling App)**
សម្រាប់ប្រកាសពន្ធប្រចាំខែ និងប្រចាំឆ្នាំ របស់សហគ្រាសដែលជាអ្នកជាប់ពន្ធតូច

**កម្មវិធីត្រួតពិនិត្យ និងតាមដានឯកសារ (GDT Check & Track App)**
សម្រាប់តាមដានឯកសារដែលបានដាក់ស្នើមករដ្ឋបាលសារពើពន្ធ ពិនិត្យភាពត្រឹមត្រូវនៃឯកសារដែលមាន QR Code ចេញដោយអគ្គនាយកដ្ឋានពន្ធដារ

**កម្មវិធីគណនាពន្ធលើប្រាក់បៀវត្ស (GDT Salary Tax Calculation App)**
សម្រាប់គណនាពន្ធលើប្រាក់បៀវត្សប្រចាំខែដែលត្រូវបង់

**កម្មវិធីគណនាពន្ធលើមធ្យោបាយដឹកជញ្ជូន (GDT Means of Transportation Tax Calculation App)**
សម្រាប់គណនាប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូន ដែលត្រូវបង់ប្រាក់ពន្ធប្រចាំឆ្នាំ

**ព័ត៌មានពន្ធដារ (GDT News App)**
សម្រាប់ទទួលបានព័ត៌មាន វគ្គបណ្តុះបណ្តាល សិក្ខាសាលា ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត វីដេអូផ្សេងៗទៀតស្តីពីពន្ធដារ...

**កម្មវិធីជជែកផ្ទាល់ជាមួយពន្ធដារ (GDT Live Chat App)**
សម្រាប់សាកសួរព័ត៌មានផ្សេងៗស្តីពីពន្ធដារ ( ផ្នែកពន្ធទូទៅ និង e-Tax Service )

**ប្រតិទិនពន្ធដារ (GDT Calendar App)**
អាចពិនិត្យកាលបរិច្ឆេទដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធប្រចាំខែ និងឆ្នាំ

**កម្មវិធីសទ្ទានុក្រមពន្ធដារ (Tax Glossary App)**
សម្រាប់ស្វែងរកពាក្យគន្លឹះផ្សេងៗស្តីពីពន្ធដារ

**កម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw App)**
សម្រាប់បញ្ចូលវិក្កយបត្រ ដើម្បីចូលរួមផ្សងសំណាងឈ្នះរង្វាន់ជាច្រើនពីអគ្គនាយកដ្ឋានពន្ធដារ

## តើលោក-លោកស្រី បានឈ្វេងយល់អំពីព្រឹត្តិបត្រនេះបានកម្រិតណាដែរ? លោក-លោកស្រី អាចសាកល្បងឆ្លើយនូវសំណួរខាងក្រោម៖

១. តើរាជរដ្ឋាភិបាលបានចេញសេចក្តីសម្រេច ស្តីពីការដាក់ចេញឱ្យអនុវត្តកម្មវិធីពិសេសជំរុញការវិនិយោគ ក្នុងខេត្តព្រះសីហនុ ឆ្នាំ២០២៤ នៅថ្ងៃខែឆ្នាំណា?

- ក. ថ្ងៃទី១០ ខែមករា ឆ្នាំ២០២៤
- ខ. ថ្ងៃទី២១ ខែមករា ឆ្នាំ២០២៤
- គ. ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៤
- ឃ. ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៤

២. តើពន្ធលើអចលនទ្រព្យឆ្នាំ២០២៤ ផុតកំណត់នៅពេលណា?

- ក. ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៤
- ខ. ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤
- គ. ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤
- ឃ. ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៤

៣. តើពន្ធលើមធ្យោបាយដឹកជញ្ជូនឆ្នាំ២០២៤ ចាប់ផ្តើមប្រមូលពីពេលណា ដល់ពេលណា?

- ក. ចាប់ប្រមូលពីថ្ងៃទី១ ខែមិថុនា ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៤
- ខ. ចាប់ប្រមូលពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៤

៤. តើកម្មវិធីពន្ធដារកម្ពុជា មានការផ្សាយផ្ទាល់នៅរៀងរាល់ថ្ងៃណា?

- ក. ថ្ងៃច័ន្ទ
- ខ. ថ្ងៃព្រហស្បតិ៍
- គ. ថ្ងៃសុក្រ
- ឃ. ថ្ងៃពុធ

៥. តើទស្សនិកជនអាចលើកជាសំណួរក្នុងកម្មវិធីពន្ធដារកម្ពុជាបានដោយរបៀបណា?

- ក. ១២៧៧
- ខ. Comment ក្នុង Facebook page
- គ. GDT Live Chat
- ឃ. ចម្លើយទាំងអស់ត្រឹមត្រូវ

៦. តើ Call Center មានលេខប៉ុន្មាន?

- ក. ១២៧៧
- ខ. ១២៧២
- គ. ១២២២
- ឃ. ១២៥២

៧. តើរថយន្ត Ford Ranger ឆ្នាំផលិត២០២៤ ទ្វារ៤ ត្រូវបង់ពន្ធលើមធ្យោបាយដឹកជញ្ជូនក្នុងឆ្នាំ២០២៤ ដោយចាត់ជាប្រភេទរថយន្តទេសចរណ៍ ឬរថយន្តដឹកទំនិញ?

- ក. រថយន្តទេសចរណ៍
- ខ. រថយន្តដឹកទំនិញ

៨. តើសហគ្រាសចុះបញ្ជីដំបូងក្នុងថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ ត្រូវបង់ពន្ធប៉ាតង់មួយឆ្នាំពេញ ឬពាក់កណ្តាលឆ្នាំ?

- ក. ពាក់កណ្តាលឆ្នាំ
- ខ. ពេញមួយឆ្នាំ

៩. តើប្រភពព័ត៌មានសំខាន់ៗរបស់អគ្គនាយកដ្ឋានពន្ធដារមានអ្វីខ្លះ?

- ក. គេហទំព័រអគ្គនាយកដ្ឋានពន្ធដារ
- ខ. ទំព័រហ្វេសប៊ុកផ្លូវការ និងតេលេក្រាម
- គ. YouTube Channel
- ឃ. ចម្លើយទាំងអស់ត្រឹមត្រូវ

១០. តើអ្នកជាប់ពន្ធតូច អាចបំពេញកាតព្វកិច្ចពន្ធតាមរយៈកម្មវិធីឈ្មោះអ្វី?

- ក. GDT Lucky Draw App
- ខ. GDT Live Chat
- គ. GDT Tax Prefiling App
- ឃ. GDT Taxpayer App

១១. តើកម្មវិធី GDT e-Administration អាចដាក់ពាក្យស្នើសុំបិទសហគ្រាសសម្រាប់អ្នកជាប់ពន្ធតូចបានដែរឬទេ?

- ក. បាន
- ខ. មិនបាន

១២. តើអគ្គនាយកដ្ឋានពន្ធដារមានប្រព័ន្ធឬកម្មវិធីសម្រាប់អ្នកជាប់ពន្ធតាមដានឯកសារដែលស្នើសុំមករដ្ឋបាលសារពើពន្ធដែរឬទេ? បើមានឈ្មោះអ្វី?

- ក. មាន កម្មវិធីត្រួតពិនិត្យនិងតាមដានឯកសារ GDT Check & Track App
- ខ. មិនមាន អ្នកជាប់ពន្ធត្រូវមកជួបមន្ត្រីពន្ធដារដោយផ្ទាល់

១៣. តើអ្នកជាប់ពន្ធអាចគណនាប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូនតាមកម្មវិធីអ្វី?

- ក. GDT Live Chat
- ខ. GDT Lucky Draw App
- គ. GDT Means of Transportation
- ឃ. GDT Tax Prefiling App

១៤. តើចំណូលតាមប្រភេទអ្នកជាប់ពន្ធមួយណាដែលដើរតួនាទីស្នូលនៃចំណូលពន្ធដារ?

- ក. អ្នកជាប់ពន្ធធំ
- ខ. អ្នកជាប់ពន្ធមធ្យម
- គ. អ្នកជាប់ពន្ធតូច
- ឃ. អ្នកជាប់ពន្ធផ្សេងៗទៀត

១៥. តើលោកអ្នកអាចបញ្ចូលវិក្កយបត្រដើម្បីចូលរួមផ្សងសំណាងតាមរយៈកម្មវិធីឈ្មោះអ្វី?

- ក. GDT News App
- ខ. GDT Lucky Draw App
- គ. Tax Glossary App
- ឃ. GDT Check and Track App

---

**ចម្លើយ**

| សំណួរ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ចម្លើយ | ក | ឃ | ក | ខ | ឃ | ក | ក | ខ | ឃ | គ | ក | ក | គ | ក | ខ |




# អគ្គនាយកដ្ឋានពន្ធដារ

## សូមស្វាគមន៍

**សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច លេខតំណភ្ជាប់របស់អង្គភាព**

**(ដោយមិនចាំបាច់ជ្រើសរើសភាសា)**

**ដើម្បីទាក់ទងទៅកាន់នាយកដ្ឋាន ឬសាខាពន្ធដារខេត្ត-ខណ្ឌ**

**ដោយឥតគិតថ្លៃ**

អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
សារអេឡិចត្រូនិក: gdt@tax.gov.kh លេខទូរស័ព្ទ: (855) 23 266 668

## អាសយដ្ឋាននាយកដ្ឋាន សាលាជាតិពន្ធដារ ទីចាត់ការពន្ធដាររាជធានីភ្នំពេញ និងសាខាពន្ធដារខេត្ត-ខណ្ឌ

## នាយកដ្ឋានថ្នាក់កណ្ដាល សាលាជាតិពន្ធដារ និងទីចាត់ការពន្ធដាររាជធានីភ្នំពេញ

### នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ

អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ១០៩៩
សារអេឡិចត្រូនិក: admin.info@tax.gov.kh

### នាយកដ្ឋានហិរញ្ញវត្ថុ និងបុគ្គលិក

អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ១៨០០
សារអេឡិចត្រូនិក: dfp@tax.gov.kh

### នាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ

អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ២១០០
សារអេឡិចត្រូនិក: dlpic@tax.gov.kh

### នាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ

អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ២៧០១
សារអេឡិចត្រូនិក: dpt@tax.gov.kh

### នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន

អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៨០១៤
សារអេឡិចត្រូនិក: dit@tax.gov.kh

### នាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ

អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៣២០១
សារអេឡិចត្រូនិក: dtci@tax.gov.kh

### នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ

អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៣៦០១
សារអេឡិចត្រូនិក: dlt@tax.gov.kh

### នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម

អគារជាន់ទី១៩ ផ្លូវ១០២ មជ្ឈមណ្ឌលភ្នំពេញ ភូមិ១ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៤៩០០
សារអេឡិចត្រូនិក: dsmt@tax.gov.kh

### នាយកដ្ឋានសវនកម្មសហគ្រាស

អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៥៦០០
សារអេឡិចត្រូនិក: dea@tax.gov.kh

### សាលាជាតិពន្ធដារ

អគារលេខ៤១-៤៣ ផ្លូវ១១២ សង្កាត់ផ្សារដេប៉ូ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ (ខាងកើតអគ្គនាយកដ្ឋានពន្ធដារ)
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៦៤០១
សារអេឡិចត្រូនិក: nts@tax.gov.kh

### ទីចាត់ការពន្ធដាររាជធានីភ្នំពេញ

អគារជាន់ទី១៨ ផ្លូវ១០២ មជ្ឈមណ្ឌលភ្នំពេញ ភូមិ១ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៦៨០១
សារអេឡិចត្រូនិក: ppmd@tax.gov.kh

## សាខាពន្ធដារខណ្ឌ

### សាខាពន្ធដារ ខណ្ឌឫស្សីកែវ

អគារ១០២ ផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩០០៧
សារអេឡិចត្រូនិក: russeykeo@tax.gov.kh

### សាខាពន្ធដារ ខណ្ឌដូនពេញ

ផ្ទះលេខ១៦៦ ផ្លូវលេខ១៣០ សង្កាត់ផ្សារកណ្ដាលទី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩០៣២
សារអេឡិចត្រូនិក: daunpenh@tax.gov.kh

### សាខាពន្ធដារ ខណ្ឌ៧មករា

ដីឡូលេខ០៥ ផ្លូវលេខ១៥០ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩០៥៧
សារអេឡិចត្រូនិក: 7makara@tax.gov.kh

### សាខាពន្ធដារ ខណ្ឌមានជ័យ

អគារលេខ៣៤C ផ្លូវ៣៦១ កែងផ្លូវ៦៤២ សង្កាត់ច្បារអំពៅ១ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩០៨៣
សារអេឡិចត្រូនិក: meanchey@tax.gov.kh

### សាខាពន្ធដារ ខណ្ឌចំការមន

អគារលេខ២៨ ផ្លូវលេខ៤៨៨ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩១០៩
សារអេឡិចត្រូនិក: chamkarmorn@tax.gov.kh

### សាខាពន្ធដារ ខណ្ឌទួលគោក

ផ្ទះលេខ២៤ ផ្លូវ២៨៧ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩១៣៥
សារអេឡិចត្រូនិក: tuolkork@tax.gov.kh

### សាខាពន្ធដារ ខណ្ឌដង្កោ

ផ្លូវ២១៧ ភូមិល្វេស សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩១៦១
សារអេឡិចត្រូនិក: dangkor@tax.gov.kh

### សាខាពន្ធដារ ខណ្ឌសែនសុខ

អគារលេខ៩ ផ្លូវលេខ១០១៩(ហាណូយ) សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩១៨៨
សារអេឡិចត្រូនិក: sensok@tax.gov.kh

### សាខាពន្ធដារ ខណ្ឌពោធិ៍សែនជ័យ

ផ្ទះលេខ២៣៤B ផ្លូវលេខ ២០០៧ សង្កាត់កាកាប១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩២១៣
សារអេឡិចត្រូនិក: porsenchey@tax.gov.kh

## សាខាពន្ធដារខេត្ត

### សាខាពន្ធដារ ខេត្តបន្ទាយមានជ័យ

ភូមិក្បាលស្ពាន សង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ(ខាងត្បូងស្ពានសៃសិនចំងាយ ៣០០ម៉ែត្រ តាមបណ្តោយផ្លូវជាតិលេខ៥ ឆ្ពោះទៅកាន់ស្រុកមង្គលបូរី)
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៧០៨
សារអេឡិចត្រូនិក: banteaymeanchey@tax.gov.kh

### សាខាពន្ធដារ ខេត្តបាត់ដំបង

ផ្ទះលេខ២ ផ្លូវជាតិលេខ៥ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩២៩២
សារអេឡិចត្រូនិក: battambang@tax.gov.kh

### សាខាពន្ធដារ ខេត្តកំពង់ចាម

ផ្ទះលេខ៥ ភូមិទី១៥ ផ្លូវខេមរភូមិន្ទ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម ខេត្តកំពង់ចាម
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩២៦៥
សារអេឡិចត្រូនិក: kampongcham@tax.gov.kh

### សាខាពន្ធដារ ខេត្តកំពង់ឆ្នាំង

ភូមិឃ្លាំងប្រាក់ សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៤៧៣
សារអេឡិចត្រូនិក: kampongchhnang@tax.gov.kh

### សាខាពន្ធដារ ខេត្តកំពង់ធំ

ភូមិបល្ល័ង្កលិច សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៣៦៩
សារអេឡិចត្រូនិក: kampongthom@tax.gov.kh

### សាខាពន្ធដារ ខេត្តកំពង់ស្ពឺ

ផ្លូវជាតិលេខ៤ ភូមិត្រពាំងលើក សង្កាត់រកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៤៩៩
សារអេឡិចត្រូនិក: kampongspeu@tax.gov.kh

### សាខាពន្ធដារ ខេត្តកំពត

ផ្លូវលេខ៧២៩ ភូមិ១ឧសភា សង្កាត់កំពង់កណ្តាល ក្រុងកំពត ខេត្តកំពត
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៥២៦
សារអេឡិចត្រូនិក: kampot@tax.gov.kh

### សាខាពន្ធដារ ខេត្តកណ្តាល

អគារលេខ២៦ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩២៣៩
សារអេឡិចត្រូនិក: kandal@tax.gov.kh

### សាខាពន្ធដារ ខេត្តកោះកុង

អគារកែងផ្លូវលេខ៩០០ និងផ្លូវលេខ៩៩៥ ភូមិ២ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៥៧៧
សារអេឡិចត្រូនិក: kohkong@tax.gov.kh

### សាខាពន្ធដារ ខេត្តក្រចេះ

ភូមិក្រចេះ សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៦៣០
សារអេឡិចត្រូនិក: kratie@tax.gov.kh

### សាខាពន្ធដារ ខេត្តមណ្ឌលគិរី

ផ្លូវលេខ ៣៧៦៣ ភូមិកណ្តាល សង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៦៨១
សារអេឡិចត្រូនិក: mondulkiri@tax.gov.kh

### សាខាពន្ធដារ ខេត្តព្រៃវែង

អាគារកែងផ្លូវលេខ៥ និងផ្លូវលេខ៣ ភូមិ២ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៣១៨
សារអេឡិចត្រូនិក: preyveng@tax.gov.kh

### សាខាពន្ធដារ ខេត្តព្រះវិហារ

ភូមិអណ្តូងពោធិ៍ សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៦០៤
សារអេឡិចត្រូនិក: preahvihear@tax.gov.kh

### សាខាពន្ធដារ ខេត្តពោធិ៍សាត់

ផ្លូវជាតិលេខ៥ ភូមិមាន់ចៃ សង្កាត់ព្រៃញី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៤៤៧
សារអេឡិចត្រូនិក: pursat@tax.gov.kh

### សាខាពន្ធដារ ខេត្តរតនគិរី

ផ្លូវលេខ ២០ ភូមិថ្មដា សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៦៥៥
សារអេឡិចត្រូនិក: ratanakiri@tax.gov.kh

### សាខាពន្ធដារ ខេត្តសៀមរាប

ផ្លូវជាតិលេខ 6 ភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៣៤៣
សារអេឡិចត្រូនិក: siamreap@tax.gov.kh

### សាខាពន្ធដារ ខេត្តព្រះសីហនុ

វិថី ២៨មិថុនា ភូមិ០១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៥៥២
សារអេឡិចត្រូនិក: preahsihanouk@tax.gov.kh

### សាខាពន្ធដារ ខេត្តស្ទឹងត្រែង

ផ្លូវភូមិស្ពានថ្ម សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៧៣៣
សារអេឡិចត្រូនិក: stoengtreng@tax.gov.kh

### សាខាពន្ធដារ ខេត្តស្វាយរៀង

ផ្លូវលេខ១១៤ ភូមិពោងបន្លែ សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ខេត្តស្វាយរៀង
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៤២១
សារអេឡិចត្រូនិក: svayrieng@tax.gov.kh

### សាខាពន្ធដារ ខេត្តតាកែវ

ភូមិ១ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៣៩៦
សារអេឡិចត្រូនិក: takeo@tax.gov.kh

### សាខាពន្ធដារ ខេត្តឧត្តរមានជ័យ

អគារខាងលិចសាលាខេត្ត ទល់មុខវិមានឯករាជ្យ ភូមិបុរីវឌ្ឍបាល សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៨១១
សារអេឡិចត្រូនិក: odormeanchey@tax.gov.kh

### សាខាពន្ធដារ ខេត្តកែប

ផ្លូវលេខ២៣៥០ ភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៧៥៩
សារអេឡិចត្រូនិក: kep@tax.gov.kh

### សាខាពន្ធដារ ខេត្តប៉ៃលិន

ភូមិប៉ាហ៊ីត្បូង សង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខេត្តប៉ៃលិន
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៧៨៥
សារអេឡិចត្រូនិក: pailin@tax.gov.kh

### សាខាពន្ធដារ ខេត្តត្បូងឃ្មុំ

ភូមិនិគមលើ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ (ជាប់ខាងត្បូងសាលាឧទ្ទេសណ៍ខេត្តត្បូងឃ្មុំ)
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៨៣៧
សារអេឡិចត្រូនិក: tboungkhmum@tax.gov.kh

# កម្មវិធីរៀនអំពីពន្ធដារតាមអនឡាញ ( GDT E-Learning)




ការផ្តល់សេវាអប់រំចំពោះអ្នកជាប់ពន្ធ(**TaxEducation**)គឺជាផ្នែកមួយនៃការផ្តល់សេវាអ្នកជាប់ពន្ធនិងជាមុខងារស្នូលដ៏សំខាន់មួយដែលអគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងយកចិត្តទុកដាក់ខ្ពស់ ដើម្បីលើកកម្ពស់ការយល់ដឹងរបស់អ្នកជាប់ពន្ធអំពីពន្ធអាករគ្រប់ប្រភេទ ក្នុងគោលបំណងពង្រឹងអនុលោមភាពសារពើពន្ធដោយស្ម័គ្រចិត្ត និងជំរុញការគ្រប់គ្រងប្រមូលចំណូលពន្ធប្រកបដោយប្រសិទ្ធភាពខ្ពស់ក្នុងនោះកម្មវិធីសិក្សាពីចម្ងាយ (តាមប្រព័ន្ធអនឡាញ) ជាមធ្យោបាយដ៏សមស្រប និងពេញនិយមមួយសម្រាប់សាធារណជននិងអ្នកជាប់ពន្ធអាចសិក្សាឈ្វេងយល់អំពីពន្ធដារទោះបីជាមានការមមាញឹកក្នុងការប្រកបអាជីវកម្ម ឬបំពេញការងាររបស់ខ្លួនយ៉ាងណាក្តី។

ឆ្លើយតបនឹងតម្រូវការនេះ អគ្គនាយកដ្ឋានពន្ធដារបានបង្កើតឱ្យមានកម្មវិធី "**រៀនអំពីពន្ធដារតាមអនឡាញ (GDT E-Learning)**" ដែលជាកម្មវិធីសិក្សាពីចម្ងាយតាមប្រព័ន្ធអេឡិចត្រូនិកតាមរយៈវីដេអូបង្រៀនអំពីពន្ធអាករគ្រប់ប្រភេទ ដោយមន្ត្រីជំនាញនៃអគ្គនាយកដ្ឋានពន្ធដារ និងមានការចាក់ផ្សាយជារៀងរាល់សប្តាហ៍ នៅថ្ងៃអង្គារ វេលាម៉ោង ១១:៣០នាទី។ កម្មវិធី "**រៀនអំពីពន្ធដារតាមអនឡាញ (GDT E-Learning)**" បានលើកយកប្រធានបទសំខាន់ៗមកធ្វើបទបង្ហាញដើម្បីចែករំលែកជាចំណេះដឹងជូនសាធារណជននិងអ្នកជាប់ពន្ធ ជាអាទិ៍មាន ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ ពន្ធកាត់ទុក ពន្ធលើប្រាក់បៀវត្ស អាករលើតម្លៃបន្ថែម ពន្ធប៉ាតង់ កិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា (**DTA**) និងការបង្ការការគិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូលជាដើម។សាធារណជននិងអ្នកជាប់ពន្ធដែលខកខានមិនបានទស្សនាការចាក់ផ្សាយកម្មវិធី "**រៀនអំពីពន្ធដារតាមអនឡាញ ( GDT E-Learning )**" ប្រចាំសប្តាហ៍តាមពេលវេលាខាងលើ ក៏អាចចូលទស្សនាឡើងវិញបានតាមរយៈ **Youtube Channel** ផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ៕

**សូមស្កេន ដើម្បីចូលទៅកាន់ Youtube Channel អគ្គនាយកដ្ឋានពន្ធដារ**

**https://www.youtube.com/@generaldepartmentoftaxation**

## កម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw App)

លោកអ្នកគ្រាន់តែថតវិក្កយបត្រដែលបានទិញទំនិញ-សេវា រួចបញ្ចូល (Upload) ក្នុងកម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw App) របស់អគ្គនាយកដ្ឋានពន្ធដារ នោះលោកអ្នកនឹងទទួលបានឱកាសឈ្នះរង្វាន់ដ៏សន្ធឹកសន្ធាប់ពីអគ្គនាយកដ្ឋានពន្ធដារ លើសពីនេះទៅទៀត លោកអ្នកក៏បានចូលរួមចំណែកក្នុងការបង្កើនចំណូលថវិកាជាតិ ដើម្បីចូលរួមអភិវឌ្ឍប្រទេសជាតិយើងផងដែរ៕

សូមស្កេន ដើម្បីទទួលបាន វីដេអូណែនាំពីកម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw App)






## កម្មវិធីទូរស័ព្ទដៃអ្នកជាប់ពន្ធ (GDT Taxpayer App)

សូមស្កេនដើម្បីទស្សនាវីដេអូណែនាំកម្មវិធីទូរស័ព្ទដៃសម្រាប់អ្នកជាប់ពន្ធ GDT Taxpayer App




កម្មវិធីទូរស័ព្ទដៃអ្នកជាប់ពន្ធ (GDT Taxpayer App) គឺជាកម្មវិធីទូរស័ព្ទដៃដែលផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធ អាចបង់ពន្ធនៅគ្រប់ទីកន្លែងបានតាមទូរស័ព្ទ លើប្រភេទពន្ធមួយចំនួនដូចជា ៖

- ពន្ធលើអចលនទ្រព្យ
- ពន្ធលើមធ្យោបាយដឹកជញ្ជូន និង
- ពន្ធលើផ្ទាំងផ្សព្វផ្សាយ។

សូមធ្វើការទាញយកកម្មវិធី GDT Taxpayer App ដើម្បីងាយស្រួលក្នុងការបង់ពន្ធ៕

## មជ្ឈមណ្ឌលពិគ្រោះយោបល់តាមទូរស័ព្ទរបស់អគ្គនាយកដ្ឋានពន្ធដារ (១២៧៧)
## មានចម្ងល់ពីពន្ធដារ មិនដឹងសួរនៅទីណាមែនទេ?

លោកអ្នកអាចទទួលសេវាពិគ្រោះយោបល់តាមទូរស័ព្ទដោយទាក់ទងមកលេខ ១២៧៧ ដោយឥតគិតថ្លៃ រៀងរាល់ថ្ងៃនិងម៉ោងធ្វើការ ដើម្បីសាកសួររាល់ចម្ងល់ទាំងឡាយស្ដីពីពន្ធដារ ដូចជា៖

- ច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្ដីពីពន្ធដារ
- សេវាកម្មអេឡិចត្រូនិក
- ការចុះបញ្ជីនិងការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ
- ពន្ធលើអចលនទ្រព្យ និងពន្ធលើដីធ្លីមិនបានប្រើប្រាស់
- ពន្ធប្រថាប់ត្រា
- ពន្ធលើមធ្យោបាយដឹកជញ្ជូន
- ការប្រកាសបង់ពន្ធទូទៅ និង
- ព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងពន្ធដារ




## ឬលោកអ្នកអាច Chat សួរសំណួរពីពន្ធដារតាម
## កម្មវិធី GDT Live Chat ដោយគ្រាន់តែស្កេន QR Code ខាងក្រោម



# ការបង់ពន្ធលើអចលនទ្រព្យកាន់តែងាយស្រួលតាមរយៈមុខងារថ្មី Quick Payment ក្នុងកម្មវិធីទូរស័ព្ទដៃអ្នកជាប់ពន្ធ ( GDT Taxpayer App )



**ជំហានទី១** ត្រូវជ្រើសរើសជម្រើសណាមួយក៏បានក្នុងចំណោមជម្រើសទាំង ៤ រួមមាន ៖

- ស្កេនបារកូដសម្គាល់អចលនទ្រព្យលើសេចក្ដីជូនដំណឹងបង់ប្រាក់ពន្ធលើអចលនទ្រព្យ ឬ
- ស្កេនបារកូដលើកាតសម្គាល់ការបង់ពន្ធលើអចលនទ្រព្យ ឬ
- បញ្ចូលលេខអត្តសញ្ញាណសម្គាល់អចលនទ្រព្យ (PIN) ឬ
- បញ្ចូលលេខបង្កាន់ដៃបង់ប្រាក់ពន្ធឆ្នាំចាស់









**ជំហានទី២**

ជ្រើសរើសធនាគារពាណិជ្ជដៃគូរបស់អគ្គនាយកដ្ឋានពន្ធដារណាមួយក៏បានដើម្បីបង់ប្រាក់ពន្ធជាការស្រេច។



GDT Taxpayer App




សូមស្កេន ដើម្បីទាញយកកម្មវិធី

Download on the App Store

GET IT ON Google Play

សូមស្កេនដើម្បីទស្សនាវីដេអូណែនាំកម្មវិធីទូរស័ព្ទដៃសម្រាប់អ្នកជាប់ពន្ធ GDT Taxpayer App

# កម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ ( GDT e-Administration)

**ដាក់លិខិតរដ្ឋបាលនិងឯកសារនានាមករដ្ឋបាលសារពើពន្ធបានពីគ្រប់ទីកន្លែង ដោយគ្រាន់តែប្រើប្រាស់កម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ ( GDT e-Administration ) តាមជំហានងាយៗដូចខាងក្រោម៖**

**ជំហានទី ១**

ចូលទៅកាន់គេហទំព័រផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ https://www.tax.gov.kh ជ្រើសរើសសេវាកម្មអេឡិចត្រូនិកពន្ធដារ និងទាញយក (**Download**) កម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ (**GDT e-Administration**) រួចដំឡើង (**Setup**) កម្មវិធីនេះនៅលើកុំព្យូទ័រជាការស្រេច។

**ជំហានទី ២**

ប្រើប្រាស់គណនីដែលមានស្រាប់ដូចធ្លាប់ចូលប្រើប្រាស់ប្រព័ន្ធ កម្មវិធីផ្សេងៗរបស់អគ្គនាយកដ្ឋានពន្ធដារ ក្នុងករណីមិនទាន់មានគណនី សូមចុះឈ្មោះប្រើប្រាស់ដោយចុច "**បង្កើតគណនីថ្មី**"។

**ជំហានទី ៣**

ជ្រើសរើសប្រភេទអ្នកប្រើប្រាស់ជា អ្នកជាប់ពន្ធ ឬភ្នាក់ងារសេវាកម្មពន្ធដារ ឬអ្នកតំណាងសហគ្រាស រួចបញ្ចូលព័ត៌មាន និងឯកសារដែលកម្មវិធីតម្រូវ។

**ជំហានទី ៤**

ចុចម៉ឺនុយ "**បង្កើតលិខិតរដ្ឋបាលថ្មី**" បន្ទាប់មកបញ្ចូលព័ត៌មានអ្នកស្នើសុំ កម្មវត្ថុនៃលិខិត និងខ្លឹមសារសង្ខេប រួចជ្រើសរើសអង្គភាពដែលត្រូវទទួលលិខិត។

**ជំហានទី ៥**

ភ្ជាប់លិខិតរដ្ឋបាលនិងឯកសារយោងផ្សេងៗ (**Attachment**) ជាទម្រង់ **PDF** បន្ទាប់មកពិនិត្យផ្ទៀងផ្ទាត់ព័ត៌មានដែលបានបញ្ចូលព្រមទាំងឯកសារភ្ជាប់ឡើងវិញ រួចចុចបញ្ជូនជាការស្រេច។



# ការប្រកាសនិងបង់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូនសម្រាប់ឆ្នាំ២០២៤




# អ្នកជាប់ពន្ធតូចកាន់តែងាយស្រួលក្នុងការបំពេញកាតព្វកិច្ចពន្ធ តាមរយៈកម្មវិធី ( GDT Tax Prefiling App)




ដើម្បីជួយសម្រួលដល់ការប្រកាសនិងបង់ប្រាក់ពន្ធរបស់អ្នកជាប់ពន្ធតូចអគ្គនាយកដ្ឋានពន្ធដារបានបង្កើតនិងដាក់ឱ្យប្រើប្រាស់កម្មវិធីទូរស័ព្ទដៃដែលមានឈ្មោះ កម្មវិធីប្រកាសពន្ធអាជីវកម្មសម្រាប់អ្នកជាប់ពន្ធតូច ( GDT Tax Prefiling App ) ដែលមានមុខងារកត់ត្រាទិន្នន័យទិញ-លក់ជួយគណនាប្រាក់ពន្ធដែលត្រូវបង់ក្នុងការប្រកាសពន្ធប្រចាំខែនិងប្រចាំឆ្នាំ ពិនិត្យមើលទិន្នន័យបំណុលពន្ធ និងបង់ប្រាក់ពន្ធ៕

សូមស្កេន ដើម្បីទាញយកកម្មវិធី
ប្រកាសពន្ធអាជីវកម្មសម្រាប់
អ្នកជាប់ពន្ធតូច
(GDT Tax Prefiling App)

Download on the App Store
GET IT ON Google Play

YouTube

សូមស្កេន ដើម្បីទស្សនាវីដេអូណែនាំអំពីការប្រើប្រាស់
GDT Tax Prefiling App

# ប្រភពព័ត៌មានអំពីពន្ធដារ




## គេហទំព័រហ្វេសប៊ុកផ្លូវការរបស់ អគ្គនាយកដ្ឋានពន្ធដារ

សូមស្វាគមន៍ការមកកាន់ប្រព័ន្ធផ្សព្វផ្សាយរបស់អគ្គនាយកដ្ឋានពន្ធដារ
សម្រាប់ការផ្សព្វផ្សាយ និងចែកចាយព័ត៌មានថ្មីៗរាល់ថ្ងៃពីពន្ធដារ ។

សូមស្កេនដើម្បីទទួលបានព័ត៌មានថ្មីៗរាល់ថ្ងៃពីពន្ធដារ



## ឆានែលតេឡេក្រាម ព័ត៌មានពន្ធដារកម្ពុជា

សូមស្វាគមន៍ការមកកាន់ប្រព័ន្ធផ្សព្វផ្សាយរបស់អគ្គនាយកដ្ឋានពន្ធដារ
សម្រាប់ការផ្សព្វផ្សាយ និងចែកចាយព័ត៌មានថ្មីៗរាល់ថ្ងៃពីពន្ធដារ ។

សូមស្កេនដើម្បីទទួលបានព័ត៌មានថ្មីៗរាល់ថ្ងៃពីពន្ធដារ




## តើលោកអ្នកនៅតែមានចម្ងល់ អំពី ពន្ធដារ មែនទេ?

ជួយសម្រួលដល់អ្នកជាប់ពន្ធ និងសាធារណជនដែលមានចម្ងល់ពាក់ព័ន្ធនឹងពន្ធដារ
បានជជែកផ្ទាល់ជាមួយមន្ត្រីជំនាញពន្ធដារតាមអនឡាញពីគ្រប់ទីកន្លែងរៀងរាល់ម៉ោងធ្វើការ

Download on the App Store
GET IT ON Google Play

សូមស្កេនដើម្បីទាញយកកម្មវិធី GDT LIVE CHAT




www.tax.gov.kh/km/tax-bulletin

សូមស្កេន QR Code
ដើម្បីទទួលបានព្រឹត្តិបត្រពន្ធដារ
តាមរយៈទូរស័ព្ទដៃ




www.tax.gov.kh/km/tax-news-letter

សូមស្កេន QR Code
ដើម្បីទទួលបាន
ព្រឹត្តិបត្រព័ត៌មានប្រចាំសប្តាហ៍
តាមរយៈទូរស័ព្ទដៃ




**សម្រាប់ព័ត៌មានបន្ថែមលោក-លោកស្រីអាចទំនាក់ទំនងតាមរយៈ**

Website Facebook Instagram Youtube

អាសយដ្ឋាន ៖ អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
មជ្ឈមណ្ឌលពិគ្រោះយោបល់ / **Call Center** ៖ ១២៧៧ (ដោយឥតគិតថ្លៃ) | គេហទំព័រ ៖ www.tax.gov.kh | សារអេឡិចត្រូនិក ៖ gdt@tax.gov.kh